# ជំពូកទី ៣
# ក្របខ័ណ្ឌច្បាប់

Draft

# ជំពូកទី ៣
# ក្របខណ្ឌច្បាប់

## ៣.១ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា (១៩៩៣)

រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ដែលអនុម័តដោយសភាធម្មនុញ្ញ នៅថ្ងៃទី២១ ខែកញ្ញា ឆ្នាំ ១៩៩៣ ត្រូវបានប្រកាសឲ្យប្រើប្រាស់ជាផ្លូវការដោយព្រះរាជក្រម ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ១៩៩៣។ គិតមកដល់ត្រឹម ខែមីនា ឆ្នាំ២០០៨ មានវិសោធនកម្ម ០៧ លើកត្រូវបានធ្វើ និងប្រកាសឲ្យប្រើប្រាស់។

- លើកទី១ ៖ ប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ(គ្មានព័ត៌មាន) ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ ១៩៩៤
- លើកទី២ ៖ ប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៣៩៩/០១ ចុះថ្ងៃទី០៨ ខែមិនា ឆ្នាំ១៩៩៤
- លើកទី៣ ៖ ប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៧០១/១១ ចុះថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០០១
- លើកទី៤ ៖ ប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៦០៥/០១៨ ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០០៥ «
- លើកទី៥ ៖ ច្បាប់រដ្ឋធម្មនុញ្ញបន្ថែម ប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០០៤
- លើកទី៦ ៖ ប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៣០៦/០០៦ ចុះថ្ងៃទី០៩ ខែមីនា ឆ្នាំ២០០៦
- លើកទី៧ ៖ ប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០២០៨/០០៨ ចុះថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០០១

មាត្រា ៥៨..

ទ្រព្យសម្បត្តិរបស់រដ្ឋមានជាអាទិ៍ ដីធ្លី ក្រោមដី ភ្នំ សមុទ្រ បាតសមុទ្រ ក្រោមបាតសមុទ្រ ឆ្នេរសមុទ្រ អាកាស កោះ ទន្លេ ព្រែក ស្ទឹង បឹង ព្រៃឈើ ធនធានធម្មជាតិ មជ្ឈមណ្ឌលសេដ្ឋកិច្ចវប្បធម៌ មូលដ្ឋានការពារប្រទេស សំណង់ផ្សេងៗទៀតដែលបានកំណត់ថាជារបស់រដ្ឋ។

ការគ្រប់គ្រង ការប្រើប្រាស់ និងការចាត់ចែងលើទ្រព្យសម្បត្តិរដ្ឋនឹងត្រូវកំណត់ក្នុងច្បាប់។

មាត្រា ៥៩..

រដ្ឋត្រូវរក្សាការពារបរិស្ថាន និងតុល្យភាពនៃភោគទ្រព្យធម្មជាតិ ហើយត្រូវចាត់ចែងឲ្យមានផែនការច្បាស់លាស់ក្នុងការគ្រប់គ្រងមានជាអាទិ៍ ដីធ្លី ទឹក អាកាស ខ្យល់ ភូគព្ភសាស្ត្រ ប្រព័ន្ធអេកូឡូស៊ី រ៉ែ ថាមពល ប្រេងកាត និងឧស្ម័ន ថ្ម និងខ្សាច់ ត្បូងថ្ម ព្រៃឈើ និងអនុផលព្រៃឈើ ពពួកសត្វព្រៃ មច្ឆាជាតិ ធនធានជលផល។

មាត្រា ៦១..

រដ្ឋជំរុញការអភិវឌ្ឍសេដ្ឋកិច្ចគ្រប់វិស័យ ជាពិសេសវិស័យកសិកម្ម សិប្បកម្ម ឧស្សាហកម្ម ចាប់ពីតំបន់ដាច់ស្រយាលដោយយកចិត្តទុកដាក់ទៅលើនយោបាយទឹក ភ្លើង ផ្លូវ និងមធ្យោបាយដឹកជញ្ជូនបច្ចេកទេសទំនើប និងប្រព័ន្ធឥណទាន។

Draft

មាត្រា ៦៩..

រដ្ឋមានកាតព្វកិច្ចថែរក្សា និងពង្រីកវប្បធម៌ជាតិ។

រដ្ឋមានកាតព្វកិច្ចការពារ និងពង្រីកភាសាខ្មែរឲ្យសមស្របនឹងសេចក្តីត្រូវការ។

រដ្ឋមានកាតព្វកិច្ចថែរក្សា និងការពារប្រាសាទបុរាណ សិល្បៈបុរាណ និងកែលម្អរមណីយដ្ឋានប្រវត្តិសាស្រ្តឡើងវិញ។

## ៣.២ ច្បាប់

### ៣.២.១ ច្បាប់ស្តីពីការវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា (១៩៩៤)

មាត្រា ១..

ច្បាប់នេះមានវិសាលភាពគ្របដណ្តប់លើការវិនិយោគនានា ដែលអនុវត្តន៍នៅលើទឹកដីនៃព្រះរាជាណាចក្រកម្ពុជាដោយអ្នកវិនិយោគជាជនជាតិខ្មែរ ឬជនបរទេស។

មាត្រា២..

អ្នកវិនិយោគទាំងអស់ត្រូវស្ថិតនៅក្រោមច្បាប់នេះ ហើយអាចជារូបវន្តបុគ្គលឬជានិតិបុគ្គល។

មាត្រា ៦..

អ្នកវិនិយោគត្រូវដាក់ពាក្យសុំនៅក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាដើម្បីពិនិត្យ និងសម្រេច។

មាត្រា ៧..

ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ត្រូវឆ្លើយតបអំពីការសម្រេចរបស់ខ្លួននៅអ្នកវិនិយោគក្នុងរយៈពេល ៤៥ ថ្ងៃ យ៉ាងយូរគិតពីថ្ងៃទទួលពាក្យសុំដែលបានបំពេញបែបបទត្រឹមត្រូវនិងគ្រប់គ្រាន់។ បើគ្មានមូលហេតុត្រឹមត្រូវ មន្រ្តីរាជការណាដែលប្រកែកមិនព្រមទទួលពិនិត្យ និងឆ្លើយតបអំពីការសម្រេចរបស់ខ្លួនទៅអ្នកវិនិយោគវិញ ហួសកាលកំណត់ខាងលើត្រូវផ្តន្ទាទោសតាមបញ្ញត្តិច្បាប់។

មាត្រា ១៧..

អ្នកវិនិយោគនៅព្រះរាជាណាចក្រកម្ពុជាមានសិទ្ធិធ្វើការជ្រើសរើស និងជួលនិយោជិតខ្មែរ និងបរទេស ដោយសេរីផ្អែកលើមូលដ្ឋាននៃច្បាប់ការងារ និងច្បាប់អន្តោប្រវេសន៍។

Draft

មាត្រា ២៣..

ក្នុងករណីដែលអ្នកវិនិយោគត្រូវបានអនុញ្ញាតឲ្យរំលាយក្រុមហ៊ុន ឬសហគ្រាសរបស់ខ្លួនជាផ្លូវការទោះតាមផ្លូវការ ទោះតាមផ្លូវតុលាការក្តី ឬក្រៅផ្លូវតុលាការក្តី អ្នកវិនិយោគអាចផ្ទេរនូវទ្រព្យសម្បត្តិដែលសេសសល់ទៅក្រៅប្រទេស ឬមួយប្រើប្រាស់នៅក្នុងព្រះរាជាណាចក្រកម្ពុជា។ ចំពោះគ្រឿងម៉ាស៊ីន និងសម្ភារៈបរិក្ខារដែលបានការអនុញ្ញាតឲ្យនាំចូលដោយរួចពន្ធហើយបានប្រើប្រាស់ក្នុងអំឡុងពេលតិចជាងប្រាំឆ្នាំ(៥ឆ្នាំ)អ្នកវិនិយោគត្រូវបង់ពន្ធតាមច្បាប់ជាធរមាន។

មាត្រា ២៥..

ក្នុងករណីដែលអ្នកវិនិយោគរំលោភ ឬមិនអនុវត្តន៍តាមលក្ខខណ្ឌទាំងឡាយដែលបានកំណត់ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាមានសិទ្ធិអំណាចដកហូតសិទ្ធិផ្សេងៗ និងផលប្រយោជន៍ទាំងអស់ ឬមួយផ្នែកដែលបានផ្តល់ជូនអ្នកវិនិយោគកន្លងមក។

## ៣.២.២ ច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ (១៩៩៦)

ច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ១៩៩៦ នាសម័យប្រជុំលើកទី៧ នីតិកាលទី១ និងត្រូវបានប្រកាសឲ្យប្រើប្រាស់ដោយព្រះរាជក្រម នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៦។ ខ្លឹមសារសំខាន់ៗ នៃច្បាប់រួមមាន ៖

មាត្រា ១..

ច្បាប់នេះមានគោលដៅ ៖

- ការពារ លើកកម្ពស់គុណភាពបរិស្ថាន និងសុខភាពពលរដ្ឋដោយធ្វើការទប់ស្កាត់ ការកាត់បន្ថយ និងការត្រួតពិនិត្យការបំពុល
- វាយតម្លៃហេតុប៉ះពាល់បរិស្ថាន មុននឹងចេញសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាលចំពោះរាល់គម្រោងដែលបានស្នើឡើង
- ធានាឲ្យមានការអភិរក្ស ការអភិវឌ្ឍ ការគ្រប់គ្រង និងការប្រើប្រាស់ដោយសមហេតុផល និងប្រកបដោយនិរន្តរភាព និងភាពស្ថិតស្ថេរនូវធនធានធម្មជាតិនៃព្រះរាជាណាចក្រកម្ពុជា
- លើកទឹកចិត្ត និងផ្តល់លទ្ធភាពឲ្យសាធារណៈជនចូលរួមក្នុងកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ
- បង្ក្រាបអំពើទាំងឡាយណា ដែលធ្វើឲ្យប៉ះពាល់ដល់បរិស្ថាន។

ទាក់ទងនឹងការគ្រប់គ្រងធនធានធម្មជាតិ ច្បាប់បានតម្រូវឲ្យបណ្តាក្រុមហ៊ុនទាំងអស់ត្រូវរៀបចំរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង ឬរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានពេញលេញ (EIA)។ ផ្អែកលើច្បាប់នេះបានចែងនៅក្នុងមាត្រា៦ និងមាត្រា៧ នៃជំពូកទី៣ ដូចតទៅ ៖

មាត្រា ៦..

ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ត្រូវអនុវត្តន៍លើរាល់គម្រោង និងសកម្មភាពរបស់ឯកជន ឬសាធារណៈហើយត្រូវបានពិនិត្យ និងវាយតម្លៃដោយក្រសួងបរិស្ថានមុនដាក់ជូនរាជរដ្ឋាភិបាលសម្រេច។

ការវាយតម្លៃនេះក៏ត្រូវបានអនុវត្តន៍ផងដែរ ចំពោះសកម្មភាពដែលមានស្រាប់ និងកំពុងដំណើរការហើយដែលពុំទាន់បានវាយតម្លៃហេតុប៉ះពាល់បរិស្ថាននៅឡើយ។

បែបបទនៃកិច្ចដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ត្រូវកំណត់ដោយអនុក្រឹត្យតាមសំណើរបស់ក្រសួងបរិស្ថាន។

ប្រភេទ និងទំហំគម្រោងនិងសកម្មភាពដែលស្នើឡើងព្រមទាំងសកម្មភាពដែលមានស្រាប់ និងកំពុងដំណើរការទាំងឯកជន និងសាធារណៈដែលត្រូវមានការវាយតម្លៃហេតុប៉ះពាល់បរិស្ថាននោះ ត្រូវកំណត់ដោយអនុក្រឹត្យតាមសំណើរបស់ក្រសួងបរិស្ថាន។

មាត្រា ៧..

ចំពោះរាល់ពាក្យស្នើសុំធ្វើគម្រោងវិនិយោគ និងរាល់គម្រោងដែលរដ្ឋស្នើឡើងត្រូវមានការវាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង (IEIA) ឬការវាយតម្លៃហេតុប៉ះពាល់បរិស្ថានដូចមានចែងក្នុងមាត្រា ៦ នៃច្បាប់នេះ។ ក្រសួងបរិស្ថានត្រូវពិនិត្យ និងផ្តល់យោបល់លើការវាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង ឬការវាយតម្លៃហេតុប៉ះពាល់បរិស្ថានទៅអង្គការមានសមត្ថកិច្ច ក្នុងរយៈពេលដូចបានកំណត់ក្នុងច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា។

Draft

មាត្រា ៨..

ធនធានធម្មជាតិនៃព្រះរាជាណាចក្រកម្ពុជា ដែលមានជាអាទិ៍ ដីធ្លី ទឹក អាកាស ខ្យល់ ភូគព្ភសាស្ត្រ ប្រព័ន្ធអេកូឡូស៊ី រ៉ែ ថាមពល ប្រេងកាត និងឧស្ម័ន ថ្ម និងខ្សាច់ ត្បូងថ្ម ព្រៃឈើ និងអនុផលព្រៃឈើ ពពួកសត្វព្រៃ មច្ឆាជាតិ ធនធានជលផល ត្រូវបានអភិរក្ស អភិវឌ្ឍន៍ និងគ្រប់គ្រងប្រើប្រាស់ដោយសមហេតុផល និងប្រកបដោយនិរន្តរភាព និងភាពស្ថិតស្ថេរ។

៣.២.៣ ច្បាប់ស្តីពីកិច្ចការពារបេតិកភណ្ឌវប្បធម៌(១៩៩៦)

ច្បាប់ស្តីពីកិច្ចការពារបេតិកភណ្ឌវប្បធម៌ ដែលរដ្ឋសភាបានអនុម័តនាសម័យប្រជុំលើកទី៥ នីតិកាលទី១ ដែលមានសេចក្តីទាំងស្រុងដូចខាងក្រោម៖

មាត្រា ១..

ច្បាប់នេះមានគោលដៅថែរក្សាការពារបេតិកភណ្ឌវប្បធម៌ជាតិ និងសម្បត្តិវប្បធម៌ទូទៅប្រឆាំងនឹងការបំផ្លិចបំផ្លាញ ការប្រែក្លាយ ការប្តូររូបរាង ការជីកកកាយ ការផ្ទេរកម្មសិទ្ធិ ការនាំចេញ និងការនាំចូលដោយខុសច្បាប់។

មាត្រា ២..

បេតិកភណ្ឌវប្បធម៌ជាតិ គឺជាសម្បត្តិវប្បធម៌ដែលត្រូវបានបង្កើតឡើង ឬក៏បានរកឃើញនៅក្នុងទឹកដីនៃមាតុភូមិ។

មាត្រា ៣..

ច្បាប់នេះអនុវត្តន៍ទៅលើសម្បត្តិវប្បធម៌ជាចលន និងអចលន ទោះជាកម្មសិទ្ធិសាធារណៈក្តី ឬក៏ជាឯកជនក្តីហើយកិច្ចការពារនេះគឺជាផលប្រយោជសាធារណៈ។

លើកលែងតែមានបទបញ្ញត្តិផ្ទុយពីច្បាប់នេះ ច្បាប់នេះអនុវត្តន៍ទៅលើសម្បត្តិវប្បធម៌ដែលជាចំណែកនៃបេតិកភណ្ឌវប្បធម៌ជាតិតែប៉ុណ្ណោះ។

មាត្រា ៦..

រមណីយដ្ឋានដែលត្រូវការពាររួមមាន :

- ឧទ្យានដែលមានបុរាណវត្ថុ ឬរមណីយដ្ឋានដទៃទៀតដែលមានអត្ថប្រយោជន៍សម្រាប់បុរាណវិទ្យា នរវិទ្យា ឬប្រវត្តិវិទ្យាអាចធ្វើការកំណត់ព្រំដែនបាន។
-ព្រំដែននៃបរិវេណរមណីយដ្ឋានដែលត្រូវការពារត្រូវកំណត់ដោយព្រះរាជក្រឹត្យតាមសំណើរបស់ ក.ជ.វ.ជ។

មាត្រា ៧..

ការចុះបញ្ជីសារពើភណ្ឌ គឺជាការកត់ត្រាបញ្ចូលនូវសម្បត្តិវប្បធម៌សាធារណៈ ឬឯកជនដែលមានសារៈសំខាន់ខាងផ្នែកវិទ្យាសាស្ត្រ ប្រវត្តិសាស្ត្រ សិល្បៈ ឬសាសនា ទោះជាសម្បត្តិទាំងនោះមិនតម្រូវឲ្យចាត់ថ្នាក់ជាប្រញាប់ក៏ដោយ។

៣.២.៤ ច្បាប់ស្តីពីការងារ (១៩៩៧)

ច្បាប់ស្តីពីការងារ ដែលរដ្ឋសភាបានអនុម័តកាលពី ថ្ងៃទី១០ ខែមករា ឆ្នាំ១៩៩៧ នាសម័យប្រជុំលើកទី៧ នីតិកាលទី១ និងត្រូវបានប្រកាសឲ្យប្រើប្រាស់ដោយព្រះរាជក្រម លេខជស/រកម/០៣៩៧/០១ ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ១៩៩៧។ ខ្លឹមសារនៃច្បាប់នេះរួមមាន ៖

Draft

មាត្រា ១..

ច្បាប់នេះ គ្រប់គ្រងរាល់ទំនាក់ទំនងដែលកើតចេញពីកិច្ចសន្យាការងាររវាងនិយោជក និងកម្មករ និយោជិក ដើម្បីយកមកអនុវត្តន៍លើទឹកដីនៃព្រះរាជាណាចក្រកម្ពុជា ទោះបីកិច្ចសន្យានោះធ្វើឡើងនៅទីណាក៏ដោយទោះបីភាគីទាំងនោះមានសញ្ជាតិជាអ្វីហើយស្នាក់នៅទីណាក៏ដោយ។

ច្បាប់នេះអនុវត្តន៍ចំពោះ សហគ្រាស ឬគ្រឹះស្ថានឧស្សាហកម្ម រ៉ែ ពាណិជ្ជកម្ម សិប្បកម្ម សេវាកម្មដឹកជញ្ជូនតាមផ្លូវគោក ឬតាមផ្លូវទឹក ទោះជាប្រយោជន៍សាធារណៈ ពាក់កណ្ដាលសាធារណៈ ឬឯកជន ក្រៅសាសនា ឬក្នុងសាសនាក៏ដោយ ទោះមានលក្ខណៈជាការបង្រៀនវិជ្ជាជីវៈ ឬជាការកុសលក៏ដោយព្រមទាំងវិជ្ជាជីវៈសេរីនៃសមាគមន៍ ឬនៃក្រុមប្រភេទណាឬក៏ដោយ។

ច្បាប់នេះក៏ត្រូវអនុវត្តន៍ទៅលើបុគ្គលិកទាំងអស់ ដែលគ្មានគ្រប់គ្រងដោយសហលក្ខន្តិកៈអ្នករាជការ ឬលក្ខន្តិកៈទូត ព្រមទាំងភ្នាក់ងារក្រុមរាជការសាធារណៈដែលតែងតាំងដោយបណ្ដោះអាសន្នដែរ។

ច្បាប់នេះមិនត្រូវអនុវត្តន៍ទៅលើ ៖

ក- ចៅក្រមខាងតុលាការ។

ខ- ជនដែលតែងតាំងឲ្យធ្វើការជាអចិន្ត្រៃយ៍ ក្នុងក្របខណ្ឌរាជការសាធារណៈ។

គ- បុគ្គលិកនគរបាល កងទ័ព និងកងតម្រួត ដែលគ្រប់គ្រងដោយលក្ខន្តិកៈដោយឡែក។

ឃ- បុគ្គលិកធ្វើការតាមផ្លូវអាកាស និងនាវាសមុទ្រ ដែលគ្រប់គ្រងដោយច្បាប់ពិសេសថែមទៀត។ កម្មករ និងនិយោជិក មានសិទ្ធិអនុវត្តន៍បទបញ្ញត្តិស្ដីពីសេរីភាពសហជីពនៃច្បាប់ការងារនេះ។

ង- អ្នកបម្រើក្នុងផ្ទះរៀវលែងតែច្បាប់នេះបានចែងចង្អុលច្បាស់លាស់។ អ្នកបម្រើក្នុងផ្ទះទាំងនេះ មានសិទ្ធិអនុវត្តន៍បទបញ្ញត្តិស្ដីពីសេរីភាពសហជីពនៃច្បាប់ការងារនេះ។

Draft

មាត្រា ១០៤..

ប្រាក់ឈ្នួលយ៉ាងតិចណាស់ក៏ត្រូវឲ្យស្មើនឹងប្រាក់ឈ្នួលអប្បបរិមាដែលត្រូវធានា ពេលគឺរាប់រងកម្មករនិយោជិកគ្រប់រូបឲ្យមានកម្ពស់ជីវភាពសមរម្យទៅតាមសេចក្ដីថ្លៃថ្នូររបស់មនុស្ស។

មាត្រា ១៣៧..

ក្នុងគ្រឹះស្ថានប្រភេទណាក៏ដោយ ទោះបីគ្រឹះស្ថាននោះមានលក្ខណៈជាការសិក្សាវិជ្ជាជីវៈ ឬជាគរុកោសល្យព្រមទាំងនៅក្នុងវិជ្ជាជីវៈសេរីក៏ដោយ ថេរវេលាធ្វើការពេញលេញនៃកម្មករនិយោជិកទាំងពីរភេទ មិនត្រូវឲ្យលើសពីប្រាំបីម៉ោងក្នុងមួយថ្ងៃ ឬសែសិបប្រាំបីម៉ោងក្នុងមួយអាទិត្យឡើយ។

មាត្រា ២៣៩..

ក្រុមពេទ្យការងារត្រូវដឹកនាំដោយគ្រូពេទ្យម្នាក់ ឬច្រើននាក់ដោយមាននាមជាគ្រូពេទ្យការងារដែលមានភារកិច្ចការពារព្យាបាលកុំឲ្យខូចសុខភាពអ្នកធ្វើការ ដែលបណ្ដាលមកពីការងាររបស់គេពិសេសឃ្លាំមើលលក្ខខណ្ឌអនាម័យការងារគ្រោះថ្នាក់នៃជម្ងឺឆ្លង និងស្ថានភាពសុខភាពអ្នកជម្ងឺ។

សំណុំរឿងសុខភាពរបស់កម្មករនិយោជិក ដែលបុគ្គលិកពេទ្យការងារប្រមូលបានគឺជាឯកសារសម្ងាត់ ហើយព័ត៌មានក្នុងសំណុំរឿងនេះ មិនអាចផ្ដល់ឲ្យនិយោជក សហជីព ឬតតិយជនណាមួយ ដើម្បីធ្វើការកត់សម្គាល់លើកម្មករនិយោជិកបានទេ។ ក្នុងគោលបំណងសិក្សាស្រាវជ្រាវអំពីសុខភាពការងារ ឬអំពីសុខភាពសាធារណៈបម្រាមនេះមិនមែនជាឧបសគ្គចំពោះការប្រើប្រាស់ទិន្នន័យដោយមិនបញ្ចេញឈ្មោះសាមីជន។

បទបញ្ញត្តិនៃកថាខណ្ឌខាងលើ មិនជំទាស់ដល់ការផ្ដល់ព័ត៌មានឯកសារទាំងនោះ ដល់អធិការពេទ្យការងារ ឬអធិការការងារដែលអាចពិនិត្យមើលនៅគ្រប់ពេលវេលាតាមការស្នើសុំ។

មាត្រា ២៤៨..

ត្រូវចាត់ទុកជាគ្រោះថ្នាក់ការងារ គ្រោះថ្នាក់ដែលកើតឡើងដោយធ្វើការ ឬក្នុងពេលធ្វើការក៏ដោយ ហេតុយ៉ាងណាក៏ដោយ ហើយទោះមានកំហុសមកពីកម្មករ និយោជិក ឬគ្មានក៏ដោយ គឺគ្រោះថ្នាក់ដែលធ្លាក់លើរូបកាយកម្មករនិយោជិកក្នុងពេលធ្វើការឲ្យនិយោជក ឬនាយកសហគ្រាស ឬធ្លាក់លើសិស្សវិជ្ជាជីវៈ មានឈ្នួលក្តីឥតឈ្នួលក្តីកាន់មុខងារជាអ្វីនៅទីកន្លែងណាក៏ដោយ។

ម្យ៉ាងទៀត ត្រូវចាត់ទុកជាគ្រោះថ្នាក់ការងារដែរ ចំពោះគ្រោះថ្នាក់ណាដែលធ្លាក់លើកម្មករនិយោជិកក្នុងពេលដែលសាមីខ្លួនធ្វើដំណើរពីលំនៅដ្ឋានខ្លួនត្រង់ឆ្ពោះទៅទីកន្លែងធ្វើការ ឬវិលមកវិញដោយគ្មានឈប់ឬដោយគ្មានវាងទៅកន្លែងផ្សេងជាប្រយោជន៍ផ្ទាល់ខ្លួន ឬក្រៅពីការងារដែលគេតម្រូវឲ្យទៅ។

ជម្ងឺបណ្តាលមកពីវិជ្ជាជីវៈទាំងអស់ ដូចមានបញ្ជាក់ក្នុងច្បាប់ត្រូវចាត់ទុកជាគ្រោះថ្នាក់ការងារហើយទទួលការជួសជុលដូចគ្នាដែរ។

មាត្រា ៣៤៤..

អធិការកិច្ចការងារត្រូវមានបេសកកម្មជាអាទិ៍ដូចតទៅ ៖

ក. ធានាដល់ការអនុវត្តន៍ច្បាប់ការងារនេះ និងអត្ថបទអនុវត្តន៍ច្បាប់ដែលបានគ្រោងទុកក៏ដូចជាច្បាប់ និងបទបញ្ញាច្បាប់ដទៃទៀតដែលមិនទាន់បានចងក្រងហើយដែលមានការទាក់ទងដល់របបការងារ។

ខ. ផ្តល់ដំណឹង និងដំបូន្មានបច្ចេកទេសចំពោះនិយោជក និងកម្មករនិយោជិក អំពីមធ្យោបាយដ៏មានប្រសិទ្ធិភាពដើម្បីគោរពបទបញ្ញត្តិច្បាប់។

គ. ផ្តល់ព័ត៌មាន ទៅអាជ្ញាធរមានសមត្ថកិច្ចនូវការមិនគប្បី ឬការរំលោភផ្សេងៗ ដោយហេតុមកពីពុំទាន់មានបទបញ្ញត្តិច្បាប់ជាធរមាន។

ឃ. ជូនយោបល់អំពីបញ្ហាទាក់ទងនឹងការរៀបចំ ឬកែប្រែសហគ្រាស និងអង្គការចាត់តាំងដែលបានអនុញ្ញាតអំពីអាជ្ញាធររដ្ឋបាលហើយដែលមានចង្អុលក្នុងមាត្រា ១ នៃច្បាប់នេះ។

ង. ត្រួតពិនិត្យការអនុវត្តន៍បទបញ្ញត្តិ ដែលទាក់ទងនឹងលក្ខខណ្ឌជីវភាពនៃកម្មករនិយោជិក និងគ្រួសារនៃជនទាំងនេះ។

### ៣.២.៥ ច្បាប់ភូមិបាល (២០០១)

ច្បាប់ភូមិបាល ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០០១ នាសម័យប្រជុំពេញអង្គលើកទី ៦ នីតិកាលទី ២ ហើយដែលព្រឹទ្ធសភាបានអនុម័តយល់ស្របតាមទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី១៣ ខែសីហា ឆ្នាំ២០០១ នាសម័យប្រជុំពេញអង្គលើកទី៥ នីតិកាលទី១ នឹងត្រូវបានប្រកាសឲ្យប្រើប្រាស់ដោយព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១។

ច្បាប់នេះមានគោលដៅកំណត់ អំពីរបបកម្មសិទ្ធិលើអចលនវត្ថុទាំងឡាយ ក្នុងព្រះរាជាណាចក្រកម្ពុជាក្នុងគោលបំណងធានាការការពារសិទ្ធិនៃកម្មសិទ្ធិ និងសិទ្ធិផ្សេងៗទៀតលើអចលនវត្ថុស្របតាមបទបញ្ញត្តិនៃរដ្ឋធម្មនុញ្ញឆ្នាំ ១៩៩៣ នៃព្រះរាជាណាចក្រកម្ពុជា។

មាត្រា ៥..

គ្មានបុគ្គលណាមួយត្រូវបានគេដកហូតកម្មសិទ្ធិរបស់ខ្លួនបានទេ ប្រសិនបើការដកហូតនេះមិនមែនដើម្បីប្រយោជន៍សាធារណៈ។ ការដកហូតត្រូវធ្វើទៅតាមទម្រង់ និងនីតិវិធីបញ្ញត្តិដោយច្បាប់ និងបទបញ្ញាបន្ទាប់ពីបានផ្តល់សំណងជាមុនដោយសមរម្យ និងយុត្តិធម៌។



Draft

មាត្រា ៦..

មានតែភោគៈត្រឹមត្រូវតាមច្បាប់ប៉ុណ្ណោះ ដែលអាចនាំឲ្យបានកម្មសិទ្ធិ។ រដ្ឋក៏អាចផ្តល់កម្មសិទ្ធិនៃទ្រព្យជាអចលនវត្ថុដែលជារបស់រដ្ឋ ក្នុងព្រំដែនជាក់លាក់ដែលបានកំណត់ដោយច្បាប់នេះដល់រូបវន្តបុគ្គល ឬ នីតិបុគ្គលដែលមានសញ្ជាតិជាខ្មែរ។

មាត្រា ៧..

របបកម្មសិទ្ធិលើអចលនវត្ថុឆ្នាំ ១៩៧៩ មិនត្រូវបានទទួលស្គាល់។

មាត្រា ៩..

ក្រុមហ៊ុនដែលបានចុះបញ្ជីនៅកម្ពុជា ហើយដែលមានភាគហ៊ុនចាប់ពី ៥១ % ឡើងទៅកាន់កាប់ដោយរូបវន្តបុគ្គលមានសញ្ជាតិខ្មែរ ឬនីតិបុគ្គលនៃច្បាប់កម្ពុជាអាចជាកម្មសិទ្ធិករនៃទ្រព្យជាដីបាន។ មានតែចំនួនភាគរយនៃប្រាក់ហ៊ុន ដែលមានចែងក្នុងលក្ខន្តិកៈក្រុមហ៊ុនប៉ុណ្ណោះទេដែលទទួលយកជាការបាន។ រាល់ការព្រមព្រៀង ដែលចុះហត្ថលេខាជាលក្ខណៈឯកជនរវាងអ្នកចូលហ៊ុនទាំងឡាយ ដែលមានន័យផ្ទុយពីនេះត្រូវទុកជាមោឃៈ និងគ្មានអនុភាព។

ប្រសិនបើចំនួនភាគរយ ដែលមានចែងក្នុងលក្ខន្តិកៈបានប្រែប្រួលបណ្តាលឲ្យក្រុមហ៊ុនលែងមានសញ្ជាតិជាខ្មែរ ក្រុមហ៊ុនមានកាតព្វកិច្ចធ្វើការផ្លាស់ប្តូរលក្ខន្តិកៈឲ្យបានសមស្របតាមស្ថានភាពជាក់ស្តែងហើយត្រូវផ្តល់ព័ត៌មានទៅស្ថាប័នមានសមត្ថកិច្ចអំពីការប្រែប្រួលនេះ ដោយអនុវត្តន៍ឲ្យបានត្រឹមត្រូវតាមច្បាប់ជាធរមាន។

មាត្រា ១៦..

ទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋមិនអាចលក់ដូរបានឡើយ ហើយកម្មសិទ្ធិនៃទ្រព្យទាំងនោះមិនអាចកំណត់អាជ្ញាយុកាលបានទេ។

ទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ មិនអាចស្ថិតនៅក្រោមការកាន់កាប់ដោយលទ្ធកម្ម ពិសេសនៃជំពូកទី ៤ នៃច្បាប់នេះបានទេ។

ប៉ុន្តែទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ អាចជាកម្មវត្ថុនៃការអនុញ្ញាតឲ្យកាន់កាប់ ឬប្រើប្រាស់ជាបណ្តោះអាសន្នមិនទៀងហើយអាចដកហូតវិញបាន បើមិនបានបំពេញកាតព្វកិច្ចបង់ពន្ធផ្សេងៗ លើកលែងតែបានអនុញ្ញាតតាមជំពូកទី ៣ នៃច្បាប់នេះ។ ការអនុញ្ញាតទាំងនេះ មិនអាចប្រែក្លាយទៅជាកម្មសិទ្ធ ឬជាសិទ្ធកណ្តិកជាប្រយោជន៍ដល់អ្នកកាន់កាប់ទ្រព្យទាំងនេះបានឡើយ។

ទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ នៅពេលបាត់បង់ផលប្រយោជន៍សាធារណៈអាចត្រូវចាត់បញ្ចូលជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋតាមរយៈច្បាប់អនុបយោគ។

មាត្រា ១៨..

ត្រូវទុកជាមោឃៈនិងគ្មានអនុភាពហើយមិនអាចត្រូវបានធ្វើនិយ័តកម្មទោះតាមរូបភាពណាក៏ដោយនូវ៖

- រាល់ការចូលកាន់កាប់ទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ និងរាល់ការបំប្លែងការកាន់កាប់ទ្រព្យសម្បត្តិឯកជនរបស់រដ្ឋទៅជាសិទ្ធិកម្មសិទ្ធិទោះបីការកាន់កាប់ និងការបំប្លែងនេះកើតមាននៅពេលណាក៏ដោយ ដែលមិនស្របតាមលិខិតបទដ្ឋានគតិយុត្ត និងនីតិវិធីដែលបានកំណត់កន្លងមក។
- រាល់ការបំប្លែងទៅជាសិទ្ធិកម្មសិទ្ធិនៃដីសម្បទាន ទោះជាការបំប្លែងនោះកើតឡើងមុនពេលច្បាប់
- នេះចូលជាធរមានក៏ដោយលើលែងតែសម្បទានដែលឆ្លើយតបទៅនឹងប្រយោជន៍សង្គម។

Draft

- រាល់សម្បទានមិនស្របនឹងបញ្ញត្តិទាំងឡាយនៃជំពូកទី ៥
- រាល់ការចូលកាន់កាប់ទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ ទោះជាតាមរូបភាពណាក៏ដោយដែលបានកើតឡើងក្រោយច្បាប់នេះចូលជាធរមាន។

មាត្រា ១៩..

បុគ្គលទាំងឡាយដែលមានប័ណ្ណ ឬមានស្ថានភាពជាក់ស្តែងស្ថិតនៅក្រោមឥទ្ធិពលនៃមាត្រា ១៨ នៃច្បាប់នេះមិនអាចទាមទារសំណងទូទាត់ ឬសាហ៊ុយសម្រាប់ការថែទាំ ឬការរៀបចំដែលបានធ្វើនៅលើអចលនវត្ថុដែលបានកាន់កាប់ដោយខុសច្បាប់បានឡើយ។

លទ្ធកម្មណាមួយដោយខុសច្បាប់ និងដោយចេតនា ឬដោយបោកប្រាស់លើទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ ឬរបស់នីតិបុគ្គលសាធារណៈត្រូវផ្តន្ទាទោសដូចមានចែងក្នុងមាត្រា ២៥៩ នៃច្បាប់នេះ។

ចំពោះការកាន់កាប់ទ្រព្យសម្បត្តិសាធារណៈ ដែលបណ្តាលឲ្យខូចខាត ឬធ្វើឲ្យយឺតយ៉ាវដល់ការងារដែលជាប្រយោជន៍ទូទៅពិសេសចំពោះការកាន់កាប់ដីចំណីផ្លូវកម្រិតទោសនឹងត្រូវកំណត់ជាទ្វេ។

ក្នុងគ្រប់ករណីបើជនល្មើស មិនបញ្ឈប់ការកាន់កាប់របស់ខ្លួនក្នុងរយៈពេល ដែលបានកំណត់ដោយអាជ្ញាធរមានសមត្ថកិច្ចទេអាជ្ញាធរអាចដំណើរការបណ្តេញជនល្មើសចេញ។

### ៣.២.៦ ច្បាប់ស្តីពីការគ្រប់គ្រង និងការធ្វើអាជីវកម្មធនធានរ៉ែ (២០០១)

ប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៧០១/០៩ ចុះថ្ងៃទី ១៣ ខែកក្កដា ឆ្នាំ២០០១។ ច្បាប់នេះមានគោលបំណងកំណត់ការគ្រប់គ្រង និងការធ្វើអាជីវកម្មធនធានរ៉ែនៅក្នុងព្រះរាជាណាចក្រកម្ពុជាដូចមានចែងតាមមាត្រានេះ ៖

មាត្រា ១..

ច្បាប់នេះមានគោលដៅកំណត់ការគ្រប់គ្រង នឹងការធ្វើអាជីវកម្មធនធានរ៉ែ ការប្រើប្រាស់អណ្តូងរ៉ែព្រមទាំងរាល់សកម្មភាពទាំងឡាយ ដែលទាក់ទងទៅនឹងប្រតិបត្តិការធនធានរ៉ែនៅព្រះរាជាណាចក្រកម្ពុជា។ លើកលែងតែប្រតិបត្តិការប្រេងកាត និងឧស្ម័ន ត្រូវស្ថិតនៅក្រោមច្បាប់មួយដោយឡែក។

មាត្រា ២..

ធនធានរ៉ែទាំងអស់ដែលស្ថិតនៅក្នុងដី លើដី ឬក្រោមដីនៃដែនគោក ភ្នំ ខ្ពង់រាប ដែនទឹក ដែន សមុទ្រ កោះ បាតសមុទ្រ ក្រោមបាតសមុទ្រក្នុងបូរណភាពទឹកដីនៃព្រះរាជាណាចក្រកម្ពុជាជាសម្បត្តិរដ្ឋ។

មាត្រា ៥..

គ្មានរូបវន្តបុគ្គល ឬនីតិបុគ្គលណាអាចធ្វើការស្វែងរករុករក ឬធ្វើអាជីវកម្មធនធានរ៉ែ ដោយគ្មានអាជ្ញាប័ណ្ណធនធានរ៉ែ ដែលចេញឲ្យដោយស្ថាប័នមានសមត្ថកិច្ចឡើយ លើកលែងតែម្ចាស់កម្មសិទ្ធិឬអ្នកកាន់កាប់ស្របច្បាប់លើដីធ្លីដែលជាឯកជនអាចប្រើប្រាស់ ក្រួស ខ្សាច់ ថ្ម ដីឥដ្ឋ ដោយមិនចាំបាច់មានអាជ្ញាប័ណ្ណតែមិនអនុញ្ញាតឲ្យដឹកជញ្ជូនចេញផុតពីព្រំដែនដីធ្លីជាកម្មសិទ្ធដើម្បីធ្វើអាជីវកម្មនេះទេ។

ប្រជាពលរដ្ឋខ្មែរអាចធ្វើបុរសេនានៅលើដីរបស់រដ្ឋ ឲ្យតែដីនោះរដ្ឋមិនទាន់ចេញអាជ្ញាប័ណ្ណធនធានរ៉ែទៅបុគ្គលដទៃ។

Draft

មាត្រា ១១..

អាជ្ញាប័ណ្ណធនធានរ៉ែត្រូវបានរៀបចំជាប្រាំមួយប្រភេទ ដើម្បីសម្រួលដល់អ្នកដាក់ពាក្យសុំក្នុងគោលដៅសម្រួលការគ្រប់គ្រងលើការងារស្វែងរុករក និងធ្វើអាជីវកម្មធនធានរ៉ែនៅក្នុងព្រះរាជាណាចក្រកម្ពុជាឲ្យមានប្រសិទ្ធភាព។

ប៉ុន្តែសូមលើកយកតែអាជ្ញាប័ណ្ណពីរតែប៉ុណ្ណោះដែលទាក់ទងនឹងគម្រោងវិនិយោគនេះ :

១. អាជ្ញាប័ណ្ណស្វែងរុករក អាចផ្តល់ឲ្យចំពោះរូបវន្តបុគ្គល ឬនីតិបុគ្គលដែលមានលក្ខណៈសម្បត្តិនឹងសមត្ថភាពគ្រប់គ្រាន់ដើម្បីធ្វើការស្វែងរុករក និងសិក្សាអំពីសក្តានុពលធនធានរ៉ែ។

២. អាជ្ញាប័ណ្ណឧស្សាហកម្មអាជីវកម្មធនធានរ៉ែ ត្រូវបានផ្តល់ឲ្យចំពោះតែសម្បទានិកដែលមានអាជ្ញាប័ណ្ណរុករកប៉ុណ្ណោះក្នុងគោលបំណងស្វែងរុករក និងជីកយករ៉ែណាដែលមានជម្រករ៉ែមានប្រសិទ្ធភាពសេដ្ឋកិច្ច ហើយស្ថិតនៅតែក្នុងរង្វង់ព្រំដែននៃអាជ្ញាប័ណ្ណស្វែងរុករក។

មាត្រា ១២..

ក្នុងករណីដែលរដ្ឋមន្ត្រីទទួលបន្ទុកវិស័យរ៉ែកំណត់ថាពាក្យសុំអាជ្ញាប័ណ្ណស្វែងរុករក ឬអាជីកម្មធនធានរ៉ែជាគម្រោងមានទ្រង់ទ្រាយធំ និងមានផលប្រយោជន៍ពិសេសដល់ប្រទេសជាតិ រដ្ឋមន្ត្រីទទួលបន្ទុកវិស័យរ៉ែត្រូវធ្វើការចរចាជាមួយអ្នកស្នើសុំដើម្បីឈានដល់កិច្ចព្រមព្រៀងវិនិយោគទុនធនធានរ៉ែ ដែលត្រូវបន្ថែមទៅលើអាជ្ញាប័ណ្ណធនធានរ៉ែ។

### ៣.២.៧ ច្បាប់ស្តីពីព្រៃឈើ (២០០២)

ច្បាប់ស្តីពីព្រៃឈើ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០០២ នាសម័យប្រជុំពេញអង្គលើកទី ៨ នីតិកាលទី ២ ហើយដែលព្រឹទ្ធសភាបានអនុម័តយល់ស្របតាមលើទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី១៥ ខែសីហា ឆ្នាំ២០០២ នាសម័យប្រជុំពេញអង្គលើកទី ៧ នីតិកាលទី ១ និងត្រូវបានប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០២។

មាត្រា ១..

ច្បាប់នេះកំណត់ក្របខណ្ឌនៃការគ្រប់គ្រង ការប្រមូលផល ការប្រើប្រាស់ ការអភិវឌ្ឍ និងការអភិរក្សព្រៃឈើនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

គោលបំណងនៃច្បាប់នេះ គឺធានានូវការគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តរភាពដើម្បីផលប្រយោជន៍សង្គមសេដ្ឋកិច្ច និងបរិស្ថានរួមទាំងការអភិរក្សជីវៈចម្រុះ និងមរតកវប្បធម៌។

មាត្រា ២..

ច្បាប់នេះមានវិសាលភាពអនុវត្តន៍លើរាល់ព្រៃឈើទាំងអស់ ទោះជាប្រភេទព្រៃនោះកើតឡើងដោយធម្មជាតិក្តី ឬដោយដាំក្តី។

រដ្ឋធានាសិទ្ធិប្រើប្រាស់ជាប្រពៃណីនូវផល អនុផលព្រៃឈើរបស់សហគមន៍មូលដ្ឋានក្រោមបទបញ្ញត្តិនៃច្បាប់នេះ ឬច្បាប់ពាក់ព័ន្ធផ្សេងទៀត។

មាត្រា ៤..

ក្នុងការអនុវត្តន៍ច្បាប់នេះ រាល់ការសម្រេចរបស់រាជរដ្ឋាភិបាល ដែលមានសក្តានុពលភាពចំពោះផលប៉ះពាល់ធ្ងន់ធ្ងរទៅលើប្រជាពលរដ្ឋទូទៅលើជីវភាពសហគមន៍មូលដ្ឋាន និងលើធនធានព្រៃឈើនៃព្រះរាជាណាចក្រកម្ពុជាត្រូវមានការចូលរួមជាសាធារណៈ។

Draft

សកម្មភាពចម្បងៗ ពាក់ព័ន្ធទៅនឹងប្រព័ន្ធមជ្ឈដ្ឋានព្រៃឈើ ដែលអាចបណ្តាលឲ្យមានផលប៉ះពាល់អាក្រក់ដល់សង្គម និងបរិស្ថាន ចាំបាច់ត្រូវមានការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងផលប៉ះពាល់សង្គម ដោយផ្អែកតាមក្រមបច្ចេកទេសគ្រប់គ្រងព្រៃឈើកម្ពុជា និងស្របតាមច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ។ ឯកសារនៃការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងផលប៉ះពាល់សង្គមត្រូវផ្តល់ជូនសម្រាប់ការចូលរួមផ្តល់មតិជាសាធារណៈបាន។

រាល់ការសម្រេចចុងក្រោយលើរាល់សកម្មភាពចម្បងៗ ពាក់ព័ន្ធទៅនឹងប្រព័ន្ធមជ្ឈដ្ឋានព្រៃឈើរាជរដ្ឋាភិបាលត្រូវពិចារណាលើអនុសាសន៍ចុងក្រោយនៃការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងផលប៉ះពាល់សង្គម។ ការសម្រេចចុងក្រោយណាមួយក្រោមមាត្រានេះ រាជរដ្ឋាភិបាលអាចធ្វើការជូនដំណឹងជាសាធារណៈ។

មាត្រា ១៥..

ព្រៃសម្បទានិកមានសិទ្ធិដំណើរការគ្រប់គ្រង និងប្រមូលផល អនុផលព្រៃឈើនៅក្នុងដែនព្រៃសម្បទានរបស់ខ្លួនដោយធានាថាប្រតិបត្តិការទាំងនេះនឹងមិនប៉ះពាល់ដល់ ៖

១-សិទ្ធិប្រើប្រាស់ជាប្រពៃណី ដែលអនុវត្តន៍នៅលើដីកម្មសិទ្ធិ របស់សហគមន៍ជនជាតិដើមភាគតិចដែលបានចុះបញ្ជីការដោយរដ្ឋស្របតាមច្បាប់ភូមិបាល។

២-សិទ្ធិចេញ-ចូល និងសិទ្ធិប្រើប្រាស់ជាប្រពៃណីអនុវត្តន៍ដោយសហគមន៍ដែលមានទីតាំងក្នុង ឬក្បែរព្រៃសម្បទាន។

Draft

### ៣.២.៨ ច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់វិនិយោគនៃព្រះរាជាណាចក្រកម្ពុជា (២០០៣)

ច្បាប់ស្តីពីវិសោធនកម្ម នៃច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០០៣ នាសម័យប្រជុំពេញអង្គលើកទី ៩ នីតិកាលទី ២ ហើយដែលព្រឹទ្ធសភាបានយល់ស្របតាមលើទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុងដោយគ្មានការកែប្រែអ្វីឡើយកាលពីថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០០៣ នាសម័យប្រជុំពេញអង្គលើកទី ៩ នីតិកាលទី ១។

ប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៣០៣/០០៩ ចុះ ថ្ងៃទី២៤ ខែមីនា ឆ្នាំ២០០៣។

មាត្រា ១ថ្មី..

ច្បាប់នេះមានវិសាលភាពចំពោះ រាល់គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ និងកំណត់នីតិវិធីនៃការបង្កើតគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ដែលធ្វើឡើងដោយបុគ្គលមួយ។មានតែគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ទេ ដែលមានសិទ្ធិទទួលបាននូវផលប្រយោជន៍ដែលស្ថិតក្នុងក្របខណ្ឌនៃច្បាប់នេះ។

មាត្រា ៦ថ្មី..

រាល់បុគ្គលដែលមានបំណងបង្កើតគម្រោងវិនិយោគ ដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ត្រូវដាក់សំណើវិនិយោគនៅក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាតាមទម្រង់ និងតាមនីតិវិធីដែលមានចែងនៅក្នុងច្បាប់នេះ នឹងអនុក្រឹត្យ។

មាត្រា ១៨ថ្មី..

អ្នកវិនិយោគត្រូវបានអនុញ្ញាតឲ្យជួលនិយោគជិកបរទេសតាមលក្ខខណ្ឌដូចតទៅ ៖

- គុណភាព សមត្ថភាព និងជំនាញមិនអាចរកបាននៅព្រះរាជាណាចក្រកម្ពុជា ក្នុងចំណោមប្រជាពលរដ្ឋខ្មែរ។ ក្នុងករណីមានការជួលនិយោគជិតប្រភេទនេះត្រូវផ្ញើជូនមកក្រុមប្រឹក្សាអភិវឌ្ឍ
- កម្ពុជានូវឯកសាររួមមាន សេចក្តីចម្លងលិខិតឆ្លងដែន សញ្ញាប័ត្រ និងប្រវត្តិរូបសង្ខេបរបស់និយោជិកនោះ
- ត្រូវមានលិខិតអះអាងពីតម្រូវការជួលនិយោជិកបរទេស។ អ្នកវិនិយោគ ត្រូវមានការយល់ព្រម និងលិខិតអនុញ្ញាតពីក្រសួងសង្គមកិច្ចការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា
- មុននឹងចូលបម្រើការងារឲ្យអ្នកវិនិយោគ និយោជិកបរទេសត្រូវមានលិខិតអនុញ្ញាត ឲ្យធ្វើការនៅព្រះរាជាណាចក្រកម្ពុជាពីក្រសួងសង្គមកិច្ចការងារបណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទាន

អ្នកវិនិយោគមានកាតព្វកិច្ចដូចតទៅៈ

- ធ្វើការបណ្តុះបណ្តាលសមស្របជូននិយោជិកខ្មែរជាប្រចាំ
- ជំរុញលើកកម្ពស់ដល់និយោជិកខ្មែរ ដើម្បីអាចក្លាយទៅជាអ្នកមានតួនាទីដែលមានកម្រិតខ្ពស់ត្រូវធ្វើជាប្រចាំ។

### ៣.២.៩ ច្បាប់ជលផល (២០០៦)

ច្បាប់ស្តីពីជលផល ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី៣០ ខែមីនា ឆ្នាំ២០០៦ នាសម័យប្រជុំរដ្ឋសភាលើកទី ៤ នីតិកាលទី ៣ និងដែលព្រឹទ្ធសភាពុំមានពេលវេលាគ្រប់គ្រាន់ដើម្បីពិនិត្យ និងផ្តល់យោបល់លើអត្ថបទច្បាប់នេះស្របតាម មាត្រា ១១៣ ថ្មី នៃរដ្ឋធម្មនុញ្ញ និងត្រូវបានប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៥០៦/០១១ ចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ២០០៦។

ច្បាប់នេះ មានគោលបំណងធានានូវការគ្រប់គ្រងជលផល និងធនធានជលផលជំរុញកិច្ចអភិវឌ្ឍវារីវប្បកម្ម ផលិតកម្ម និងការកែច្នៃលើកស្ទួយជីវភាពរស់នៅរបស់ពលរដ្ឋក្នុងសហគមន៍មូលដ្ឋានដើម្បីផលប្រយោជន៍សង្គមសេដ្ឋកិច្ច និងបរិស្ថានរួមទាំងការអភិរក្សជីវៈចម្រុះទាំងមរតកវប្បធម៌ធម្មជាតិផងប្រកបដោយនិរន្តរភាពនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

មាត្រា ៣..

ការគ្រប់គ្រងជលផល ត្រូវស្ថិតនៅក្រោមដែនសមត្ថកិច្ចទូទៅនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

ការគ្រប់គ្រងព្រៃលិចទឹក និងព្រៃកោងកាង ដែលពាក់ព័ន្ធនឹងវដ្តជីវិតនៃធនធានជលផលត្រូវស្ថិតនៅក្រោមវិសាលភាពនៃច្បាប់នេះ។

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទមានសិទ្ធិសហការធ្វើសកម្មភាពពង្រឹងការអនុវត្តន៍ច្បាប់ចំពោះរាល់បទល្មើសជលផល ដែលកើតមាននៅក្នុងតំបន់ការពារធម្មជាតិក្រោមការសម្របសម្រួលជាមួយក្រសួងបរិស្ថានស្របតាមបទបញ្ញត្តិដូចមានចែងក្នុងជំពូកទី ១៤ នៃច្បាប់នេះ។ សកម្មភាពនេះ នឹងមិនធ្វើឲ្យប៉ះពាល់ដល់ដែនសមត្ថកិច្ចគ្រប់គ្រងរបស់ក្រសួងបរិស្ថាន ដូចមានចែងក្នុងច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិឡើយ។

Draft

មាត្រា ៦..

រដ្ឋបាលជលផល គឺជាអាជ្ញាធររដ្ឋាភិបាលដែលចំណុះក្រោមក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មានភារកិច្ចគ្រប់គ្រងជលផល និងធនធានជលផលស្របតាមគោលនយោបាយ វិស័យជលផល និងខ្លឹមសារនៃច្បាប់នេះ។ រដ្ឋបាលជលផលមានរចនាសម្ព័ន្ធគ្រប់គ្រង ចាត់តាំងមួយឯកភាពទូទាំងប្រទេសជាខ្សែរយៈបណ្តោយដែលបែងចែកជាថ្នាក់កណ្តាល អធិការដ្ឋាន ខណ្ឌ ផ្នែក និងសង្កាត់ រដ្ឋបាលជលផល។

ការរៀបចំ និងការប្រព្រឹត្តទៅនៃអង្គភាពរបស់រដ្ឋបាលជលផល ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

មាត្រា ២២..

ហាមឃាត់ការចាក់ចោល ការបោះចោល ការបង្ហូរ ឬការបាចពង្រាយទឹកក្នុងដែននេសាទនូវកាកសំណល់រឹងឬរាវ សារធាតុពុលដែលបានកំណត់ដោយច្បាប់ និងលិខិតបទដ្ឋានគតិយុត្តិនៃព្រះរាជាណាចក្រកម្ពុជា និងអនុសញ្ញាអន្តរជាតិស្តីពីការបំពុលបរិស្ថាន ឬការប្រព្រឹត្តសកម្មភាពដែលធ្វើឲ្យពុល និងការបង្កគ្រោះថ្នាក់ដល់វារីសត្វ និងវារីរុក្ខជាតិ។

មាត្រា ៨៧..

រដ្ឋបាលជលផលមានសិទ្ធិសម្រេច អំពីការពិន័យអន្តរការណ៍លើបទល្មើសជលផល ដូចមានចែងក្នុងមាត្រា ៩២ មាត្រា ៩៣ មាត្រា៩៤ មាត្រា ៩៥ មាត្រា ៩៦ និងមាត្រា ៩៧ នៃច្បាប់នេះ។

ការពិន័យអន្តរការណ៍លើបទល្មើសជលផល អាចធ្វើបានតែក្នុងករណីជនល្មើសសារភាពទោសកំហុស និងយល់ព្រមបង់ប្រាក់ពិន័យស្របតាមទោសបញ្ញត្តិនៃច្បាប់នេះក្នុងរយៈពេលមិនឲ្យលើពីដប់ប្រាំ (១៥) ថ្ងៃ គិតពីថ្ងៃចេញសេចក្តីសម្រេចពិន័យ។

បែបបទទាក់ទងនឹងការផ្តល់សិទ្ធិសម្រេចពិន័យអន្តរការណ៍ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។ ក្នុងការកំណត់បរិមាណទឹកប្រាក់ពិន័យអន្តរការណ៍ត្រូវពិចារណាលើកត្តាដូចតទៅ ៖

១- ផលប្រយោជន៍សេដ្ឋកិច្ចជាក់ស្តែងពីលទ្ធផលនៃបទល្មើស។

២- កម្រិតខូចខាតដល់បរិស្ថាន។

៣- ចំនួននៃការប្រព្រឹត្តបទល្មើស។

៤- បរិមាណប្រាក់ពិន័យដែលធ្វើឲ្យរាងចាល។

៥- ការប្រព្រឹត្តល្មើសដោយចេតនា។

៣.២.១០ ច្បាប់ស្តីពីការគ្រប់គ្រងធនធានទឹកនៅក្នុងព្រះរាជាណាចក្រកម្ពុជា (២០០៧)

ច្បាប់ស្តីពីការគ្រប់គ្រងធនធានទឹកនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី២២ ខែឧសភា ឆ្នាំ២០០៧ នាសម័យប្រជុំរដ្ឋសភាលើកទី ៦ នីតិកាលទី ៣ និងដែលព្រឹទ្ធសភាបានយល់ស្របតាមទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុងដោយគ្មានការកែប្រែអ្វីឡើយកាលពីថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០០៧ នាសម័យប្រជុំពេញអង្គព្រឹទ្ធសភាលើកទី ៣ នីតិកាលទី ២។ ច្បាប់នេះ ត្រូវបានប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៦០៧/០១៦ ចុះ ថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០០៧។

Draft

មាត្រា ៦..

ក្នុងការអនុវត្តន៍ច្បាប់គ្រប់គ្រងធនធានទឹក ក្រសួងធនធានទឹក និងឧតុនិយមត្រូវកំណត់គោលនយោបាយគ្រប់គ្រងអភិរក្ស និងអភិវឌ្ឍន៍ធនធានទឹកស្របតាមតម្រូវការរបស់តំបន់នីមួយៗ នៅទូទាំងព្រះរាជាណាចក្រកម្ពុជាក្នុងទិសដៅធានានិរន្តរភាពធនធានទឹក និងប្រសិទ្ធភាពក្នុងការប្រើប្រាស់ទឹកដើម្បីជៀសវាងមហន្តរាយ និងវិវាទផ្សេងៗ។

មាត្រា ៧..

ការសហការ និងការចូលរួមរបស់ស្ថាប័នពាក់ព័ន្ធផ្នែកឯកជន អ្នកទទួលផលគ្រប់ប្រភេទអង្គការក្រៅរដ្ឋាភិបាល និងអង្គការអន្តរជាតិនឹងត្រូវបានជំរុញដោយរាជរដ្ឋាភិបាលនៅក្នុងសកម្មភាពដែលទាក់ទងទៅនឹងការគ្រប់គ្រង ការវិនិយោគ ការធ្វើអាជីវកម្ម ការអភិរក្ស និងការអភិវឌ្ឍធនធានទឹក។

មាត្រា ២១..

បុគ្គលទាំងឡាយដែលបានជួបប្រទះប្រភពទឹកក្រោមដី ល្អាងទឹកក្រោមដី ក្នុងពេលបំពេញការងាររុករករ៉ែ និងសកម្មភាពផ្សេងៗទៀតត្រូវផ្តល់ព័ត៌មានមកក្រសួងធនធានទឹក និងឧតុនិយម។

មាត្រា ២២..

រាល់ការបញ្ចេញចោល ការទុកចោល ឬការរក្សាទុកនូវសារធាតុពុល ដែលអាចធ្វើឲ្យប៉ះពាល់ដល់គុណភាពទឹក និងអាចបង្កគ្រោះថ្នាក់ដល់មនុស្សសត្វ និងរុក្ខជាតិត្រូវតែសុំអាជ្ញាប័ណ្ណទឹក ឬការអនុញ្ញាត។

ប្រភេទសារធាតុពុលដែលមានចែងខាងលើ និងស្តង់ដារបច្ចេកទេសនៃការបញ្ចេញទឹកសំណល់ នឹងមានកំណត់ដោយអនុក្រឹត្យ។

រាល់កិច្ចដំណើរការក្នុងមាត្រានេះ ក្រសួងធនធានទឹក និងឧតុនិយមត្រូវពិគ្រោះយោបល់ជាមួយក្រសួងពាក់ព័ន្ធនានា។

៣.២.១១ ច្បាប់ស្តីពីជីវសុវត្ថិភាព (២០០៨)

ច្បាប់ ស្តីពីជីវសុវត្ថិភាព ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃ២៨ ខែធ្នូ ឆ្នាំ២០០៧ នាសម័យប្រជុំសភាលើកទី ៧ នីតិកាលទី ៣ និងដែលព្រឹទ្ធសភាបានយល់ស្របតាមទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុងដោយគ្មានការកែប្រែអ្វីឡើយកាលពីថ្ងៃទី១៨ ខែមករា ឆ្នាំ២០០៨ នាសម័យប្រជុំពេញអង្គព្រឹទ្ធសភាលើកទី ៤ នីតិកាលទី ២ និងត្រូវបានប្រកាសឲ្យប្រើប្រាស់ដោយព្រះរាជក្រមលេខ នស/រកម/០២០៨/ ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៨ ។

មាត្រា ១១..

ការនាំចូលសារពាង្គកាយកែច្នៃរស់ ចូលមកក្នុងព្រះរាជាណាចក្រកម្ពុជា ដើម្បីបញ្ចូលទៅក្នុងបរិស្ថានដោយចេតនា ត្រូវបានតម្រូវឲ្យមានការវាយតម្លៃហានិភ័យព្រមទាំងមានការយល់ព្រមពីក្រសួងបរិស្ថានជាមុនមុននឹងស្នើសុំការអនុញ្ញាតនាំចូលពីស្ថាប័នមានសមត្ថកិច្ចដែលពាក់ព័ន្ធ។

ម្ចាស់ស្នើ ត្រូវដាក់ពាក្យទៅក្រសួងបរិស្ថាន អំពីគោលបំណងនៃការនាំចូលរបស់ខ្លួន។

មាត្រា ១៧..

រូបវន្តបុគ្គល ឬនីតិបុគ្គលដែលមានបំណងនាំចេញពីព្រះរាជាណាចក្រកម្ពុជា នូវសារពាង្គកាយកែច្នៃរស់ដែលបានបញ្ញត្តិដោយច្បាប់នេះត្រូវជូនដំណឹងជាលាយលក្ខណអក្សរជាមុនទៅស្ថាប័នជាតិមានសមត្ថកិច្ចនៃប្រ

Draft

ទេសដែលនាំចូលមុននឹងដាក់ពាក្យស្នើសុំលិខិតអនុញ្ញាតនាំចេញ ក្រសួងមានសមត្ថកិច្ចនៃព្រះរាជាណាចក្រកម្ពុជា។

មាត្រា ២១..

ម្ចាស់សំណើ ត្រូវទទួលបន្ទុកក្នុងការវាយតម្លៃហានិភ័យ និងទទួលរ៉ាប់រងលើចំណាយទាំងអស់សម្រាប់ការវាយតម្លៃនេះ។ នៅពេលបានទទួលលទ្ធផលនៃការវាយតម្លៃហានិភ័យ និងឯកសារពាក់ព័ន្ធទាំងឡាយដែលបានតម្រូវដោយច្បាប់នេះ ក្រសួងបរិស្ថាននឹងផ្តល់ការឯកភាពជាគោលការណ៍ដែលមាន ឬគ្មានលក្ខខណ្ឌ ឬតម្រូវឲ្យផ្តល់ព័ត៌មានបន្ថែម ឬបដិសេធមិនផ្តល់ការឯកភាព។

៣.២.១២ ច្បាប់ស្តីពីការគ្រប់គ្រងពូជដំណាំ និងសិទ្ធិអ្នកបង្កាត់ពូជដំណាំ (២០០៨)

មាត្រា ១..

ច្បាប់នេះ មានគោលដៅគ្រប់គ្រង និងត្រួតពិនិត្យលើការបង្កាត់ ការបញ្ចេញឲ្យប្រើការផលិត ការកែច្នៃ ការចុះបញ្ជី ការចែកចាយ ការនាំចូល នាំចេញពូជដំណាំ និងការការពារពូជថ្មីនៃដំណាំ ក្នុងព្រះរាជាណាចក្រកម្ពុជា។

មាត្រា ៤..

ការផ្តល់សិទ្ធិការពារពូជថ្មីនៃដំណាំ ត្រូវស្ថិតនៅក្រោមដែនសមត្ថកិច្ចនៃក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល។

ការគ្រប់គ្រងពូជដំណាំគ្រប់ប្រភេទ ត្រូវស្ថិតនៅក្រោមដែនសមត្ថកិច្ចនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

មាត្រា ៦..

ពូជថ្មីនៃដំណាំដែលទទួលបាននូវសិទ្ធិការពារត្រូវមានលក្ខណៈវិនិច្ឆ័យដូចខាងក្រោម ៖

- ភាពថ្មី
- ភាពខុសប្លែក
- ឯកសណ្ឋានភាព
- ស្ថេរភាព។

មាត្រា ១១..

រូបវន្តបុគ្គល ឬនីតិបុគ្គលដែលបានបង្កាត់ ឬ រកឃើញ និងអភិវឌ្ឍន៍ពូជថ្មីនៃដំណាំហើយមានបំណងការពារកម្មសិទ្ធិបញ្ញាលើពូជថ្មីនោះត្រូវដាក់ពាក្យស្នើសុំនៅក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ដែលត្រូវបញ្ជូនឯកសារនោះទៅក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដើម្បីសិក្សាវាយតម្លៃអំពីលទ្ធផលបច្ចេកទេសដោយអនុលោមតាមបទបញ្ញត្តិច្បាប់នេះ។

វិញ្ញាបនបត្របញ្ជាក់សិទ្ធិការពារពូជថ្មីនៃដំណាំ ត្រូវផ្តល់ដោយក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ក្រោយពីទទួលបានលិខិតបញ្ជាក់លទ្ធផលនៃការសិក្សា វាយតម្លៃលក្ខណៈបច្ចេកទេសពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

មាត្រា ១៣..

អ្នកដាក់ពាក្យស្នើសុំការពារពូជថ្មីត្រូវ ៖

ក- មានសញ្ជាតិជាខ្មែរ ឬ សញ្ជាតិបរទេស ប៉ុន្តែត្រូវមាននិវេសនដ្ឋាននៅក្នុងព្រះរាជាណាចក្រកម្ពុជា ឬ



Draft

ខ- មានទីលំនៅអចិន្ត្រៃយ៍នៅរដ្ឋជាភាគីហត្ថលេខីនៃអនុសញ្ញាសហព័ន្ធអន្តរជាតិការពារពូជថ្មីនៃដំណាំ ឬនៅរដ្ឋណាមួយដែលមានបដិការយោគយល់គ្នាទៅវិញទៅមកជាមួយព្រះរាជាណាចក្រកម្ពុជា។

មាត្រា ៣៥..

រូបវន្តបុគ្គល ឬ នីតិបុគ្គលអាចដាក់ពាក្យស្នើសុំមករដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល និងរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ឲ្យផ្តល់អាជ្ញាប័ណ្ណបញ្ជាក្នុងការប្រើប្រាស់ពូជថ្មីនៃដំណាំដោយផ្អែកលើមូលហេតុនៃភាពចាំបាច់ដើម្បីការពារផលប្រយោជន៍សាធារណៈនៅក្នុងព្រះរាជាណាចក្រកម្ពុជា។ អ្នកទទួលបានអាជ្ញាប័ណ្ណបញ្ជាស្របតាមមាត្រានេះ ត្រូវបង់ប្រាក់សំណងសមស្របទៅឲ្យម្ចាស់សិទ្ធិពូជថ្មីនៃដំណាំ។

### ៣.២.១៣ ច្បាប់ស្តីពីការគ្រប់គ្រងថ្នាំកសិកម្ម និងជីកសិកម្ម (២០១២)

ច្បាប់ស្តីពីការគ្រប់គ្រងថ្នាំកសិកម្ម និងជីកសិកម្ម ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី២១ ខែធ្នូ ឆ្នាំ ២០១១ នាសម័យប្រជុំរដ្ឋសភាលើកទី ៧ នីតិកាលទី ៤ និងដែលព្រឹទ្ធសភាបានយល់ស្របតាមទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុងដោយគ្មានការកែប្រែអ្វីឡើយកាលពីថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០១១ នាសម័យប្រជុំពេញអង្គលើកទី ១០ នីតិកាលទី ២ ហើយច្បាប់នេះត្រូវបានប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០១១២/០០៥ ចុះ ថ្ងៃទី១៤ ខែមករា ឆ្នាំ២០១២។

មាត្រា ១..

ច្បាប់នេះ មានគោលបំណងគាំទ្រគោលនយោបាយ ជំរុញការប្រើប្រាស់សក្តានុពលភាពនៃវិស័យកសិកម្មឲ្យមានប្រសិទ្ធិភាពខ្ពស់ដើម្បីអភិវឌ្ឍន៍សង្គម និងសេដ្ឋកិច្ចជាតិ ៖

- ធានាការគ្រប់គ្រងថ្នាំកសិកម្ម និងជីកសិកម្មប្រកបដោយប្រសិទ្ធិភាព និងសុវត្ថិភាពព្រមទាំងមានសង្គតិភាពជាមួយនឹងបមាណីយអន្តរជាតិ
- លើកកម្ពស់ការយល់ដឹងជាសាធារណៈ លើការអនុវត្តន៍ការតម្រូវបមាណីយសម្រាប់ថ្នាំកសិកម្ម និងជីកសិកម្មនៅក្នុងគ្រប់សកម្មភាពពាក់ព័ន្ធនឹងផលិតផលនេះ
- កាត់បន្ថយហានិភ័យ ដែលបង្កដោយការប្រើប្រាស់ថ្នាំកសិកម្ម និងជីកសិកម្ម ដើម្បីផលប្រយោជន៍របស់កសិករ និងប្រជាពលរដ្ឋទូទាំងប្រទេសដោយធានាបាននូវសន្តិសុខស្បៀងសុវត្ថិភាព ស្បៀងសុខភាពសាធារណៈ និងនិរន្តរភាពនៃបរិស្ថាន។

មាត្រា ៤១..

រូបវន្តបុគ្គល ឬនិតិបុគ្គលដែលប្រើប្រាស់ថ្នាំកសិកម្មត្រូវមានការយល់ដឹងដូចខាងក្រោម ៖

- ត្រូវជ្រើសរើសប្រភេទថ្នាំកសិកម្មសមស្របសម្រាប់ប្រភេទដំណាំ ឬប្រភេទផលិតផល និងប្រភេទសមាសភាពចង្រៃ
- ត្រូវប្រើប្រាស់តែប្រភេទថ្នាំកសិកម្ម ដែលមិនស្ថិតក្នុងចំណាត់ថ្នាក់ហាមឃាត់នៃបញ្ជីថ្នាំកសិកម្ម នៅក្នុងព្រះរាជាណាចក្រកម្ពុជា មានប្រភពដើមផ្គត់ផ្គង់ចែកចាយស្របតាមច្បាប់នេះមានស្លាកសញ្ញាព័ត៌មានជាភាសាខ្មែរ និងមានលេខបញ្ជីកាផ្តល់ដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នៅលើសំបកវេចខ្ចប់
- ត្រូវប្រើប្រាស់ថ្នាំកសិកម្មស្របតាមសេចក្តីណែនាំអំពីការប្រើប្រាស់ និងត្រូវអនុវត្តន៍តាមរយៈពេលបញ្ឈប់ការប្រើប្រាស់មុនពេលប្រមូលផល នៅលើស្លាកសញ្ញាព័ត៌មាននៃសំបកវេចខ្ចប់ដែលក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទបានយល់ព្រមលើការចុះបញ្ជី

- ត្រូវយល់ដឹងពីបច្ចេកទេសប្រើប្រាស់ថ្នាំកសិកម្ម និងត្រូវប្រើប្រាស់ឧបករណ៍សុវត្ថិភាពក្នុងពេលធ្វើប្រព្រឹត្តិកម្មលើសមាសភាពចង្រៃ
- ត្រូវយល់ដឹងពីវិធានសុវត្ថិភាព ក្នុងការប្រើប្រាស់ថ្នាំកសិកម្ម ដើម្បីទប់ស្កាត់ភាពប្រឈមនឹងគ្រោះថ្នាក់ចំពោះខ្លួនឯង អ្នកដទៃ និងបរិស្ថាន។

មាត្រា ៤២..

ក្រុមហ៊ុនថ្នាំកសិកម្ម ឬម្ចាស់កសិដ្ឋាន ត្រូវមានករណីកិច្ចចំពោះកម្មករ និយោជិករបស់ខ្លួនដូចខាងក្រោម ៖

- ផ្តល់ការបណ្តុះបណ្តាលវិធានសុវត្ថិភាពក្នុងការគ្រប់គ្រង និងការប្រើប្រាស់ថ្នាំកសិកម្ម
- ផ្តល់ឧបករណ៍សុវត្ថិភាពដល់បុគ្គលិកប្រតិបត្តិការថ្នាំកសិកម្មផ្ទាល់
- កំណត់បទដ្ឋានសម្រាប់ឧបករណ៍ប្រើប្រាស់ថ្នាំកសិកម្ម និងឧបករណ៍ការពារសុវត្ថិភាព
- អនុវត្តន៍កម្មវិធីត្រួតពិនិត្យ និងថែទាំសុខភាពជាប្រចាំ។

រូបវន្តបុគ្គល ឬនីតិបុគ្គលដែលប្រើប្រាស់ថ្នាំកសិកម្មគ្រប់ប្រភេទក្នុងកសិដ្ឋាន មានករណីយកិច្ចចូលរួមក្នុងគ្រប់សកម្មភាពអប់រំណែនាំស្តីពីវិធានសុវត្ថិភាព ដោយមន្ត្រីមានសមត្ថកិច្ចរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

មាត្រា ៤៣..

ការបោះចោលសំណល់ប្រើប្រាស់ថ្នាំកសិកម្ម និងសំបកវេចខ្ចប់ថ្នាំកសិកម្ម គ្រប់ប្រភេទ ត្រូវអនុវត្តន៍តាមវិធានដូចខាងក្រោម ៖

- មិនត្រូវបោះចោល កប់ ឬដុតបំផ្លាញសំណល់ពីការប្រើប្រាស់ថ្នាំកសិកម្មនៅទីកន្លែងដែលគ្មានការអនុញ្ញាតពីអង្គភាពកសិកម្ម ឬអាជ្ញាធរមានសមត្ថកិច្ច
- មិនត្រូវប្រើប្រាស់ឡើងវិញនូវសំបកវេចខ្ចប់ថ្នាំកសិកម្ម ដើម្បីវេចខ្ចប់ផលិតផលដែលមិនមែនជាថ្នាំកសិកម្មជាពិសេសចំណីអាហារ ឬចំណីសត្វ។

គោលការណ៍ណែនាំស្តីពីវិធានសុវត្ថិភាពក្នុងការប្រើប្រាស់ថ្នាំកសិកម្ម ការបោះចោលសំណល់ពីការប្រើប្រាស់ថ្នាំកសិកម្ម និងសំបកវេចខ្ចប់ថ្នាំកសិកម្ម ត្រូវកំណត់ដោយប្រកាសរួមរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងរដ្ឋមន្ត្រីក្រសួងបរិស្ថាន។

មាត្រា ៤៥..

រូបវន្តបុគ្គល ឬនីតិបុគ្គលដែលប្រើប្រាស់ថ្នាំកសិកម្ម ដែលបង្កឲ្យមានគ្រោះថ្នាក់ដល់សុខភាព មនុស្ស សត្វ ខូចខាតបរិស្ថាន ឬទ្រព្យសម្បត្តិសាធារណៈត្រូវជួសជុលការខូចខាត ឬត្រូវទទួលទណ្ឌកម្មតាមច្បាប់ជាធរមាន។

មាត្រា ៤៩..

ត្រូវហាមឃាត់ចំពោះការប្រើប្រាស់ថ្នាំកសិកម្មគ្រប់ប្រភេទដូចខាងក្រោម ៖

១- ការប្រើប្រាស់ថ្នាំកសិកម្ម ដែលស្ថិតក្នុងចំណាត់ថ្នាក់ហាមឃាត់នៃបញ្ជីថ្នាំកសិកម្មនៅក្នុងព្រះរាជាណាចក្រកម្ពុជាដើម្បីកម្ចាត់សមាសភាពចង្រៃគ្រប់ប្រភេទ។

២- ការប្រើប្រាស់ថ្នាំកសិកម្មលើដំណាំស្បៀងគ្រប់ប្រភេទ ឬលើស្មៅចំណីសត្វ មុនពេលប្រមូលផលមិនស្របតាមរយៈពេលបញ្ឈប់ការប្រើប្រាស់មុនពេលប្រមូលផលដែលកំណត់លើស្លាកសញ្ញាព័ត៌មានថ្នាំកសិ-កម្ម និងត្រូវបានយល់ព្រមក្នុងការចុះបញ្ជី។



Draft

៣- ការប្រើប្រាស់ថ្នាំកសិកម្ម ឬការធ្វើសេវាកម្មដោយប្រើថ្នាំកសិកម្ម ប្រភេទនិយ័តករការ ការលួតលាស់ ឬប្រភេទជំរុញការលូតលាស់របស់រុក្ខជាតិ ឬដំណាំខុសប្រក្រតីលើសពីកម្រិតប្រើប្រាស់ ឬលាយចម្រុះជាមួយនឹងសារជាតុគីមីគ្រោះថ្នាក់ ដែលហាមឃាត់ ឬលាយជាមួយនឹងសារជាតុគីមីផ្សេងទៀត ដោយផ្ទុយនឹងបទដ្ឋានបច្ចេកទេសដែលបង្កគ្រោះថ្នាក់ដល់សុខភាពមនុស្ស សត្វ និងបរិស្ថាន។

## ៣.៣ ព្រះរាជក្រឹត្យ និងអនុក្រឹត្យ

### ៣.៣.១ អនុក្រឹត្យ ស្តីពីការត្រួតពិនិត្យការបំពុលទឹក (១៩៩៩)

អនុក្រឹត្យលេខ ២៧ អនក្រ.បក ស្តីពីការត្រួតពិនិត្យការបំពុលទឹកបានអនុម័តនៅថ្ងៃទី០៦ ខែមេសា ឆ្នាំ ១៩៩៩ ដោយរាជរដ្ឋាភិបាលកម្ពុជា។

មាត្រា ១..

អនុក្រឹត្យនេះ មានគោលដៅកំណត់ការត្រួតពិនិត្យការបំពុលទឹក ដើម្បីទប់ស្កាត់និងកាត់បន្ថយការបំពុលទឹកនៅតាមតំបន់ទឹកសាធារណៈសំដៅធានាបានការពារសុខភាពមនុស្ស និងការអភិរក្សជីវៈចម្រុះ។

មាត្រា ២..

អនុក្រឹត្យនេះ មានវិសាលភាពអនុវត្តន៍ចំពោះរាល់ប្រភពបំពុល និងរាល់សកម្មភាពទាំងឡាយដែលបង្កឲ្យមានការបំពុលទឹកនៅតាមតំបន់ទឹកសាធារណៈ។

មាត្រា ៤..

កម្រិតកំណត់ស្តង់ដារ នៃការបញ្ចេញសំណល់រាវពីប្រភពបំពុលទាំងឡាយ មានចែងនៅក្នុងតារាងឧបសម្ព័ន្ធទី ២ នៃអនុក្រឹត្យនេះ។

មាត្រា ១០..

ការបញ្ចេញចោល ឬការដឹកចេញនូវសំណល់រាវពីប្រភពបំពុលទៅកន្លែងដទៃ ក្នុងគោលបំណងណាមួយ ត្រូវសុំការអនុញ្ញាតពីក្រសួងបរិស្ថានជាមុនសិន និងត្រូវធ្វើសេចក្តីចម្លងនៃពាក្យសុំនោះទៅក្រសួង និងស្ថាប័នពាក់ព័ន្ធ។

ដូច្នេះ រាល់សកម្មភាពរបស់គម្រោងត្រូវអនុវត្តន៍តាមការកំណត់នូវស្តង់ដារការបំពុលទឹកនៃអនុក្រឹត្យនេះដែលមានភ្ជាប់ឧបសម្ព័ន្ធចំនួន ០៥ រួមមាន ៖

- ឧបសម្ព័ន្ធ ១ ៖ ប្រភេទសារជាតុប្រកបដោយគ្រោះថ្នាក់។
- ឧបសម្ព័ន្ធ ២ ៖ កម្រិតស្តង់ដារនៃការបញ្ចេញសំណល់រាវពីប្រភពបំពុលចូលទៅក្នុងតំបន់ទឹកសាធារណៈ ឬទៅក្នុងប្រព័ន្ធបណ្តាញលូ។
- ឧបសម្ព័ន្ធ ៣ ៖ ប្រភេទនៃសារជាតុពុលដែលតម្រូវឲ្យមានការអនុញ្ញាតពីក្រសួងបរិស្ថាន និងបញ្ចេញចោលនូវសំណល់រាវរបស់ខ្លួន ឬដឹកទៅទីដទៃ។
- ឧបសម្ព័ន្ធ ៤ ៖ កម្រិតកំណត់ស្តង់ដារគុណភាពទឹកនៅតាមតំបន់ទីសាធារណៈសម្រាប់អភិរក្សជីវៈចម្រុះក្នុងទឹក។
- ឧបសម្ព័ន្ធ ៥ ៖ កម្រិតកំណត់ស្តង់ដារគុណភាពទឹកនៅតាមតំបន់សាធារណៈសម្រាប់ការពារសុខភាពសាធារណៈ។

Draft

ទាក់ទងនឹងអនុក្រឹត្យនេះ គឺតម្រូវឲ្យម្ចាស់គម្រោងត្រូវមានការត្រួតពិនិត្យការបំពុលទឹកពីតំបន់ខ្លួនឯង ដើម្បីទប់ស្កាត់ និងកាត់បន្ថយការបំពុលទឹកទៅតំបន់ទីទៃក្នុងគោលដៅថែរក្សាការពារសុខមាលភាពមនុស្ស និង ការអភិរក្សជីវៈចម្រុះ។

តារាង ៣.១ ៖ ឧបសម្ព័ន្ធ ២ កម្រិតកណត់ស្តង់ដារនៃការបញ្ចេញសំណល់រាវ ពីប្រភពបំពុលចូលទៅក្នុង តំបន់ទឹកសាធារណៈ ឬក្នុងប្រព័ន្ធបណ្តាញលូ

| ល.រ | ប៉ារ៉ាម៉ែត្រ | ខ្នាត | បរិមាណសារធាតុបំពុល ដែលអាចអនុញ្ញាតឲ្យបញ្ចេញ | |
|---|---|---|---|---|
| | | | តំបន់ទឹកសាធារណៈដែលត្រូវបានការពារ | តំបន់ទឹកសាធារណៈ និងលូ |
| ១ | សីតុណ្ហភាព | °C | <45 | <45 |
| ២ | pH | | 6-9 | 5-9 |
| ៣ | BOD | mg/l | <30 | <80 |
| ៤ | COD | mg/l | <50 | <100 |
| ៥ | សារធាតុរឹងអណ្តែតក្នុងទឹក | mg/l | <60 | <120 |
| ៦ | សារធាតុរឹងដែលរលាយក្នុងទឹក | mg/l | <1000 | <2000 |
| ៧ | ប្រេង ឬខ្លាញ់ | mg/l | <5.0 | <15 |
| ៨ | សាប៊ូ | mg/l | <5.0 | <15 |
| ៩ | ផេណុល | mg/l | <0.1 | <1.2 |
| ១០ | នីត្រាត | mg/l | <10 | <20 |
| ១១ | ក្លរ៉ក្នុងទម្រង់សេរី | mg/l | <1.0 | <2.0 |
| ១២ | ក្លរ៉ជាអ៊ីយ៉ុង | mg/l | <500 | <700 |
| ១៣ | ស៊ុលផាត | mg/l | <300 | <500 |
| ១៤ | ស៊ុលហ្វីត | mg/l | <0.2 | <1.0 |
| ១៥ | ផូស្វាត | mg/l | <3.0 | <6.0 |
| ១៦ | ស៊ីអានីត ($CN^{-1}$) | mg/l | <0.2 | <1.5 |
| ១៧ | បារ្យ៉ូម (Ba) | mg/l | <4.0 | <7.0 |
| ១៨ | អាសេនិច (As) | mg/l | <0.10 | <1.0 |
| ១៩ | សំណប៉ាហាំង (Sn) | mg/l | <2.0 | <8.0 |
| ២០ | ដែក (Fe) | mg/l | <1.0 | <20 |
| ២១ | បរ (B) | mg/l | <1.0 | <5.0 |
| ២២ | ម៉ង់កាណែស (Mn) | mg/l | <1.0 | <5.0 |
| ២៣ | កាត់ម្ញូម (Cd) | mg/l | <0.1 | <0.5 |
| ២៤ | ក្រូម $(Cr)^{+3}$ | mg/l | <0.2 | <1.0 |
| ២៥ | ក្រូម $(Cr)^{+6}$ | mg/l | <0.05 | <0.5 |
| ២៦ | ទង់ដែង (Cu) | mg/l | <0.2 | <1.0 |
| ២៧ | សំណ (Pb) | mg/l | <0.1 | <1.0 |
| ២៨ | បារត (Hg) | mg/l | <0.002 | <0.05 |

Draft

| ល.រ | ប៉ារ៉ាម៉ែត្រ | ខ្នាត | បរិមាណសារធាតុបំពុល ដែលអាចអនុញ្ញាតឲ្យបញ្ចេញ | |
|---|---|---|---|---|
| | | | តំបន់ទឹកសាធារណៈដែលត្រូវបានការពារ | តំបន់ទឹកសាធារណៈ និងលូ |
| ២៩ | នីកែល (Ni) | mg/l | <0.2 | <1.0 |
| ៣០ | សេលេញ៉ូម (Se) | mg/l | <0.05 | <0.5 |
| ៣១ | ប្រាក់ (Ag) | mg/l | <0.1 | <0.5 |
| ៣២ | ស័ង្កសី (Zn) | mg/l | <1.0 | <3.0 |
| ៣៣ | ម៉ូលីបដែន (Mo) | mg/l | <0.1 | <1.0 |
| ៣៤ | អាម៉ូញាក់ ($NH_3$) | mg/l | <5.0 | <7.0 |
| ៣៥ | អុកស៊ីសែនដែលរលាយក្នុងទឹក | mg/l | >2.0 | >1.0 |
| ៣៦ | ប៉ូលីក្លរ៉ូ ប៊ីផេនីល (PCB) | mg/l | <0,003 | <0,003 |
| ៣៧ | កាល់ស្យូម (Ca) | mg/l | <150 | <200 |
| ៣៨ | ម៉ាញ៉េស្យូម (Mg) | mg/l | <150 | <200 |
| ៣៩ | កាបូនតេត្រាក្លរួ | mg/l | <3 | <3 |
| ៤០ | អ៊ិចសាក្លរូបង់សែន | mg/l | <2 | <2 |
| ៤១ | ដេដេតេ | mg/l | <1,3 | <1,3 |
| ៤២ | អង់ឌ្រីន | mg/l | <0,01 | <0,01 |
| ៤៣ | ឌីអលឌ្រីន | mg/l | <0,01 | <0,01 |
| ៤៤ | អេនឌ្រីន | mg/l | <0,01 | <0,01 |
| ៤៥ | អ៊ីសូឌ្រីន | mg/l | <0,01 | <0,01 |
| ៤៦ | ពែក្លរូអេទីឡែន | mg/l | <2,5 | <2,5 |
| ៤៧ | អ៊ិចសាក្លរូប៊ុយតាឌីអែន | mg/l | <3 | <3 |
| ៤៨ | ក្លរ៉ូហ្វម | mg/l | <1 | <1 |
| ៤៩ | 1,2 ឌីក្លរូអេទីឡែន | mg/l | <2,5 | <2,5 |
| ៥០ | ទ្រីក្លរូអេទីឡែន | mg/l | <1 | <1 |
| ៥១ | ទ្រីក្លរូបង់សែន | mg/l | <2 | <2 |
| ៥២ | អ៊ិចសាក្លរូស៊ីក្លូអ៊ិចសែន | mg/l | <2 | <2 |

*កំណត់សម្គាល់ ៖ ក្រសួងបរិស្ថាន និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវសហការរៀបចំកម្រិតកំណត់ស្តង់ដារថ្នាំពុលកសិកម្មដែលបញ្ចេញពីប្រភពបំពុល។*

Draft

**តារាង ៣.២ ៖ ឧបសម្ព័ន្ធ ៤ កម្រិតកំណត់ស្តង់ដារគុណភាពទឹកនៅតាមតំបន់ទឹសាធារណៈ សម្រាប់អភិរក្ស ជីវៈចម្រុះក្នុងទឹក**

១. សម្រាប់ទឹកទន្លេ

| ល.រ | ប៉ារ៉ាម៉ែត្រ | ខ្នាត | កម្រិតស្តង់ដារ |
|---|---|---|---|
| ១ | pH | | 6,5-8,5 |
| ២ | $BOD_5$ | Mg/l | 1-10 |
| ៣ | សារធាតុរឹងអណ្តែតក្នុងទឹក (SS) | Mg/l | 25-100 |

| | | | |
|---|---|---|---|
| ៤ | កម្រិតរលាយអុកស៊ីសែន (DO) | Mg/l | 7,5-2,0 |
| ៥ | កូលីហ្វម (Coliform) | MPN/100ml | <5000 |

## ២. សម្រាប់បឹង និងអាងស្តុកទឹក

| ល.រ | ប៉ារ៉ាម៉ែត្រ | ខ្នាត | កម្រិតស្តង់ដារ |
|---|---|---|---|
| ១ | pH | | 6,5-8,5 |
| ២ | COD | Mg/l | 1-8 |
| ៣ | សារធាតុរឹងអណ្តែតក្នុងទឹក (SS) | Mg/l | 1-15 |
| ៤ | កម្រិតរលាយអុកស៊ីសែន (DO) | Mg/l | 7,5-2,0 |
| ៥ | កូលីហ្វម (Coliform) | MPN/100ml | <1000 |
| ៦ | អាសូតសរុប (Total Nitrogen) | Mg/l | 0,1-0,6 |
| ៧ | ផូស្វ័រសរុប (Total Phosphorus) | Mg/l | 0,005-0,5 |

តារាង ៣.៣ ៖ ឧបសម្ព័ន្ធ ៥ កម្រិតកំណត់ស្តង់ដារគុណភាពទឹកនៅតាមតំបន់សាធារណៈសម្រាប់ការពារ សុខភាពសាធារណៈ

| ល.រ | ប៉ារ៉ាម៉ែត្រ | ខ្នាត | កម្រិតស្តង់ដារ |
|---|---|---|---|
| ១ | កាបូនតេត្រាក្លរួ | µg/l | <12 |
| ២ | អ៊ិចសាក្លរូបង់សែន | µg/l | <0,03 |
| ៣ | ដេដេតេ | µg/l | <10 |
| ៤ | អង់ឌ្រីន | µg/l | <0,01 |
| ៥ | ឌីអលឌ្រីន | µg/l | <0,01 |
| ៦ | អេនឌ្រីន | µg/l | <0,005 |
| ៧ | អ៊ីសូឌ្រីន | µg/l | <0,005 |
| ៨ | ពែក្លរូអេទីឡែន | µg/l | <10 |
| ៩ | អ៊ិចសាក្លរូប៊ុយតាឌីអែន | µg/l | <0,1 |
| ១០ | ក្លរូហ្វម | µg/l | <12 |
| ១១ | ១,២ ឌីក្លរូអេទីឡែន | µg/l | <10 |
| ១២ | ទ្រីក្លរូអេទីឡែន | µg/l | <10 |
| ១៣ | ទ្រីក្លរូបង់សែន | µg/l | <0,4 |
| ១៤ | អ៊ិចសាក្លរូស៊ីក្លូអ៊ិចសែន | µg/l | <0,05 |
| ១៥ | បង់សែន | µg/l | <10 |
| ១៦ | តេត្រាក្លរូអេទីឡែន | µg/l | <10 |
| ១៧ | កាត់ម្មូម | µg/l | <1 |
| ១៨ | បារតសរុប | µg/l | <0,5 |
| ១៩ | បារតសរីរាង្គ | µg/l | 0 |
| ២០ | សំណ | µg/l | <10 |

Draft

| ល.រ | ប៉ារ៉ាម៉ែត្រ | ខ្នាត | កម្រិតស្តង់ដារ |
|---|---|---|---|
| ២១ | ក្រូមវ៉ាឡង់៦ | μg/l | <50 |
| ២២ | អាសេនីច | μg/l | <10 |
| ២៣ | សេលេញ៉ូម | μg/l | <10 |
| ២៤ | ប៉ូលីក្លរូប៊ីផេនីល (PCB) | μg/l | 0 |
| ២៥ | ស៊ីអានីត (CN) | μg/l | <0,005 |

មាត្រា ១២..

ការសុំអនុញ្ញាតលើការបញ្ចេញចោល ឬការដឹកសំណល់រាវចេញពីប្រភពបំពុលទៅកន្លែងដទៃ ដូចមានចែងក្នុងមាត្រា ១០ នៃអនុក្រឹត្យនេះ នឹងត្រូវអនុវត្តន៍ទៅលើប្រភពបំពុលទាំងគម្រោងថ្មី និងទាំងគម្រោងកំពុងដំណើរការលើកលែងតែគម្រោងប្រភពបំពុលថ្មី ដែលរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានរបស់គម្រោងនោះត្រូវបានអនុម័ត និងត្រូវបានរួចផុតពីការតម្រូវឲ្យសុំការអនុញ្ញាតលើការបញ្ចេញចោល ឬដឹកសំណល់រាវរបស់ខ្លួនទៅកន្លែងដទៃ។

៣.៣.២ អនុក្រឹត្យស្តីពីការគ្រប់គ្រងសំណល់រឹង (១៩៩៩)

អនុក្រឹត្យលេខ ៣៦ អនក្រ.បក ស្តីពីការគ្រប់គ្រងសំណល់រឹង បានអនុម័តនៅថ្ងៃទី២៧ ខែមេសា ឆ្នាំ ១៩៩៩ ដោយរាជរដ្ឋាភិបាលកម្ពុជា។

មាត្រា ១..

អនុក្រឹត្យនេះមានគោលដៅកំណត់ការគ្រប់គ្រងសំណល់រឹង ប្រកបដោយលក្ខណៈបច្ចេកទេសសមស្រប និងប្រកបដោយសុវត្ថិភាពសំដៅធានាបាននូវការការពារសុខភាពសាធារណៈ គុណភាពបរិស្ថាន និងការអភិរក្សជីវៈចម្រុះ។

មាត្រា ២..

អនុក្រឹត្យនេះមានវិសាលភាពអនុវត្តន៍ ចំពោះរាល់សកម្មភាពបោះចោល ទុកដាក់ ស្តុក ប្រមូល ដឹកជញ្ជូន កែច្នៃ និងបញ្ចេញចោលសំរាម និងសំណល់ប្រកបដោយគ្រោះថ្នាក់។

មាត្រា ១៤..

ម្ចាស់សំណល់ត្រូវធ្វើ និងធ្វើរៀងរាល់បីខែម្តងទៅក្រសួងបរិស្ថាននូវរបាយការណ៍ដែលទាក់ទងនឹងសំណល់ប្រកបដោយគ្រោះថ្នាក់នៅក្នុងមូលដ្ឋានរបស់ខ្លួនរួមមាន ៖

ក- ប្រភេទ និងបរិមាណសំណល់

ខ- វិធីសាស្ត្រក្នុងការទុកដាក់ ឬស្តុកទុកជាបណ្តោះអាសន្ន

គ- វិធីសាស្ត្រក្នុងការសម្អាតសំណល់ ឬបំបាត់សំណល់។

<u>តារាងឧបសម្ព័ន្ធ</u>

ប្រភេទសំណល់រឹងគ្រោះថ្នាក់

១. សំណល់កក ដែលបង្កើតឡើងដោយរោងចក្រប្រព្រឹត្តកម្មសម្អាតសំណល់រាវ និងទឹកលូ

២. សំណល់ដែលសល់ពីការឆេះមិនអស់នៅក្នុងឧស្សាហកម្ម

៣. សំណល់ប្លាស្ទិក ប៉ូលីវីនីលក្លរួ

៤. សំណល់សារធាតុជ័រប៉ូលីក្លរីណេតទីតបីផេនីល (PCB) នៃម៉ាស៊ីនត្រជាក់ ទូរទស្សន៍ វិទ្យុ ម៉ាញ៉េ ។ល។

Draft

៥. សំណល់ជ័រ និងកៅស៊ូដែលមានសារធាតុប៉ូលីម៉ែប៉ុយទីលីន

៦. សំណល់ប្រេងឥន្ធនៈ និងប្រេងម៉ាស៊ីន

៧. សំណល់ដែលមានផ្ទុកជាតិអាស៊ីត

៨. សំណល់ដែលមានផ្ទុកជាតិបាស

៩. សំណល់លោហៈ និងសមាសធាតុរបស់វារួមមាន ៖

| | | | |
|---|---|---|---|
| សង្កសី (Zn) | សេលីនីយ៉ូម (Se) | សំណប៉ាហាំង (Sn) | វ៉ាណាដ្យូម (V) |
| ទង់ដែង (Cu) | អាសេនិច (As) | បារីយ៉ូម (Ba) | កូបាល់ (Co) |
| នីកែល (Ni) | អង់ទីម៉ូនី (Sb) | បេរីលីយ៉ូម (Be) | តាល់យ៉ូម (Tl) |
| ក្រូម (Cr) | ម៉ូលីបដែន (Mo) | បរ (B) | តេលុយរីយ៉ូម (Te) |
| សំណ (Pb) | ទីតានីយ៉ូម (Ti) | អ៊ុយរ៉ាញ៉ូម (U) | ប្រាក់ (Ag) |
| បារ៉ត (Hg) | កាត់ម្យូម (Cd) | ដែក (Fe) | |

១០. លម្អងផ្សែង និងធូលីដែលកើតមានក្នុងករណីសម្អាតផ្សែងបញ្ចេញពីមូលដ្ឋានផលិតកម្ម

១១. សំណល់អំពូលអគ្គិសនី និងបន្ទះប្រព័ន្ធគ្រឿងអេឡិចត្រូនិចអគ្គិសនី

១២. សំណល់អាគុយ និងថ្មពិល

១៣. សំណល់ដែលនាំឲ្យមានការចម្លងមេរោគ ឬជម្ងឺ

១៤. សំណល់ផេះនៃឡដុតសម្អាត សំណល់រឹង និងសំណល់ប្រកបដោយគ្រោះថ្នាក់

១៥. ផលិតផលដែលមិនឆ្លើយតបទៅនឹងបទដ្ឋាននានា និងហួសកំណត់

១៦. សំណល់ដែលបានពីក្រោយពេលធ្វើប្រព្រឹត្តកម្មសម្អាតដីកខ្វក់ ឬដីខូចគុណភាព

១៧. សារធាតុ ដែលជាផលិតផលបានមកពីការធ្វើប្រព្រឹត្តកម្មសម្អាតសំណល់ដែលមានចែងពីចំនុចទី ១ ដល់ទី ៣២

Draft

### ៣.៣.៣ អនុក្រឹត្យស្តីពីកិច្ចដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន (១៩៩៩)

អនុក្រឹត្យលេខ ៧២ អនក្រ.បក ស្តីពីកិច្ចដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន បានអនុម័តនៅថ្ងៃទី១១ ខែសីហា ឆ្នាំ១៩៩៩ ដោយរាជរដ្ឋាភិបាលកម្ពុជា។

មាត្រា ១..

- កំណត់ការវាយតម្លៃហេតុប៉ះពាល់បរិស្ថានលើរាល់គម្រោង និងសកម្មភាពរបស់ឯកជន ឬសាធារណៈហើយត្រូវបានពិនិត្យ និងវាយតម្លៃដោយក្រសួងបរិស្ថានមុនដាក់ជូនរាជរដ្ឋាភិបាលសម្រេច។
- កំណត់ប្រភេទ និងទំហំគម្រោងសកម្មភាព ដែលស្នើឡើងព្រមទាំងសកម្មភាពដែលមានស្រាប់ និងកំពុងដំណើរការទាំងឯកជន និងសាធារណៈដែលត្រូវវាយតម្លៃហេតុប៉ះពាល់បរិស្ថាន។
- បំផុសឲ្យមានការចូលរួមពីសាធារណៈជន ក្នុងកិច្ចដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថានព្រមទាំងទទួលយកមតិយោបល់មកធ្វើការពិចារណាក្នុងកិច្ចដំណើរអនុម័តគម្រោង។

មាត្រា ៣..

ក្រសួងបរិស្ថានមានភារកិច្ច ៖

ក-ពិនិត្យ និងវាយតម្លៃលើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន ដោយសហការណ៍ជាមួយក្រសួងស្ថាប័នពាក់ព័ន្ធ។

ខ-តាមដាន ឃ្លាំមើល និងចាត់វិធានការ ឲ្យម្ចាស់គម្រោងប្រតិបត្តិតាមផែនការគ្រប់គ្រងបរិស្ថានក្នុងដំណាក់កាលសាងសង់ ប្រតិបត្តិ និងបញ្ចប់គម្រោងដូចមានចែងក្នុងរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន ដែលបានអនុម័តរួច។

មាត្រា ៤..

ស្ថាប័ន និងក្រសួងដែលមានសិទ្ធិអនុម័តលើគម្រោង មានភារកិច្ចពិនិត្យ និងសម្រេចលើគម្រោងដូចមានចែងក្នុងឧបសម្ព័ន្ធនៃអនុក្រឹត្យនេះដែលក្រសួងបរិស្ថានបានពិនិត្យ និងផ្តល់យោបល់លើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន។

មាត្រា ៨..

ម្ចាស់គម្រោង ត្រូវដាក់ពាក្យសុំពិនិត្យរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានពេញលេញ និងរបាយការណ៍សិក្សាលទ្ធភាពទៅក្រសួងបរិស្ថាន ចំពោះគម្រោងដែលអាចបង្កហេតុប៉ះពាល់បរិស្ថានធ្ងន់ធ្ងរដល់ធនធានធម្មជាតិ អេកូស៊ីស្តែម សុខភាព និងសុខមាលភាពសាធារណៈ។

មាត្រា ១០..

គោលការណ៍ណែនាំ ស្តីពីការធ្វើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង និងរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានពេញលេញត្រូវកំណត់ដោយប្រកាសរបស់ក្រសួងបរិស្ថាន។

មាត្រា ១៥..

ក្រសួងបរិស្ថានត្រូវពិនិត្យរបាយការណ៍ ដូចមានចែងក្នុងមាត្រា ១៤ ព្រមទាំងចាត់បញ្ជូនយោបល់ និងសំណើទៅម្ចាស់គម្រោង និងស្ថាប័នអនុម័តគម្រោងក្នុងរយៈពេល ៣០ ថ្ងៃ គិតថ្ងៃធ្វើការចាប់ពីថ្ងៃដែលក្រសួងបានទទួលរបាយការណ៍សិក្សាបុរេលទ្ធភាព និងរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូងពីម្ចាស់គម្រោង។

មាត្រា ១៦..

ក្នុងករណីដែលក្រសួងបរិស្ថាន តម្រូវឲ្យមានរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានពេញលេញ ម្ចាស់គម្រោងត្រូវរៀបចំ និងបញ្ជូនរបាយការណ៍ដូចមានចែងក្នុងមាត្រា ៨ ទៅក្រសួងបរិស្ថានជាមួយនឹងការដាក់ពាក្យសុំវិនិយោគទៅស្ថាប័នអនុម័តគម្រោង។

មាត្រា ១៧..

ក្រសួងបរិស្ថាន ត្រូវពិនិត្យរបាយការណ៍ដូចមានចែងក្នុងមាត្រា ១៦ ព្រមទាំងចាត់បញ្ជូនយោបល់ និងសំណើរទៅម្ចាស់គម្រោង និងស្ថាប័នអនុម័តគម្រោងក្នុងរយៈពេល ៣០ ថ្ងៃ គិតថ្ងៃធ្វើការចាប់ពីថ្ងៃដែលក្រសួងបានទទួលរបាយការណ៍សិក្សាលទ្ធភាព និងរបាយការណ៍វាយតម្លៃហេតុប៉ះពាល់ពេញលេញពីម្ចាស់គម្រោង។

មាត្រា ១៨..

ក្នុងករណីក្រសួងបរិស្ថានខកខានមិនបានបញ្ជូនយោបល់ និងសំណើដូចមានចែងក្នុងមាត្រា ១៥ និងមាត្រា ១៧ នោះ ស្ថាប័នអនុម័តគម្រោងអាចកំណត់បានថាគម្រោងនោះត្រូវបានបំពេញតាមតម្រូវការនៃអនុក្រឹត្យនេះ។

មាត្រា ២០..

មុនចាប់ដំណើរការអនុវត្តន៍គម្រោង ម្ចាស់គម្រោងត្រូវទទួលយោបល់ឯកភាព ពីក្រសួងបរិស្ថានលើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង ឬរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានពេញលេញ។

មាត្រា ២៧..

ម្ចាស់កម្មសិទ្ធ ឬម្ចាស់ទទួលខុសត្រូវ ត្រូវអនុវត្តន៍ផែនការគ្រប់គ្រងបរិស្ថានដែលមានចែងក្នុងរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានក្នុងរយៈពេល ៦ ខែ គិតចាប់តាំងពីថ្ងៃដែលក្រសួងបរិស្ថានបានចេញសេចក្តីជូនដំណឹងថារបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានបានបំពេញតាមតម្រូវការនៃអនុក្រឹត្យនេះ។

មាត្រា ២៨..

ក្រសួងបរិស្ថាន ត្រូវសហការជាមួយស្ថាប័នពាក់ព័ន្ធចេញបញ្ជាឲ្យផ្អាកសកម្មភាព ចំពោះម្ចាស់គម្រោង ឬម្ចាស់កម្មសិទ្ធណាដែលពុំបានអនុវត្តន៍តាមផែនការគ្រប់គ្រងបរិស្ថាននៃគម្រោងដូចបានចែងក្នុងរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដែលបានឯកភាពរួចហើយ។

### ៣.៣.៤ អនុក្រឹត្យស្តីពីការត្រួតពិនិត្យការបំពុលខ្យល់ និងការរំខានដោយសំឡេង (២០០០)

អនុក្រឹត្យលេខ ៤២ អនក្រ.បក ស្តីពីការត្រួតពិនិត្យការបំពុលខ្យល់ និងការរំខានដោយសំឡេងត្រូវបានអនុម័តនៅថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០០០ ដោយរាជរដ្ឋាភិបាលកម្ពុជា។ អនុក្រឹត្យនេះ រៀបចំឡើងដើម្បីអនុវត្តន៍ និងបំពេញបន្ថែមនូវបញ្ញត្តិនានាដែលមានចែងក្នុងច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ (១៩៩៦) ជាពិសេសពាក់ព័ន្ធនឹងការងារត្រួតពិនិត្យសកម្មភាព និងប្រភពដែលនាំឲ្យមានការបំពុលខ្យល់ និងការរំខានដោយសំឡេង ។

មាត្រា ១..

អនុក្រឹត្យនេះ កំណត់ការត្រួតពិនិត្យ ការបំពុលខ្យល់ និងការរំខានដោយសំឡេងដើម្បីទប់ស្កាត់ និងកាត់បន្ថយសារធាតុដែលបំពុលខ្យល់ និងសំឡេងក្នុងបរិយាកាសសំដៅការពារគុណភាពបរិស្ថាន និងសុខភាពសាធារណៈ។

មាត្រា ២..

អនុក្រឹត្យនេះ មានវិសាលភាពអនុវត្តន៍ និងចាត់វិធានការចំពោះរាល់ប្រភពបំពុលចល័ត និងអចល័តទាំងឡាយដែលបង្កឲ្យមានការបំពុលខ្យល់ និងការរំខានដោយសំឡេងនៅក្នុងបរិយាកាស។ កម្រិតកំណត់ស្តង់ដាគុណភាពខ្យល់ និងសំឡេងរំខានមានចែងនៅក្នុងឧបសម្ព័ន្ធចំនួន ០៨ នៃអនុក្រឹត្យនេះរួមមាន ៖

- ឧបសម្ព័ន្ធ ១ ៖ កម្រិតកំណត់ស្តង់ដាគុណភាពខ្យល់។
- ឧបសម្ព័ន្ធ ២ ៖ កម្រិតកំណត់ស្តង់ដារអតិបរមានៃសារធាតុប្រកបដោយគ្រោះថ្នាក់ដែលអនុញ្ញាតឲ្យមាននៅក្នុងខ្យល់។
- ឧបសម្ព័ន្ធ ៣ ៖ កម្រិតកំណត់ស្តង់ដារអតិបរមានៃសារធាតុបំពុលដែលអនុញ្ញាតបញ្ចេញពីប្រភពអចល័តចូលទៅក្នុងបរិយាកាស។
- ឧបសម្ព័ន្ធ ៤ ៖ កម្រិតកំណត់ស្តង់ដារនៃការបញ្ចេញឧស្ម័នពីប្រភពចល័ត។
- ឧបសម្ព័ន្ធ ៥ ៖ កម្រិតកំណត់ស្តង់ដារអតិបរមា ដែលអនុញ្ញាតបញ្ចេញសំឡេងនៅលើផ្លូវសាធារណៈពីប្រភពយានយន្ត។
- ឧបសម្ព័ន្ធ ៦ ៖ កម្រិតកំណត់ស្តង់ដារសំឡេងអតិបរមា ដែលអនុញ្ញាតនៅតំបន់សាធារណៈ និងតំបន់លំនៅដ្ឋាន (dB (A))។
- ឧបសម្ព័ន្ធ ៧ ៖ កម្រិតកំណត់ស្តង់ដារសម្រាប់ត្រួតពិនិត្យសំឡេងក្នុងទីតាំងរោងជាង រោងចក្រឧស្សាហកម្ម។

Draft

- ឧបសម្ព័ន្ធ ៨ ៖ កម្រិតកំណត់ស្តង់ដារជាតិស្ពាន់ធ័រ សំណ បង់សែន និងអ៊ីដ្រូកាប៊ួប្រហើរដែលអនុញ្ញាតឲ្យមាននៅក្នុងប្រេងឥន្ធនៈ និងធ្យូងថ្ម។

### តារាង ៣.៤ ៖ ឧបសម្ព័ន្ធ ១ កម្រិតកំណត់ស្តង់ដារគុណភាពខ្យល់

| ល.រ | ប៉ារ៉ាម៉ែត្រ | ខ្នាត | រយៈពេលជាមធ្យម | | | |
|---|---|---|---|---|---|---|
| | | | ១ម៉ោង | ៨ម៉ោង | ២៤ម៉ោង | ១ឆ្នាំ |
| ១ | កាបូនអុកស៊ីត CO | mg/m$^3$ | ៤០ | ២០ | | |
| ២ | អាសូតឌីអុកស៊ីត $NO_2$ | mg/m$^3$ | ០.៣ | | ០.១០ | ០.១០ |
| ៣ | ស្ពាន់ធ័រឌីអុកស៊ីត $SO_2$ | mg/m$^3$ | ០.៥ | | ០.៣០ | |
| ៤ | អូសូន $O_3$ | mg/m$^3$ | ០.២ | | ០.០០៥ | |
| ៥ | សំណ Pb | mg/m$^3$ | | | ០.៣៣ | |
| ៦ | សារធាតុរឹងអណ្តែតក្នុងខ្យល់ TSP | mg/m$^3$ | | | | ០.១០ |

***កំណត់សម្គាល់៖***

- *កម្រិតកំណត់ស្តង់ដារនេះ អនុវត្តន៍សម្រាប់ធ្វើការវាយតម្លៃគុណភាពខ្យល់ទូទៅ និងអង្កេតតាមដានស្ថានភាពនៃការបំពុលខ្យល់*
- *វិធីសាស្ត្រនៃការវិភាគគុណភាពខ្យល់នឹងត្រូវកំណត់តាមគោលការណ៍ណែនាំរបស់ក្រសួងបរិស្ថាន*
- *TSP – Total Suspended Particulate*

### តារាង ៣.៥ ៖ ឧបសម្ព័ន្ធ ៥ កម្រិតកំណត់ស្តង់ដារអតិបរមា ដែលអនុញ្ញាតបញ្ចេញសំឡេងទៅលើផ្លូវ សាធារណៈពីប្រភពយានយន្ត

| ល.រ | ប្រភេទយានយន្ត | កម្រិតអតិបរមា (dB(A)) |
|---|---|---|
| ១ | ទោចក្រយានយន្តចំណុះស៊ីឡាំង (cc)< ១២៥ cm$^3$ | ៨៥ |
| ២ | ទោចក្រយានយន្តចំណុះស៊ីឡាំង (cc)≥ ១២៥ cm$^3$ | ៩០ |
| ៣ | ត្រីចក្រយានយន្ត | ៩០ |
| ៤ | រថយន្តធុនតូច រថយន្តដឹកអ្នកដំណើរ< ១២នាក់ | ៨០ |
| ៥ | រថយន្តដឹកអ្នកដំណើរ≥ ១២នាក់ | ៨៥ |
| ៦ | រថយន្តដឹកទំនិញដែលផ្ទុកទំនិញ< ៣,៥តោន | ៨៥ |
| ៧ | រថយន្តដឹកទំនិញដែលផ្ទុកទំនិញ≥ ៣,៥តោន | ៨៨ |
| ៨ | រថយន្តដឹកទំនិញដែលមានកម្លាំង≥ ១៥០ KW | ៨៩ |
| ៩ | គ្រឿងយន្តផ្សេងៗទៀតដែលមិនបានរៀបរាប់ខាងលើ | ៩១ |

***កំណត់សម្គាល់៖*** *កម្រិតកំណត់ស្តង់ដារនេះ អនុវត្តន៍សម្រាប់ការត្រួតពិនិត្យកម្រិតបញ្ចេញសំឡេងពីប្រភពយានយន្តគ្រប់ប្រភេទដែលកំពុងធ្វើចរាចរណ៍លើផ្លូវសាធារណៈ។*

Draft

**តារាង ៣.៦ ៖ ឧបសម្ព័ន្ធ ៦ កម្រិតកំណត់ស្តង់ដារសំឡេងអតិបរមា ដែលអនុញ្ញាតនៅតំបន់សាធារណៈ និង តំបន់លំនៅដ្ឋាន**

| ល.រ | ទីតាំង | អំឡុងពេល | | |
|---|---|---|---|---|
| | | ពីម៉ោង៦ព្រឹកដល់ម៉ោង១៨ល្ងាច | ពីម៉ោង១៨ល្ងាចដល់ម៉ោង២២យប់ | ពីម៉ោង២២យប់ដល់ម៉ោង៦ព្រឹក |
| ១ | តំបន់ស្ងៀមស្ងាត់<br>-មន្ទីរពេទ្យ<br>-បណ្ណាល័យ<br>-សាលារៀន<br>-មត្តេយ្យសាលា | ៤៥ | ៤០ | ៣៥ |
| ២ | -តំបន់លំនៅដ្ឋាន<br>-សណ្ឋាគារ ទីកន្លែង រដ្ឋបាល<br>-ភូមិគ្រឹះ ផ្ទះល្វែង | ៦០ | ៥០ | ៤៥ |
| ៣ | តំបន់ពាណិជ្ជកម្ម សេវាកម្ម និងចម្រុះ | ៧០ | ៦៥ | ៥០ |
| ៤ | ឧស្សាហកម្មធុនស្រាល លាយចម្រុះនៅក្នុងតំបន់លំនៅដ្ឋាន | ៧៥ | ៧០ | ៥០ |

*កំណត់សម្គាល់៖ កម្រិតកំណត់ស្តង់ដារនេះ អនុវត្តន៍សម្រាប់ការត្រួតពិនិត្យកម្រិតសំឡេងពីប្រភព ឬសកម្មភាពណាមួយ ដែលបញ្ចេញសំឡេងចូលក្នុងតំបន់សាធារណៈ និងតំបន់លំនៅដ្ឋាន។*

### ៣.៣.៥ អនុក្រឹត្យស្តីពីការគ្រប់គ្រងដីរដ្ឋ (២០០៥)

អនុក្រឹត្យលេខ ១១៨ អនក្រ.បក ស្តីពីការគ្រប់គ្រងដីរដ្ឋ បានអនុម័តនៅថ្ងៃទី០៧ ខែតុលា ឆ្នាំ២០០៥ ដោយរាជរដ្ឋាភិបាលកម្ពុជា។

មាត្រា ១..

អនុក្រឹត្យនេះមានគោលដៅកំណត់គោលការណ៍ នីតិវិធី យន្តការ និងការរៀបចំផ្នែកសម្រាប់ការគ្រប់គ្រងដីរដ្ឋលើ ៖

- ការធ្វើអត្តសញ្ញាណកម្ម និងការធ្វើផែនទីដីរដ្ឋ
- ការចុះបញ្ជី និងការធ្វើចំណាត់ថ្នាក់ដីរដ្ឋ
- ការបង្កើត និងការថែរក្សាប្រព័ន្ធទិន្នន័យដីរដ្ឋ
- ការបែងចែក និងការគ្រប់គ្រងដីរដ្ឋ និង
- ការធ្វើចំណាត់ថ្នាក់ដីរដ្ឋឡើងវិញ។

មាត្រា ៣..

គោលការណ៍ទូទៅសម្រាប់អនុវត្តន៍ក្នុងការគ្រប់គ្រងដីរដ្ឋមានដូចខាងក្រោម ៖

ក-ជាទូទៅរដ្ឋ គឺជាម្ចាស់នៃដីទាំងអស់ដែលមិនស្ថិតនៅក្រោមការកាន់កាប់ជាកោតៈស្របច្បាប់ ឬជាកម្មសិទ្ធ ដោយបុគ្គលឯកជន ឬដោយសមូហភាពស្របតាមច្បាប់ភូមិបាលឆ្នាំ ២០០១។

ខ-ដីរដ្ឋរួមមានដីសាធារណៈរបស់រដ្ឋ និងដីឯកជនរបស់រដ្ឋ។

Draft

គ-ក្បាលដីរដ្ឋនីមួយៗ ត្រូវចុះបញ្ជីជាដីសាធារណៈរបស់រដ្ឋ ឬជាដីឯកជនរបស់រដ្ឋនៅក្នុងសៀវភៅគោលបញ្ជីដីធ្លី។

ឃ-ដីរដ្ឋអាចផ្តល់ឲ្យជាសម្បទានដីសង្គមកិច្ច ជាសម្បទានដីសេដ្ឋកិច្ច ឬជាសម្បទានផ្សេងៗទៀតបានលុះត្រាតែដីនោះត្រូវបានចុះបញ្ជីថាជាដីសាធារណៈរបស់រដ្ឋ និងជាដីឯកជនរបស់រដ្ឋ និងត្រូវអនុវត្តន៍តាមនីតិវិធីច្បាប់។

មាត្រា ៨..

ក- ការចុះបញ្ជីដីរដ្ឋត្រូវធ្វើឡើងផ្អែកលើការចុះបញ្ជីដែលមានលក្ខណៈជាប្រព័ន្ធអនុលោមតាមអនុក្រឹត្យស្តីពីនីតិវិធីនៃការកសាងប្លង់សុរិយោដី និងសៀវភៅគោលបញ្ជីដីធ្លី ឬផ្អែកលើការចុះបញ្ជីដែលមានលក្ខណៈដាច់ដោយដុំ អនុលោមតាមអនុក្រឹត្យស្តីពីការចុះបញ្ជីដីធ្លីដាច់ដោយដុំ។

ខ- ដំណើរការចុះបញ្ជីដីរដ្ឋរួមមាន ៖

១. ការបញ្ជាក់កម្មសិទ្ធិរបស់រដ្ឋលើដី។

២. ការកំណត់ព្រំប្រទល់ច្បាស់លាស់លើដី។

៣. ការដោះស្រាយទំនាស់ដោយអាជ្ញាធរមានសមត្ថកិច្ច។

៤. ការចុះបញ្ជីក្នុងសៀវភៅគោលបញ្ជីដីធ្លី។

គ- ប្រសិនបើមានការធ្វើអត្តសញ្ញាណកម្ម និងការធ្វើផែនទីដីរដ្ឋមុនពេលធ្វើការចុះបញ្ជីដីលទ្ធផលនៃការធ្វើអត្តសញ្ញាណកម្ម និងការធ្វើផែនទីដីរដ្ឋនោះ មិនមែនជាព័ត៌មានសម្រេចឡើយ តែជាព័ត៌មានបឋមសម្រាប់ប្រើប្រាស់ក្នុងដំណើរការចុះបញ្ជីដីរដ្ឋ។

ឃ- ក្រសួងស្ថាប័ន ឬអាជ្ញាធរដែនដីដែលអះអាងថាក្បាលដីរដ្ឋណាមួយ ជាដីសាធារណៈរបស់រដ្ឋត្រូវផ្តល់ឯកសារ និងភស្តុតាងផ្សេងៗទៀតដែលបង្ហាញថាដីនោះត្រូវបានរាប់បញ្ចូលជាទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈដូចមានចែងក្នុងមាត្រា ១៥ នៃច្បាប់ភូមិបាលឆ្នាំ ២០០១។

ង- ក្នុងការចុះបញ្ជីដីលើដំបូងដីរដ្ឋដែលមិនបានបង្ហាញឲ្យឃើញថា មានចរិកបម្រើប្រយោជន៍សាធារណៈដូចមានចែងក្នុងមាត្រា ៤ នៃអនុក្រឹត្យនេះ និងមាត្រា ១៥ នៃច្បាប់ភូមិបាលត្រូវចុះបញ្ជីជាដីឯកជនរបស់រដ្ឋ។

៣.៣.៦ អនុក្រឹត្យស្តីពីសម្បទានដីសេដ្ឋកិច្ច

អនុក្រឹត្យលេខ ១៤៦ អនក្រ.បក ស្តីពីសម្បទានដីសេដ្ឋកិច្ចបានអនុម័ត ដោយរាជរដ្ឋាភិបាលនៅថ្ងៃទី ២៧ ខែធ្នូ ឆ្នាំ២០០៥ ។ ខ្លឹមសារសំខាន់ៗ នៃអនុក្រឹត្យនេះមានដូចខាងក្រោម ៖

មាត្រា ១..

អនុក្រឹត្យនេះមានគោលដៅកំណត់លក្ខណៈវិនិច្ឆ័យ នីតិវិធី យន្តការ និងការរៀបចំស្ថាប័នសម្រាប់ការផ្តួចផ្តើម និងការផ្តល់សម្បទានដីសេដ្ឋកិច្ចសម្រាប់ការតាមដានត្រួតពិនិត្យការអនុវត្តន៍កិច្ចសន្យា និងសម្រាប់ការត្រួតពិនិត្យឡើងវិញលើសម្បទានដីសេដ្ឋកិច្ចដែលបានចុះកិច្ចសន្យាមុនពេល ដែលអនុក្រឹត្យនេះចូលជាធរមានស្របតាមការកំណត់នៃច្បាប់ភូមិបាលឆ្នាំ ២០០១។

មាត្រា ៧..

អាជ្ញាធរមានសមត្ថកិច្ចចុះកិច្ចសន្យា ជាអ្នកផ្តួចផ្តើមលើគម្រោងសម្បទានដីសេដ្ឋកិច្ចតាមជំហានដូចតទៅ ៖



Draft

១. រៀបចំឯកសារដំបូងសម្រាប់ស្នើគម្រោងសម្បទានដីសេដ្ឋកិច្ច តាមទម្រង់ដែលត្រូវបង្កើតឡើងដោយលេខាធិការដ្ឋានបច្ចេកទេសហើយដែលត្រូវមានបញ្ចូលព័ត៌មានដូចចែងក្នុងមាត្រា ៨ នៃអនុក្រឹត្យនេះ។

២. បញ្ជូនឯកសារដំបូងទៅលេខាធិការដ្ឋានបច្ចេកទេសដើម្បីធ្វើការពិនិត្យសិក្សា និងផ្តល់អនុសាសន៍បឋមដោយផ្អែកលើមាត្រា ៣ និងមាត្រា ៥ នៃអនុក្រឹត្យនេះ។

៣. ពិគ្រោះយោបល់ជាមួយគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់ខេត្តក្រុង និងជាមួយស្ថាប័នដាក់បញ្ញត្តិលើគម្រោងសម្បទានដីសេដ្ឋកិច្ច។

៤. រៀបចំឲ្យមានការវាយតម្លៃដំបូងអំពីហេតុប៉ះពាល់បរិស្ថាន និងសង្គមសម្រាប់គម្រោងសម្បទាន ដីសេដ្ឋកិច្ច។

៥. ប្រសិនបើការវាយតម្លៃដំបូងអំពីហេតុប៉ះពាល់បរិស្ថាន និងសង្គម បង្ហាញនូវហេតុប៉ះពាល់អវិជ្ជមានកម្រិតមធ្យម ឬខ្ពស់ត្រូវរៀបចំឲ្យមានការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមពេញលេញ។

៦. រៀបចំឯកសារពេញលេញសម្រាប់គម្រោងសម្បទានដីសេដ្ឋកិច្ច ដែលមានបញ្ចូលអនុសាសន៍ទាំងអស់ និងរបាយការណ៍នានាដែលជាលទ្ធផលនៃជំហានរៀបរាប់ខាងលើជាមូលដ្ឋានក្នុងការរៀបចំឯកសារស្តីពីលក្ខខណ្ឌសម្រាប់ការដាក់សំណើដែលមានការអំពាវនាវ។

## ៣.៤ ប្រកាស

### ៣.៤.១ ប្រកាសអន្តរក្រសួងមហាផ្ទៃ និងក្រសួងបរិស្ថានស្តីពីការគ្រប់គ្រងសំរាម សំណល់រឹងនៅក្នុងខេត្តក្រុងនៃព្រះរាជាណាចក្រកម្ពុជា (២០០៣)

ប្រកាសអន្តរក្រសួងលេខ៨០ ប្រក.មផ-បស្ក ចុះថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០០៣ ស្តីពីការគ្រប់គ្រងសំរាម សំណល់រឹងនៅក្នុងខេត្ត ក្រុង នៃព្រះរាជាណាចក្រកម្ពុជា។

- ប្រការ ១ ៖ ប្រកាសនេះមានគោលបំណងជំរុញកិច្ចទទួលខុសត្រូវរបស់អាជ្ញាធរដែនដី និងសមត្ថកិច្ចពាក់ព័ន្ធក្នុងការអនុវត្តន៍ប្រកបដោយប្រសិទ្ធភាពនូវវិធានការគ្រប់គ្រងសំរាម សំណល់រឹង នៅក្នុងខេត្ត ក្រុងនៃព្រះរាជាណាចក្រកម្ពុជា ដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ខ្លួនសំដៅធានាបាននៅកិច្ចការពារសុខភាពសាធារណៈ សោភ័ណភាព គុណភាពបរិស្ថាន និងជីវៈចម្រុះ។
- ប្រការ ៤ ៖ ការបោះចោល ឬចាក់ចោលសំរាម សំណល់រឹងរាយប៉ាយតាមដងផ្លូវទីសាធារណៈ ទីប្រជុំជន ទីផ្សារ កន្លែងកំសាន្ត មណ្ឌលទេសចរណ៍ រមណីយដ្ឋាន បូជនីយដ្ឋាន ទីវាលស្រែចម្ការ តំបន់ ការពារ តំបន់ព្រៃភ្នំ តំបន់ឆ្នេរ ច្រាំងទន្លេ ប្រភពទឹកប្រើប្រាស់ ផ្លូវនាវាចរ ប្រព័ន្ធបង្ហូរទឹកកលូ ប្រព័ន្ធប្រឡាយ កសិកម្ម ត្រូវហាមឃាត់ជាដាច់ខាត។
- ប្រការ ៥ ៖ អាជ្ញាធរដែនដីត្រូវទទួលខុសត្រូវ និងចាត់វិធានការចាំបាច់មួយចំនួន ដើម្បីរាំងនិងបញ្ឈប់ការចោលសំរាម សំណល់រឹងរាយប៉ាយនៅតាមទីកន្លែងដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ខ្លួនដូចមានចែងនៅក្នុងប្រការ ៤ ខាងលើរួមមាន ៖
  - ក- រៀបចំដាក់ធុងសំរាមសាធារណៈឲ្យបានគ្រប់គ្រាន់ ធានាបាននូវសោភ័ណភាព និងបរិស្ថានស្អាត។
  - ខ- រៀបចំដាក់ផ្លាកសញ្ញាហាមឃាត់ និងអប់រំពីការទុកដាក់និងបោះចោលសំរាម សំណល់រឹង។



Draft

គ- កំណត់ និងរៀបចំកន្លែងស្តុកសំរាម សំណល់រឹងបណ្តោះអាសន្ន ឲ្យបានសមស្របដោយមិនបង្កបញ្ហាដែលនាំឲ្យប៉ះពាល់ដល់ការធ្វើចរាចរ សុខភាពសាធារណៈ សោភ័ណភាព និងសណ្តាប់ធ្នាប់សង្គម។

ឃ- ធ្វើការប្រមូល សម្អាត និងដឹកជញ្ជូនសំរាម សំណល់រឹងទាំងនោះយកទៅចាក់ចោលនៅទីតាំងដែលបានកំណត់ដោយស្ថាប័នមានសមត្ថកិច្ច ឬអាជ្ញាធរដែនដីឲ្យបានទៀងទាត់ជាប្រចាំ។

- ប្រការ ៩ ៖ ការដុតសំរាម សំណល់រឹងគ្រប់ប្រភេទ ទោះស្ថិតក្នុងទីលាន ឬល្អៅចាក់សំរាម សំណល់រឹងក្តីត្រូវហាមឃាត់ជាដាច់ខាត។
- ប្រការ ១១ ៖ មន្ទីរបរិស្ថានខេត្ត ក្រុង និងភ្នាក់ងារបរិស្ថាន ខណ្ឌ ស្រុក ត្រូវបំពេញភារកិច្ចជាសេនាធិការឲ្យអាជ្ញាធរដែនដីក្នុងការរៀបចំផែនការគ្រប់គ្រង និងចូលរួមធ្វើផែនការសកម្មភាពក្នុងការប្រមូលស្តុកទុកបណ្តោះអាសន្ន ដឹកជញ្ជូន និងបោះចោលសំរាម សំណល់រឹង ហើយត្រូវចូលរួមសហការ និងត្រូវពិនិត្យការអនុវត្តន៍នោះ។
- ប្រការ ១៤ ៖ ប្រជាពលរដ្ឋគ្រប់រូប ត្រូវមានកាតព្វកិច្ចចូលរួមយ៉ាងសកម្ម ក្នុងការថែទាំអនាម័យលំនៅដ្ឋាន និងជុំវិញលំនៅដ្ឋាន សោភ័ណភាពទីសាធារណៈ ឬទីប្រជុំជននៃខេត្ត ក្រុង គុណភាពបរិស្ថាន និងត្រូវចូលរួមយ៉ាងសកម្មក្នុងការការពារ និងថែទាំធុងសំរាមសាធារណៈ។

### ៣.៤.២ ប្រកាសស្តីពីគោលការណ៍ណែនាំទូទៅ ក្នុងការធ្វើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់ បរិស្ថានដំបូង និងពេញលេញ

ប្រកាសលេខ ៣៧៦ ប្រក.ប.ស្ក ចុះថ្ងៃទី០២ ខែកញ្ញា ឆ្នាំ២០០៩ ស្តីពីគោលការណ៍ណែនាំទូទៅក្នុងការធ្វើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង និងពេញលេញ។

- ប្រការ ១ ៖ មានគោលបំណងអនុវត្តន៍គោលការណ៍ណែនាំ ទូទៅស្តីពីការរៀបចំរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង ពេញលេញ និងតារាងសង្ខេបដូចមានភ្ជាប់ក្នុងឧបសម្ព័ន្ធ ១ និង ២ ប្រកាសនេះ។
- ប្រការ ២ ៖ ម្ចាស់គម្រោងជាបុគ្គលឯកជន ជាក្រុមហ៊ុនឯកជន ជាក្រុមហ៊ុនចំណុះរដ្ឋ ឬក្រុមហ៊ុនរដ្ឋជាក្រសួង/ស្ថាប័នរដ្ឋ ត្រូវរៀបចំរបាយការណ៍វាយតម្លៃហេតុប៉ះពាល់ដំបូង ឬពេញលេញ លើគម្រោងស្នើឡើងព្រមទាំងសកម្មភាពដែលមានស្រាប់ និងកំពុងដំណើរការដូចមានចែងក្នុងឧបសម្ព័ន្ធនៃអនុក្រឹត្យលេខ ៧២ អនក្រ.បក ចុះថ្ងៃទី ១១ ខែ សីហា ឆ្នាំ ១៩៩៩ ស្តីពី "កិច្ចដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន" ដើម្បីដាក់ជូនក្រសួងបរិស្ថានពិនិត្យ និងផ្តល់យោបល់លើកលែងតែគម្រោងដែលមានលក្ខណៈពិសេស និងចាំបាច់បន្ទាន់ដែលសម្រេចដោយរាជរដ្ឋាភិបាល។
- ប្រការ ១១ ៖ ក្នុងការពិនិត្យនិងផ្តល់យោបល់លើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង ឬពេញលេញរបស់ក្រសួងបរិស្ថាន ដោយគិតចាប់ពីថ្ងៃទទួលរបាយការណ៍ជាផ្លូវការមានដូចខាងក្រោម ៖
    - មន្ត្រីជំនាញរបស់នាយកដ្ឋានអង្កេត ពិនិត្យការវាយតម្លៃហេតុប៉ះពាល់បរិស្ថានចុះពិនិត្យទីតាំងជាក់ស្តែង និងផ្តល់យោបល់ក្នុងរយៈពេល ១០ ថ្ងៃ។
    - អន្តរនាយកដ្ឋានពាក់ព័ន្ធរបស់ក្រសួងបរិស្ថានមានរយៈពេល ០៥ ថ្ងៃ។
    - ថ្នាក់ដឹកនាំរបស់ក្រសួងបរិស្ថានមានរយៈពេល ០៥ ថ្ងៃ។

Draft

- អន្តរក្រសួងមានរយៈពេល ០៥ ថ្ងៃ ដែលមានការចូលរួមពីក្រសួង/ស្ថាប័នពាក់ព័ន្ធ អាជ្ញាធរមូលដ្ឋាន អង្គការរដ្ឋាភិបាល និងអ្នកពាក់ព័ន្ធនានានឹងគម្រោងវិនិយោគ ដោយមានរដ្ឋមន្ត្រីក្រសួងបរិស្ថានជាប្រធាន។

### ៣.៤.៣ ប្រកាសស្តីពីការដាក់ឲ្យប្រើប្រាស់នូវកម្រិតកំណត់ស្តង់ដារបរិមាណជាតិពុល ឬសាធាតុគ្រោះថ្នាក់ដែលអនុញ្ញាតឲ្យបោះបង់ចោល

ប្រកាសលេខ៣៨៧ ប្រ.ក.ប.ស្ថ ចុះថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០១៥ ស្តីពីការដាក់ឲ្យប្រើប្រាស់នូវកម្រិតកំណត់ស្តង់ដារបរិមាណជាតិពុល ឬសាធាតុគ្រោះថ្នាក់ដែលអនុញ្ញាតឲ្យបោះបង់ចោល។

- ប្រការ ១ ៖

ដាក់ឲ្យប្រើប្រាស់នូវកម្រិតកំណត់ស្តង់ដារបរិមាណសាជាតុគីមីពុល ឬសាធាតុគ្រោះថ្នាក់នៅក្នុងសំណល់ដែលអនុញ្ញាតឲ្យមាននៅក្នុងដីដូចមានចែងក្នុងឧបសម្ព័ន្ធ ១ និងតារាងឧបសម្ព័ន្ធ ២ នៃប្រកាសនេះ។

- ប្រការ ២ ៖

រាល់ការបោះបង់ចោលនូវសាជាតុគីមីពុល សាជាតុគ្រោះថ្នាក់ ឬសំណល់គ្រោះថ្នាក់ត្រូវស្នើសុំមកក្រសួងបរិស្ថាន។

- ប្រការ ៣ ៖

បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយ និងប្រកាសនេះត្រូវទុកជានិរាករណ៍។

- ប្រការ ៤ ៖

អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ អគ្គនាយកនៃអគ្គនាយកដ្ឋានចំណេះដឹង និងព័ត៌មានបរិស្ថានអគ្គនាយកដ្ឋាននៃអគ្គនាយកដ្ឋានគាំពារបរិស្ថាន អគ្គនាយកដ្ឋាននៃអគ្គនាយកដ្ឋានរដ្ឋបាលការពារ និងអភិរក្សធម្មជាតិអគ្គាធិការនៃអគ្គាធិការដ្ឋាន ប្រធាននាយកដ្ឋានគ្រប់គ្រងសាជាតុគ្រោះថ្នាក់ នាយកដ្ឋានសវនកម្មផ្ទៃក្នុងនាយកខុទ្ទកាល័យគ្រប់គ្រងអង្គភាពចំណុះក្រសួងបរិស្ថាន ត្រូវទទួលបន្ទុកអនុវត្តន៍ប្រកាសនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

Draft

តារាង ៣.៧ ៖ ឧបសម្ព័ន្ធ១ កម្រិតកំណត់ស្តង់ដារបរិមាណជាតិពុល ឬសាធាតុគ្រោះថ្នាក់ដែលអនុញ្ញាតឲ្យបោះបង់ចោលនៅទីលានសុវត្ថិភាព

| ល.រ | ឈ្មោះសាជាតុគីមី | ឯកតា (មីលីក្រាម/គ.ក្រ នៃសំណល់ស្ងួត) | កំហាប់អតិបរិមាណនៃសារជាតុគីមីពុលនៅក្នុងសំណល់ |
|---|---|---|---|
| ១ | អាសេនិច និងសមាសភាគរបស់វា(As) | មីលីក្រាម/គ.ក្រ | <៤០ |
| ២ | កាត់ម្ញូម និងសមាសភាគរបស់វា(Cd) | មីលីក្រាម/គ.ក្រ | <៥.០ |
| ៣ | ក្រូម និងសមាសភាគរបស់វា$(Cr)^{+6}$ | មីលីក្រាម/គ.ក្រ | <៣៨០ |
| ៤ | ទង់ដែង និងសមាសភាគរបស់វា(Cu) | មីលីក្រាម/គ.ក្រ | <១៩០ |

| ល.រ | ឈ្មោះសាធាតុគីមី | ឯកតា (មីលីក្រាម/គ.ក្រ នៃសំណល់ស្ងួត) | កំហាប់អតិបរិមាណនៃសារធាតុគីមីពុលនៅក្នុងសំណល់ |
|---|---|---|---|
| ៥ | សំណរ និងសមាសភាគរបស់វា(Pb) | មីលីក្រាម/គ.ក្រ | <៤២០ |
| ៦ | បារត និងសមាសភាគរបស់វា(Hg) | មីលីក្រាម/គ.ក្រ | <១០ |
| ៧ | ម៉ូលីបដែន និងសមាសភាគរបស់វា(Mo) | មីលីក្រាម/គ.ក្រ | <៥៧ |
| ៨ | នីកែល និងសមាសភាគរបស់វា(Ni) | មីលីក្រាម/គ.ក្រ | <៧៥ |
| ៩ | សេលេញ៉ូម និងសមាសភាគរបស់វា(Se) | មីលីក្រាម/គ.ក្រ | <១០០ |
| ១០ | សង្កសី និងសមាសភាគរបស់វា(Zn) | មីលីក្រាម/គ.ក្រ | <៥០០ |
| ១១ | ស៊ីអានីត និងសមាសភាគរបស់វា(CN) | មីលីក្រាម/គ.ក្រ | <៥០ |
| ១២ | ភ្លុយអរីន និងសមាសភាគរបស់វា(F) | មីលីក្រាម/គ.ក្រ | <៤០០ |
| ១៣ | ម៉ង់កាណែស និងសមាសភាគរបស់វា(Mn) | មីលីក្រាម/គ.ក្រ | <៥០០ |
| ១៤ | បង់សែន ($C_6H_6$) | មីលីក្រាម/គ.ក្រ | <១.០ |
| ១៥ | តូលុយអែន ($C_6H_5CH_3$) | មីលីក្រាម/គ.ក្រ | <១៣០ |
| ១៦ | អេទីលបង់សែន ($C_6H_5CH_2CH_3$) | មីលីក្រាម/គ.ក្រ | <៥០ |
| ១៧ | ស៊ីឡែន ($C_6H_4C_2H_6$) | មីលីក្រាម/គ.ក្រ | <២៥ |
| ១៨ | ផេណុល ($C_6H_6O$) | មីលីក្រាម/គ.ក្រ | <៤០ |
| ១៩ | ក្រេសុល ($CH_3C_6H_4OH$) | មីលីក្រាម/គ.ក្រ | <៥.០ |
| ២០ | ស្ទីរ៉ែន ($C_6H_5CH_=CH_2$) | មីលីក្រាម/គ.ក្រ | <១០០ |
| ២១ | អ៊ីដ្រូកាប៊ួប្រហើរ (PAH ទាំង១០មុខ) | មីលីក្រាម/គ.ក្រ | <៤០ |
| ២២ | ណិបតាឡែន ($C_{10}H_8$) | មីលីក្រាម/គ.ក្រ | <៤០ |
| ២៣ | ផេណាន់ត្រែន ($C_{14}H_{10}$) | មីលីក្រាម/គ.ក្រ | <៤០ |
| ២៤ | អាន់ត្រាសែន ($C_{14}H_{10}$) | មីលីក្រាម/គ.ក្រ | <៤០ |
| ២៥ | ភ្លុយអ៉ាន់តែន ($C_{16}H_{10}$) | មីលីក្រាម/គ.ក្រ | <៤០ |
| ២៦ | បេនស្សូ (a) អានត្រសែន ($C_{18}H_{12}$) | មីលីក្រាម/គ.ក្រ | <៤០ |
| ២៧ | គ្រីសែន ($C_{18}H_{12}$) | មីលីក្រាម/គ.ក្រ | <៤០ |
| ២៨ | បេនស្សូ(k) ភ្លុយអអាន់តែន ($C_{20}H_{12}$) | មីលីក្រាម/គ.ក្រ | <៤០ |
| ២៩ | បេនស្សូពីរ៉ែន ($C_{20}H_{12}$) | មីលីក្រាម/គ.ក្រ | <៤០ |
| ៣០ | បេនស្សូ ghi ពីរ៉ែន ($C_{22}H_{12}$) | មីលីក្រាម/គ.ក្រ | <៤០ |
| ៣១ | អ៊ីនដេណូ(១,២,៣-cd)ពីរ៉ែន ($C_{22}H_{12}$) | មីលីក្រាម/គ.ក្រ | <៤០ |
| ៣២ | ឌីក្លរូមេតាន ($CH_2Cl_2$) | មីលីក្រាម/គ.ក្រ | <១០ |
| ៣៣ | ទ្រីក្លរូមេតាន ($CHCl_3$) | មីលីក្រាម/គ.ក្រ | <១០ |

Draft

| ល.រ | ឈ្មោះសាធាតុគីមី | ឯកតា (មីលីក្រាម/គ.ក្រ នៃសំណល់ស្ងួត) | កំហាប់អតិបរិមាណនៃសារធាតុគីមីពុលនៅក្នុងសំណល់ |
|---|---|---|---|
| ៣៤ | កាបូនតេត្រាក្លរីត ($CCl_4$) | មីលីក្រាម/គ.ក្រ | <១.០ |
| ៣៥ | ទ្រីក្លរូអេទីឡែន ($C_2HCl_2$) | មីលីក្រាម/គ.ក្រ | <៦០ |
| ៣៦ | តេត្រាក្លរូអេទីឡែន ($Cl_2C=CCl_2$) | មីលីក្រាម/គ.ក្រ | <៤០ |
| ៣៧ | ១,១-ឌីក្លរូអេទីឡែន ($C_2H_4Cl_2$) | មីលីក្រាម/គ.ក្រ | <១៥ |
| ៣៨ | ១,២-ឌីក្លរូអេតាន ($ClCH_2$-$CH_2Cl$) | មីលីក្រាម/គ.ក្រ | <៤.០ |
| ៣៩ | វីនីលក្លរីត ($C_2H_3Cl$) | មីលីក្រាម/គ.ក្រ | <០.១ |
| ៤០ | ១,១,១-ទ្រីក្លរូអេតាន ($CH_3CCl_3$) | មីលីក្រាម/គ.ក្រ | <១៥ |
| ៤១ | ១,១,២-ទ្រីក្លរូអេតាន ($C_2H_3Cl_3$) | មីលីក្រាម/គ.ក្រ | <១០ |
| ៤២ | ក្លរូបង់សែន ($C_6H_5Cl$) | មីលីក្រាម/គ.ក្រ | <៣០ |
| ៤៣ | ក្លរូផេណុល ($C_6H_5ClO$) | មីលីក្រាម/គ.ក្រ | <១០ |
| ៤៤ | ក្លរូណាប់តាឡែន ($C_{10}H_7Cl$) | មីលីក្រាម/គ.ក្រ | <១០ |
| ៤៥ | ប៉ូលីក្លរូប៊ីផេនីល ($PCB_s$) | មីលីក្រាម/គ.ក្រ | <១.០ |
| ៤៦ | ឌីអុកស៊ីន និងហ្វូរ៉ាន ($TCDD_s/F_s$) | មីលីក្រាម/គ.ក្រ | <១.០ |
| ៤៧ | ឌីក្លរូប្រូប៉ាន ($CH_3CHClCH_2Cl$) | មីលីក្រាម/គ.ក្រ | <២.០ |
| ៤៨ | ដេដេតេ (DDT/DDD/DDE) | មីលីក្រាម/គ.ក្រ | <៤.០ |
| ៤៩ | អលឌ្រីន ($C_{12}H_8Cl_6$) | មីលីក្រាម/គ.ក្រ | <៤.០ |
| ៥០ | ឌីអលឌ្រីន ($C_{12}H_8Cl_6O$) | មីលីក្រាម/គ.ក្រ | <៤.០ |
| ៥១ | អង់ឌ្រីន ($C_{12}H_8Cl_6O$) | មីលីក្រាម/គ.ក្រ | <២.០ |
| ៥២ | អ៊ិកសាក្លរូស៊ីក្លូអ៊ិកសែន (HCH-compounds) | មីលីក្រាម/គ.ក្រ | <៥.០ |
| ៥៣ | កាបារីល ($C_{12}H_{11}NO_2$) | មីលីក្រាម/គ.ក្រ | <២.០ |
| ៥៤ | កាបូហ្វូរ៉ាន់ ($C_{12}H_{15}NO_2$) | មីលីក្រាម/គ.ក្រ | <៦.០ |
| ៥៥ | អាត្រាស៊ីន ($C_8H_{14}ClN_5$) | មីលីក្រាម/គ.ក្រ | <៤.០ |
| ៥៦ | ក្លរដាន ($C_{10}Cl_{10}O$) | មីលីក្រាម/គ.ក្រ | <៤.០ |
| ៥៧ | អិបតាក្លរ ($C_{10}H_5Cl_7$) | មីលីក្រាម/គ.ក្រ | <៤.០ |
| ៥៨ | អិបតាក្លរ អេប៉ុកស៊ីត ($C_{10}H_6Cl_7$) | មីលីក្រាម/គ.ក្រ | <៤.០ |
| ៥៩ | អានដូស៊ុលហ្វាន់ ($C_9H_6Cl_6O_3S$) | មីលីក្រាម/គ.ក្រ | <៤.០ |
| ៦០ | ក្លរឌីកន ($C_{10}Cl_{10}O$) | មីលីក្រាម/គ.ក្រ | <៤.០ |
| ៦១ | សំណរប៉ាហាំងសរីរាង្គ និងសមាសធាតុរបស់វា (C-Sn) | មីលីក្រាម/គ.ក្រ | <២.៥ |
| ៦២ | ប្រេងធម្មជាតិ (Mineral oil) | មីលីក្រាម/គ.ក្រ | <៥០០០ |

Draft

| ល.រ | ឈ្មោះសាធាតុគីមី | ឯកតា (មីលីក្រាម/គ.ក្រ នៃសំណល់ស្ងួត) | កំហាប់អតិបរិមាណនៃសារធាតុគីមីពុលនៅក្នុងសំណល់ |
|---|---|---|---|
| ៦៣ | ពីរីឌីន ($C_5H_5N$) | មីលីក្រាម/គ.ក្រ | <0.៥ |
| ៦៤ | តេត្រូអ៊ីដ្រូហ្វូរ៉ាន់ ($C_4H_8O$) | មីលីក្រាម/គ.ក្រ | <២.0 |
| ៦៥ | ម៉ូណូអេទីឡែនគ្លយកុល ($C_2H_6O_2$) | មីលីក្រាម/គ.ក្រ | <១00 |
| ៦៦ | ឌីអេទីលឡែនគ្លយកុល ($C_4H_{10}O_3$) | មីលីក្រាម/គ.ក្រ | <២៧0 |
| ៦៧ | អាក្រីលឡូនីទ្រីល ($C_3H_3N$) | មីលីក្រាម/គ.ក្រ | <0.១ |
| ៦៨ | ហ្វម៉ុលដេអ៊ីត ($CH_2O$) | មីលីក្រាម/គ.ក្រ | <0.១ |
| ៦៩ | មេតាណុល($CH_3OH$) | មីលីក្រាម/គ.ក្រ | <៣0 |
| ៧0 | ប៊ុយតាណុល ($C_4H_9OH$) | មីលីក្រាម/គ.ក្រ | <៣0 |
| ៧១ | ១,២ ប៊ុយទីឡេសេតាស ($C_6H_{12}O_2$) | មីលីក្រាម/គ.ក្រ | <២00 |
| ៧២ | ទ្រីប្រ៊ូមេតាន ($CHBr_3$) | មីលីក្រាម/គ.ក្រ | <៧៥ |
| ៧៣ | អេទីឡេសេតាត ($C_4H_8O_2$) | មីលីក្រាម/គ.ក្រ | <៧៥ |
| ៧៤ | អ៊ីសូប្រ៊ូប៉ាណុល ($C_3H_7OH$) | មីលីក្រាម/គ.ក្រ | <២២0 |

តារាង ៣.៨ ៖ ឧបសម្ព័ន្ធ ២ កម្រិតកំណត់ស្តង់ដាជាសាធាតុគីមីពុល ឬសាធាតុគ្រោះថ្នាក់ដែលអនុញ្ញាតឲ្យមានក្នុងដី

| ល.រ | ឈ្មោះសាធាតុគីមី | ឯកតា (មីលីក្រាម/គ.ក្រ នៃសំណល់ស្ងួត) | កំហាប់អតិបរិមាណនៃសារធាតុគីមីពុលដែលអាចអនុញ្ញាតឲ្យមាននៅក្នុងដី |
|---|---|---|---|
| ១ | អាសេនិច និងសមាសភាគរបស់វា(As) | មីលីក្រាម/គ.ក្រ | <១៥ |
| ២ | បារីយ៉ូម និងសមាសភាគរបស់វា(Ba) | មីលីក្រាម/គ.ក្រ | <១៦0 |
| ៣ | កាត់ម្ញ៉ូម និងសមាសភាគរបស់វា(Cd) | មីលីក្រាម/គ.ក្រ | <0.៨ |
| ៤ | ក្រូម និងសមាសភាគរបស់វា$(Cr)^{+6}$ | មីលីក្រាម/គ.ក្រ | <១00 |
| ៥ | ទង់ដែង និងសមាសភាគរបស់វា(Cu) | មីលីក្រាម/គ.ក្រ | <១២៥ |
| ៦ | សំណរ និងសមាសភាគរបស់វា(Pb) | មីលីក្រាម/គ.ក្រ | <៨៥ |
| ៧ | បារត និងសមាសភាគរបស់វា(Hg) | មីលីក្រាម/គ.ក្រ | <0.៣ |
| ៨ | ម៉ូលីបដែន និងសមាសភាគរបស់វា(Mo) | មីលីក្រាម/គ.ក្រ | <៣.0 |

Draft

| ល.រ | ឈ្មោះសាធាតុគីមី | ឯកតា (មីលីក្រាម/គ.ក្រ នៃសំណល់ស្ងួត) | កំហាប់អតិបរិមាណនៃសារធាតុគីមីពុលដែលអាចអនុញ្ញាតឲ្យមាននៅក្នុងដី |
|---|---|---|---|
| ៩ | នីកែល និងសមាសភាគរបស់វា(Ni) | មីលីក្រាម/គ.ក្រ | <៣៥ |
| ១០ | សេលេញ៉ូម និងសមាសភាគរបស់វា(Se) | មីលីក្រាម/គ.ក្រ | <0.៧ |
| ១១ | សង្កសី និងសមាសភាគរបស់វា(Zn) | មីលីក្រាម/គ.ក្រ | <១៤០ |
| ១២ | ម៉ង់កាណែស និងសមាសភាគរបស់វា(Mn) | មីលីក្រាម/គ.ក្រ | <៣០០ |
| ១៣ | កូបាល់ (Co) | មីលីក្រាម/គ.ក្រ | <៩ |
| ១៤ | អង់ទីមន (Sb) | មីលីក្រាម/គ.ក្រ | <៣ |
| ១៥ | បេរីល្យ៉ូម (Be) | មីលីក្រាម/គ.ក្រ | <១.១ |
| ១៦ | ប្រាក់ (Ag) | មីលីក្រាម/គ.ក្រ | <១.១ |
| ១៧ | តាល់ល្យ៉ូម (Th) | មីលីក្រាម/គ.ក្រ | <១ |
| ១៨ | វ៉ាណាដ្យូម (V) | មីលីក្រាម/គ.ក្រ | <៤២ |
| ១៩ | ស៊ីអានីតសេរី (CN) | មីលីក្រាម/គ.ក្រ | <១ |
| ២០ | ប្រ៉ូមម៉ាយ (Br) | មីលីក្រាម/គ.ក្រ | <២០ |
| ២១ | ភ្លុយអរ និងសមាសភាគរបស់វា (F) | មីលីក្រាម/គ.ក្រ | <៤០០ |
| ២២ | បង់សែន ($C_6H_6$) | មីលីក្រាម/គ.ក្រ | <0.0១ |
| ២៣ | តូលុយសែន ($C_6H_5CH_3$) | មីលីក្រាម/គ.ក្រ | <0.0១ |
| ២៤ | អេទីលបង់សែន ($C_6H_5CH_2CH_3$) | មីលីក្រាម/គ.ក្រ | <0.0៣ |
| ២៥ | ស៊ីឡែន ($C_6H_4C_2H_6$) | មីលីក្រាម/គ.ក្រ | <0.១ |
| ២៦ | ផេណុល ($C_6H_6O$) | មីលីក្រាម/គ.ក្រ | <0.0៥ |
| ២៧ | ស្ទីរ៉ែន ($C_6H_5CH_=CH_2$) | មីលីក្រាម/គ.ក្រ | <0.៣ |
| ២៨ | អ៊ីដ្រូកាប៊ួប្រហើរ (PAH ទាំង១០មុខ) | មីលីក្រាម/គ.ក្រ | <១ |
| ២៩ | ណិបតាឡែន ($C_{10}H_8$) | មីលីក្រាម/គ.ក្រ | <១ |
| ៣០ | ផេណាន់ត្រែន ($C_{14}H_{10}$) | មីលីក្រាម/គ.ក្រ | <១ |
| ៣១ | អាន់ត្រាសែន ($C_{14}H_{10}$) | មីលីក្រាម/គ.ក្រ | <១ |
| ៣២ | ភ្លុយអ៉ាន់តែន ($C_{16}H_{10}$) | មីលីក្រាម/គ.ក្រ | <១ |
| ៣៣ | បេនស្សូ (a) អានត្រសែន ($C_{18}H_{12}$) | មីលីក្រាម/គ.ក្រ | <១ |
| ៣៤ | គ្រីសែន ($C_{18}H_{12}$) | មីលីក្រាម/គ.ក្រ | <១ |
| ៣៥ | បេនស្សូ(k) ភ្លុយអអាន់តែន ($C_{20}H_{12}$) | មីលីក្រាម/គ.ក្រ | <១ |
| ៣៦ | បេនស្សូពីរ៉ែន ($C_{20}H_{12}$) | មីលីក្រាម/គ.ក្រ | <១ |

Draft

| ល.រ | ឈ្មោះសាធាតុគីមី | ឯកតា (មីលីក្រាម/គ.ក្រ នៃ សំណល់ស្ងួត) | កំហាប់អតិបរិមាណនៃសារធាតុគីមីពុលដែលអាចអនុញ្ញាតឲ្យមាននៅក្នុងដី |
|---|---|---|---|
| ៣៧ | បេនស្សូ ghi ពីរីន ($C_{22}H_{12}$) | មីលីក្រាម/គ.ក្រ | <១ |
| ៣៨ | អ៊ីនដេណូ(១,២,៣-cd)ពីរីន ($C_{22}H_{12}$) | មីលីក្រាម/គ.ក្រ | <១ |
| ៣៩ | ឌីក្លរូមេតាន ($CH_2Cl_2$) | មីលីក្រាម/គ.ក្រ | <0.៤ |
| ៤០ | ទ្រីក្លរូមេតាន ($CHCl_3$) | មីលីក្រាម/គ.ក្រ | <0.0២ |
| ៤១ | កាបូនតេត្រាក្លរីត ($CCl_4$) | មីលីក្រាម/គ.ក្រ | <0.៤ |
| ៤២ | ទ្រីក្លរូអេទីឡែន ($C_2HCl_2$) | មីលីក្រាម/គ.ក្រ | <0.១ |
| ៤៣ | តេត្រាក្លរូអេទីឡែន ($Cl_2C=CCl_2$) | មីលីក្រាម/គ.ក្រ | <0.00២ |
| ៤៤ | ១,១-ឌីក្លរូអេទីឡែន ($C_2H_4Cl_2$) | មីលីក្រាម/គ.ក្រ | <0.0២ |
| ៤៥ | ១,២-ឌីក្លរូអេតាន ($ClCH_2$-$CH_2Cl$) | មីលីក្រាម/គ.ក្រ | <0.0២ |
| ៤៦ | វីនីលក្លរីត ($C_2H_3Cl$) | មីលីក្រាម/គ.ក្រ | <0.0១ |
| ៤៧ | ១,១,១-ទ្រីក្លរូអេតាន ($CH_3CCl_3$) | មីលីក្រាម/គ.ក្រ | <0.0៧ |
| ៤៨ | ១,១,២-ទ្រីក្លរូអេតាន ($C_2H_3Cl_3$) | មីលីក្រាម/គ.ក្រ | <0.៤ |
| ៤៩ | ក្លរូបង់សែន ($C_6H_5Cl$) | មីលីក្រាម/គ.ក្រ | <0.0៣ |
| ៥០ | ក្លរូផេណុល ($C_6H_5ClO$) | មីលីក្រាម/គ.ក្រ | <0.0១ |
| ៥១ | ក្លរូណាប់តាឡែន ($C_{10}H_7Cl$) | មីលីក្រាម/គ.ក្រ | <0.0១ |
| ៥២ | ឌីអុកស៊ីន និងហ្វូរ៉ាន ($TCDD_s/F_s$) | មីលីក្រាម/គ.ក្រ | <៥ |
| ៥៣ | ឌីក្លរូប្រូប៉ាន ($CH_3CHClCH_2Cl$) | មីលីក្រាម/គ.ក្រ | <0.00២ |
| ៥៤ | ប៉ូលីក្លរូប៊ីផេនីល (PCBs) | មីលីក្រាម/គ.ក្រ | <0.0២ |
| ៥៥ | ដេដេតេ (DDT/DDD/DDE) | មីលីក្រាម/គ.ក្រ | <0.00១ |
| ៥៦ | អលឌ្រីន ($C_{12}H_8Cl_6$) | មីលីក្រាម/គ.ក្រ | <0.0000៦ |
| ៥៧ | ឌីអលឌ្រីន ($C_{12}H_8Cl_6O$) | មីលីក្រាម/គ.ក្រ | <0.000៥ |
| ៥៨ | អង់ឌ្រីន ($C_{12}H_8Cl_6O$) | មីលីក្រាម/គ.ក្រ | <0.0000៤ |
| ៥៩ | អ៊ិកសាក្លរូស៊ីក្លូអ៊ិកសែន (HCH-compounds) | មីលីក្រាម/គ.ក្រ | <0.00២ |
| ៦០ | អាល់ហ្វាអ៊ិកសាក្លរូស៊ីក្លូអ៊ិកសែន (a-HCH) | មីលីក្រាម/គ.ក្រ | <0.00៣ |
| ៦១ | បេតាអ៊ិកសាក្លរូស៊ីក្លូអ៊ិកសែន | មីលីក្រាម/គ.ក្រ | <0.00៩ |
| ៦២ | ហ្គាម៉ាអ៊ិកសាក្លរូស៊ីក្លូអ៊ិកសែន | មីលីក្រាម/គ.ក្រ | <0.000៥ |
| ៦៣ | កាបារីល ($C_{12}H_{11}NO_2$) | មីលីក្រាម/គ.ក្រ | <0.00៥ |
| ៦៤ | កាបូហ្វូរ៉ាន់ ($C_{12}H_{15}NO_2$) | មីលីក្រាម/គ.ក្រ | <0.0២ |

| ល.រ | ឈ្មោះសាធាតុគីមី | ឯកតា (មីលីក្រាម/គ.ក្រ នៃ សំណល់ស្ងួត) | កំហាប់អតិបរិមាណនៃសារធាតុគីមីពុល ដែលអាចអនុញ្ញាតឲ្យមាននៅក្នុងដី |
|---|---|---|---|
| ៦៥ | អាត្រាស៊ីន ($C_8H_{14}ClN_5$) | មីលីក្រាម/គ.ក្រ | <0.0២ |
| ៦៦ | ក្លរដាន ($C_{10}Cl_{10}O$) | មីលីក្រាម/គ.ក្រ | <0.0២ |
| ៦៧ | អិបតាក្លរ ($C_{10}H_5Cl_7$) | មីលីក្រាម/គ.ក្រ | <0.0២ |
| ៦៨ | អិបតាក្លរ អេប៉ុកស៊ីត ($C_{10}H_6Cl_7$) | មីលីក្រាម/គ.ក្រ | <0.0២ |
| ៦៩ | អានដូស៊ុលហ្វាន់ ($C_9H_6Cl_6O_3S$) | មីលីក្រាម/គ.ក្រ | <0.0២ |
| ៧0 | ក្លរឌីកន ($C_{10}Cl_{10}O$) | មីលីក្រាម/គ.ក្រ | <0.0២ |
| ៧១ | សំណរប៉ាហាំងសរីរាង្គ និងសមាសធាតុរបស់វា (C-Sn) | មីលីក្រាម/គ.ក្រ | <0.0២ |
| ៧២ | ប្រេងធម្មជាតិ (Mineral oil) | មីលីក្រាម/គ.ក្រ | <0.១ |
| ៧៣ | ពីរីឌីន ($C_5H_5N$) | មីលីក្រាម/គ.ក្រ | <៥0 |
| ៧៤ | តេត្រូអ៊ីដ្រូហ្វូរ៉ាន់ ($C_4H_8O$) | មីលីក្រាម/គ.ក្រ | <0.១ |
| ៧៥ | ម៉ូណូអេទីឡែនគ្លុយកុល ($C_2H_6O_2$) | មីលីក្រាម/គ.ក្រ | <0.១ |
| ៧៦ | ឌីអេទីលឡែនគ្លុយកុល ($C_4H_{10}O_3$) | មីលីក្រាម/គ.ក្រ | <0.១ |
| ៧៧ | អាគ្រីលឡូនីទ្រីល ($C_3H_3N$) | មីលីក្រាម/គ.ក្រ | <0.0១ |
| ៧៨ | ហ្វម៉ុលដេអ៊ីត ($CH_2O$) | មីលីក្រាម/គ.ក្រ | <0.0១ |
| ៧៩ | មេតាណុល($CH_3OH$) | មីលីក្រាម/គ.ក្រ | <0.១ |
| ៨0 | ប៊ុយតាណុល ($C_4H_9OH$) | មីលីក្រាម/គ.ក្រ | <0.0១ |
| ៨១ | ១,២ ប៊ុយទីឡេសេតាស ($C_6H_{12}O_2$) | មីលីក្រាម/គ.ក្រ | <0.0១ |
| ៨២ | ទ្រីប្រ៊ូមេតាន ($CHBr_3$) | មីលីក្រាម/គ.ក្រ | <0.២ |
| ៨៣ | អេទីឡេសេតាត ($C_4H_8O_2$) | មីលីក្រាម/គ.ក្រ | <0.២ |
| ៨៤ | អ៊ីសូប្រ៊ូប៉ាណុល ($C_3H_7OH$) | មីលីក្រាម/គ.ក្រ | <0.២ |

*សម្គាល់ ៖ រាល់ការចាក់ចោលនូវសំណល់គីមី ឬសាធាតុប្រកបដោយគ្រោះថ្នាក់ដូចមានចែងក្នុងឧបសម្ព័ន្ធខាងលើខុសទីតាំងកំណត់ដោយក្រសួង ស្ថាប័នមានសមត្ថកិច្ចត្រូវបានហាមឃាត់ដាច់ខាត និងត្រូវចាត់ទុកជាការល្មើសច្បាប់។*

## ៣.៥ សារាចរអន្តរក្រសួង

### ៣.៥.១ សារាចរអន្តរក្រសួង ស្តីពីការអនុវត្តន៍អនុក្រឹត្យស្តីពីការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន

ប្រកាសលេខ ១០៧០ ស.ជ.ណ.ប.ស្ក ចុះថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០១៥ ស្តីពីការអនុវត្តន៍អនុក្រឹត្យស្តីពីការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន។

ក្នុងគោលបំណងធ្វើឲ្យប្រសើរឡើងនូវការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនប្រកបដោយប្រសិទ្ធភាព តម្លាភាព និងគណនេយ្យភាព សំដៅធានាបាននូវសោភ័ណភាព កិច្ចគាំពារសុខភាព សាធារណៈនិងបរិស្ថាន

រាជរដ្ឋាភិបាលបានដាក់ចេញនូវអនុក្រឹត្យលេខ ១១៣ អនក្រ.បក ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០១៥ ស្តីពីការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន។ អនុក្រឹត្យនេះមានគោលដៅប្រគល់មុខងារគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនពីរដ្ឋបាលរាជធានី ក្រុង និងស្រុក និងធ្វើប្រតិភូកម្មមុខងារគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំពីរដ្ឋបាលរាជធានីទៅរដ្ឋបាលខណ្ឌ ដែលជាបេត់នៃការគ្រប់គ្រងថ្មីមួយស្របតាមគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការ។

ដើម្បីធានាបាននូវការអនុវត្តន៍អនុក្រឹត្យនេះ ប្រកបដោយភាពរលូន ប្រសិទ្ធភាព និងស័ក្តិសិទ្ធក៏ដូចជាសំដៅកាត់បន្ថយបញ្ហាប្រឈមនានាពាក់ព័ន្ធការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនដែលកំពុងកើតមាននៅតាមបណ្តាទីប្រជុំជនរាជធានី ខេត្ត ក្រសួងមហាផ្ទៃ និងក្រសួងបរិស្ថានសូមធ្វើការណែនាំការអនុវត្តន៍មួយចំនួនដូចខាងក្រោម ៖

១.ថ្នាក់ជាតិ ៖

ក្រសួងមហាផ្ទៃ និងក្រសួងបរិស្ថានត្រូវសម្របសម្រួលជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុក្នុងការរៀបចំបង្កើតក្រុមការងារអន្តរក្រសួងមួយដើម្បីពិភាក្សា និងសម្របសម្រួលជាមួយរដ្ឋបាលថ្នាក់ជាតិក្នុងការផ្ទេរការអនុវត្តន៍ និងការទទួលខុសត្រូវលើការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន ពីរដ្ឋបាលខេត្តទីឲ្យរដ្ឋបាលក្រុង ស្រុក និងប្រតិភូកម្មការអនុវត្តន៍ និងទទួលខុសត្រូវលើការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនពីរដ្ឋបាលរាជធានីទៅឲ្យរដ្ឋបាលខណ្ឌ។

ក្រុមការងារអន្តរក្រសួងនេះមានភារកិច្ចដូចខាងក្រោម ៖

- រៀបចំការផ្សព្វផ្សាយអនុក្រឹត្យ និងលិខិតបទដ្ឋាន និងឯកសារពាក់ព័ន្ធនិងការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនដល់រដ្ឋបាលថ្នាក់ក្រោមជាតិ
- ចុះសិក្សា ប្រមូលព័ត៌មាន និងរៀបចំផែនការដើម្បីសម្របសម្រួលដល់ការផ្ទេរ និងអនុវត្តន៍មុខងារគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន
- ពិនិត្យតាមដានវាយតម្លៃ និងរៀបចំសិក្ខាសាលាដើម្បីឆ្លុះបញ្ចាំង និងដកស្រង់បទពិសោធន៍លើការអនុវត្តន៍មុខងារគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន
- រៀបចំរបាយការណ៍វឌ្ឍនភាព និងបង្ហាញប្រឈមនានាអំពីការអនុវត្តន៍អនុក្រឹត្យនេះ ជូនរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងបរិស្ថាន និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុដើម្បីធ្វើរបាយការណ៍ជូនប្រមុខរាជរដ្ឋាភិបាល។

២.រដ្ឋបាលរាជធានី ត្រូវ ៖

- ផ្សព្វផ្សាយអំពីខ្លឹមសារនៃអនុក្រឹត្យលិខិតបទដ្ឋាន និងឯកសារបច្ចេកទេសពាក់ព័ន្ធនិងការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនដល់រដ្ឋបាលខណ្ឌ សង្កាត់ មន្ទី អង្គភាពជំនាញពាក់ព័ន្ធ និងប្រជាពលរដ្ឋក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ព្រមទាំងពាក់ព័ន្ធនានាដើម្បីឲ្យបានយល់ជ្រួតជ្រាបពីតួនាទីភារកិច្ចរៀងខ្លួនដូចមានចែងក្នុងអនុក្រឹត្យលេខ ១១៣
- ពិគ្រោះយោបល់ជាមួយរដ្ឋបាល និងសង្កាត់ក្នុងដែនសមត្ថកិច្ចរបស់ខ្លួនដើម្បីពិនិត្យលទ្ធភាពក្នុងការធ្វើប្រតិភូកម្មទៅឲ្យរដ្ឋបាលខណ្ឌ ឬ/និងសង្កាត់នូវមុខងារគ្រប់គ្រងសំរាម សំណល់ទីប្រជុំជនមួយផ្នែក ឬទាំងស្រុងដោយភ្ជាប់ជាមួយធនធាន មធ្យោបាយ និងសម្ភារៈ
- ពិនិត្យការអនុវត្តន៍កិច្ចសន្យាសេវាគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនកន្លងមក និងធ្វើការពិគ្រោះយោបល់ជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ និងអ្នកផ្តល់សេវា ដើម្បីធ្វើការកែសម្រួលកិច្ចសន្យាដោយ

ពិនិត្យលទ្ធភាពក្នុងការផ្ទេរការអនុវត្តន៍កិច្ចសន្យាទៅឲ្យរដ្ឋបាលខណ្ឌ ឲ្យស្របទៅនិងតម្រូវការជាក់ស្តែង និងខ្លឹមសារនៃអនុក្រឹត្យលេខ១១៣

- រៀបចំផែនការ និងវិធានការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនដោយមានការសហការណ៍ចូលរួមពីមន្ទី អង្គភាពពាក់ព័ន្ធ
- ចាត់ចែងឲ្យមានធុងសំរាមសាធារណៈ និងកំណត់កន្លែងសម្របសម្រាប់ស្តុកសំរាម សំណល់រឹងទីប្រជុំជនបណ្តោះអាសន្នតាមការចាំបាច់ដើម្បីជានាប្រសិទ្ធភាពក្នុងការប្រមុលនិងដឹកជញ្ជូន
- សហការណ៍ជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធពិនិត្យស្ថានភាពទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជនដែលមានស្រាប់ និងសិក្សាស្វែងរកទីតាំងបម្រុងទុកសម្រាប់រៀបចំទីលាន ដោយផ្តោតលើទីតាំងដែលអាចមានលទ្ធភាពសម្រាប់ការប្រើប្រាស់រួមគ្នារវាងរាជធានី និងខេត្តដែលមានព្រំប្រទល់ជាប់គ្នា
- អនុវត្តន៍តួនាទី និងការកិច្ចផ្សេងទៀតដូចមានចែងនៅក្នុងអនុក្រឹត្យលេខ ១១៣។

៣.រដ្ឋបាលខេត្ត ត្រូវ ៖

- ផ្សព្វផ្សាយអំពីខ្លឹមសារនៃអនុក្រឹត្យ លិខិតបទដ្ឋាន និងឯកសារបច្ចេកទេសពាក់ព័ន្ធ និងការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនជនដល់រដ្ឋបាលក្រុង ស្រុក ឃុំ សង្កាត់ មន្ទី អង្គភាពជំនាញពាក់ព័ន្ធ និងប្រជាពលរដ្ឋក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ព្រមទាំងអ្នកពាក់ព័ន្ធនានា ដើម្បីឲ្យបានយល់ជ្រាបពីតួនាទីការកិច្ចរៀងៗខ្លួនដូចមានចែងក្នុងអនុក្រឹត្យលេខ ១១៣
- ប្រគល់មុខងារគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន ដោយត្រូវពិនិត្យ និងបែងចែកធនធានមធ្យោបាយ និងសម្ភារៈដែលបាននិងកំពុងប្រើប្រាស់ក្នុងការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនទៅឲ្យរដ្ឋបាលក្រុង ស្រុក
- ពិនិត្យការអនុវត្តន៍កិច្ចសន្យាសេវាគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនដែលបាន និងកំពុងអនុវត្តន៍និងធ្វើការពិគ្រោះយោបល់ជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ និងអ្នកផ្តល់សេវា ដើម្បីកែសម្រួលកិច្ចសន្យា និងផ្ទេរការចុះកិច្ចសន្យា និងការគ្រប់គ្រងការអនុវត្តន៍កិច្ចសន្យាទៅឲ្យរដ្ឋបាលក្រុង ស្រុកឲ្យស្របទៅនិងខ្លឹមសារនៃអនុក្រឹត្យលេខ ១១៣
- ណែនាំសម្របសម្រួល និងជំរុញដល់រដ្ឋបាលក្រុង ស្រុកក្នុងការរៀបចំផែនការ និងវិធានការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនដោយមន្ទី និងអង្គភាពពាក់ព័ន្ធ
- ជំរុញ និងការគាំទ្រដល់រដ្ឋបាលក្រុងស្រុកក្នុងការពិនិត្យស្ថានភាពទីលានទុកដាក់សំរាមសំណល់រឹងទីប្រជុំជនដែលមានស្រាប់ និងការសិក្សាស្វែងរកទីតាំងសម្រាប់រៀបចំទីលាន ដោយផ្តោតលើទីតាំងដែលអាចមានលទ្ធភាពសម្រាប់ការប្រើប្រាស់រួមគ្នារវាងក្រុង ស្រុកដែលមានព្រំប្រទល់ជាប់គ្នា
- តាមដាន ត្រួតពិនិត្យការអនុវត្តន៍ការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន
- អនុវត្តន៍តួនាទី និងការកិច្ចផ្សេងទៀតដូចមានចែងនៅក្នុងអនុក្រឹត្យលេខ ១១៣។

៤. រដ្ឋបាលខណ្ឌ សង្កាត់ក្នុងរាជធានី ៖

- រដ្ឋបាលខណ្ឌ ត្រូវពិនិត្យផ្សព្វផ្សាយអំពីខ្លឹមសារនៃអនុក្រឹត្យ លិខិតបទដ្ឋាន និងឯកសារបច្ចេកទេសពាក់ព័ន្ធ និងការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនដល់រដ្ឋបាលរបស់ខ្លួន រដ្ឋបាលសង្កាត់ អង្គភាពជំនាញពាក់ព័ន្ធ និងប្រជាពលរដ្ឋក្នុងដែនសមត្ថកិច្ចរបស់ខ្លួនព្រមទាំងអ្នកពាក់ព័ន្ធនានាដើម្បីឲ្យ

Draft

បានយល់ជ្រួតជ្រាបពីតួនាទី ភារកិច្ចរៀងៗខ្លួនដូចមានចែងក្នុងអនុក្រឹត្យលេខ ១១៣ និងមុខងារដែលទទួលបានពីការធ្វើប្រតិភូកម្មរបស់រដ្ឋបាលរាជធានី

- រដ្ឋបាលសង្កាត់ត្រូវបន្តផ្សព្វផ្សាយខ្លឹមសារនៃអនុក្រឹត្យ លិខិតបទដ្ឋាន និងឯកសារបច្ចេកទេសពាក់ព័ន្ធ និងការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនដល់រដ្ឋបាលរបស់ខ្លួនរដ្ឋ ដើម្បីឲ្យបានយល់ជ្រួតជ្រាបពីតួនាទី ភារកិច្ចរៀងៗខ្លួនដូចមានចែងក្នុងអនុក្រឹត្យលេខ ១១៣
- រដ្ឋបាលខណ្ឌ និងរដ្ឋបាលសង្កាត់ ត្រូវអនុវត្តន៍តួនាទី ភារកិច្ចផ្សេងទៀតដូចមានចែងក្នុងអនុក្រឹត្យលេខ ១១៣ និងមុខងារដែលទទួលបានពីការធ្វើប្រតិភូកម្មរបស់រដ្ឋបាលរាជធានី។

៥. រដ្ឋបាលក្រុងស្រុក ត្រូវ ៖

- ផ្សព្វផ្សាយអំពីខ្លឹមសារនៃអនុក្រឹត្យ លិខិតបទដ្ឋាន និងឯកសារបច្ចេកទេសពាក់ព័ន្ធ និងការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនដល់រដ្ឋបាលរបស់ខ្លួន រដ្ឋបាលឃុំ អង្គភាពជំនាញពាក់ព័ន្ធ និងប្រជាពលរដ្ឋក្នុងដែនសមត្ថកិច្ចរបស់ខ្លួនព្រមទាំងអ្នកពាក់ព័ន្ធនានាដើម្បីឲ្យបានយល់ជ្រួតជ្រាបពីតួនាទីភារកិច្ចរៀងៗខ្លួនដូចមានចែងក្នុងអនុក្រឹត្យលេខ ១១៣
- ពិនិត្យលើការលទ្ធភាពក្នុងការធ្វើប្រតិភូកម្មមុខងារមួយផ្នែកនៃការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនទៅរដ្ឋបាលឃុំ សង្កាត់
- សហការណ៍ពិនិត្យលើការសន្យាកន្លងមក និងធ្វើការពិគ្រោះយោបល់ជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ និងអ្នកផ្តល់សេវាដើម្បីកែសម្រួលកិច្ចសន្យាឲ្យស្របទៅ និងតម្រូវការជាក់ស្តែងនិងខ្លឹមសារនៃអនុក្រឹត្យលេខ ១១៣
- ក្នុងករណីមិនទាន់មានសេវាគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន ត្រូវរៀបចំឲ្យមានសេវាគ្រប់គ្រងនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ស្របតាមខ្លឹមសារនៃអនុក្រឹត្យលេខ ១១៣
- សិក្សាឲ្យច្បាស់លាស់ពីស្ថានភាពនៃការបង្កើតសំរាម សំណល់រឹងទីប្រជុំជន ក្នុងដែនសមត្ថកិច្ចរបស់ខ្លួន មានជាអាទិ៍ប្រភេទ និងបរិមាណសំណល់
- រៀបចំផែនការ និងវិធានការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន ដោយមន្ទីរ និងអង្គភាពពាក់ព័ន្ធ និងអង្គភាពជំនាញ រួមជាមួយការលើកកម្ពស់ការកាត់បន្ថយបរិមាណសំណល់ដែលបង្កើត និងត្រូវបានបោះបង់ចោល
- ផ្សព្វផ្សាយ និងណែនាំដល់ប្រជាពលរដ្ឋក្នុងការប្រើប្រាស់សេវាគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន ដោយលើកកម្ពស់ការញែកនៅនិងប្រភេទ ការវេចខ្ចប់ និងការបញ្ចេញឲ្យបានត្រឹមត្រូវនូវសំរាម សំណល់រឹងទីប្រជុំជន និងការចូលរួមកាត់បន្ថយការបង្កើតសំរាម សំណល់រឹងទីប្រជុំជន
- ចាត់ចែងឲ្យមានធុងសំរាមសាធារណៈ និងកំណត់កន្លែងសមស្របសម្រាប់ស្តុកសំរាម សំណល់រឹងទីប្រជុំជនបណ្តោះអាសន្នតាមការចាំបាច់ ដើម្បីធានាប្រសិទ្ធភាពក្នុងប្រមូល និងដឹកជញ្ជូន

- សហការជាមួយរដ្ឋបាលខេត្ត មន្ទីរ និងអង្គភាពជំនាញដើម្បីសិក្សាពីស្ថានភាពទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជនដែលមានស្រាប់និងសិក្សាស្វែងរកទីតាំងសម្រាប់រៀបចំទីលានថ្មីដោយផ្តោតលើទីតាំងដែលមានលទ្ធភាពសម្រាប់ការប្រើប្រាស់រួមគ្នារវាងក្រុង ស្រុកដែលមានព្រំប្រទល់ជាប់គ្នា ដើម្បីស្នើសុំការពិនិត្យសម្រេចពីរដ្ឋបាលខេត្ត និងក្រសួងបរិស្ថាន
- អនុវត្តន៍តួនាទី និងភារកិច្ចផ្សេងទៀតដូចមានចែងនៅក្នុងអនុក្រឹត្យលេខ ១១៣។

៦. រដ្ឋបាលឃុំក្នុងស្រុក និងសង្កាត់ក្នុងក្រុង ត្រូវ ៖

- បន្តផ្សព្វផ្សាយអំពីខ្លឹមសារនៃអនុក្រឹត្យ លិខិតបទដ្ឋាន និងឯកសារបច្ចេកទេសពាក់ព័ន្ធ និងការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនដល់រដ្ឋបាលរបស់ខ្លួន អ្នកពាក់ព័ន្ធ និងប្រជាពលរដ្ឋដើម្បីឲ្យបានយល់ជ្រួតជ្រាបពីតួនាទី ភារកិច្ចរៀងៗខ្លួនដូចមានចែងក្នុងអនុក្រឹត្យ និងមុខងារដែលទទួលបានពីការធ្វើប្រតិភូកម្មរបស់រដ្ឋបាលក្រុង ស្រុក។
- អនុវត្តន៍តួនាទី និងភារកិច្ចផ្សេងទៀតដូចមានចែងនៅក្នុងអនុក្រឹត្យលេខ ១១៣ និងមុខងារដែលទទួលបានពីការធ្វើប្រតិភូកម្មរបស់រដ្ឋបាលក្រុង ស្រុក។

៧. មន្ទីរបរិស្ថានរាជធានី ខេត្ត ត្រូវ៖

- ផ្សព្វផ្សាយដល់មន្ត្រី បុគ្គលិកក្នុងអង្គភាពរបស់ខ្លួនអំពីខ្លឹមសារនៃអនុក្រឹត្យ លិខិតបទដ្ឋាន និងឯកសារបច្ចេកទេសពាក់ព័ន្ធ និងការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន
- សហការជាមួយរដ្ឋបាលរាជធានី ខេត្ត ក្រុង ខណ្ឌក្នុងការផ្សព្វផ្សាយអំពីខ្លឹមសារនៃអនុក្រឹត្យនិងវិធានការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនប្រកបដោយប្រសិទ្ធភាពដល់អ្នកពាក់ព័ន្ធ និងប្រជាពលរដ្ឋ
- ចូលរួមពិនិត្យយន្តការ និងកិច្ចសន្យាក្នុងគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនដែលមានស្រាប់ ដើម្បីឲ្យស្របតាមស្មារតីអនុក្រឹត្យលេខ ១១៣
- ចូលរួមសហការណ៍រៀបចំផែនការ និងគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជនរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ក៏ដូចជាផ្តល់យោបល់បច្ចេកទេសពាក់ព័ន្ធនិងសំណើ ឬគម្រោងសេវាគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន
- ចូលរួមសហការណ៍សិក្សា និងផ្តល់យោបល់លើការស្វែងរកទីតាំងសម្រាប់រៀបចំទីលានទុកដាក់សំរាម សំណល់រឹងទីប្រជុំជនរបស់រដ្ឋបាលរាជធានី ក្រុង ស្រុក
- តាមដាន ត្រួតពិនិត្យ និងវាយតម្លៃការងារបរិស្ថានពាក់ព័ន្ធការងារគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន និងកែច្នៃសំរាម សំណល់រឹងទីប្រជុំជន
- ជំរុញការអនុវត្តន៍វិធានការច្បាប់ពាក់ព័ន្ធ និងការគ្រប់គ្រងសំរាមសំណល់រឹងទីប្រជុំជន
- អនុវត្តន៍តួនាទី ភារកិច្ចផ្សេងទៀតដូចមានចែងក្នុងអនុក្រឹត្យលេខ ១១៣។

ទទួលបានសាពចរអន្តក្រសួងនេះ គ្រប់អង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងមហាផ្ទៃ និងក្រសួងបរិស្ថាន គ្រប់រដ្ឋបាលថ្នាក់ជាតិ មន្ទីរបរិស្ថានរាជធានី ខេត្តត្រូវសហការណ៍ផ្សព្វផ្សាយ និងអនុវត្តន៍ឲ្យមានប្រសិទ្ធភាព និងស្មារតីទទួលខុសត្រូវខ្ពស់។

## ៣.៦ សេចក្ដីសម្រេច

### ៣.៦.១ សេចក្ដីសម្រេចស្ដីពីការកំណត់តំបន់ទាំងបី ដើម្បីការពារបរិវេណប្រាសាទនៅកណ្ដាលខេត្ត-ក្រុង ក្រៅពីតំបន់អង្គរ-សៀមរាប

យោងតាមលិខិតលេខ០១ ស.រ នៃក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ចុះថ្ងៃទី០៦ ខែមករា ឆ្នាំ១៩៩៦ រាជធានីភ្នំពេញ ស្ដីពីសេចក្ដីសម្រេចស្ដីពីការកំណត់តំបន់ទាំងបី ដើម្បីការពារបរិវេណប្រាសាទនៅកណ្ដាលខេត្ត-ក្រុង ក្រៅពីតំបន់អង្គរ-សៀមរាប នេះមានដូចតទៅ៖

ប្រការ១ ..

បង្កើតការកំណត់ និងការចាត់ចែងគ្រប់គ្រងថែរក្សាការពារប្រាសាទបុរាណ ទីតាំងស្ថានីយ៍ប្រវត្តិ និងបុរេប្រវត្តិ និងរមណីយដ្ឋានបប្រវត្តិសាស្ត្រសាស្ត្រជាបីតំបន់:

ក-តំបន់ទី១ : ជាតំបន់ប្រាសាទ។

- ហាមប៉ះពាល់ដាច់ខាត។ ត្រូវបានកំណត់ព្រំប្រទល់ចម្ងាយ ៣០ម៉ែត្រ ពីកំផែងខាងក្រៅប្រាសាទ។ បើមានស្រះព័ទ្ធជុំវិញប្រាសាទ ត្រូវកំណត់ចម្ងាយ ៣០ម៉ែត្រពីមាត់ស្រះខាងក្រៅរបស់ប្រាសាទ។ តំបន់នេះមិនឲ្យមានដាំដើមឈើទេ ចៀសវាងឈើដួលរលំសង្កត់លើកំផែងប្រាសាទ។

ខ-តំបន់ទី២ : ជាតំបន់ឧទ្យានបុរាណវិទ្យា។

- ត្រូវការពារថែរក្សា។ តំបន់នេះ ត្រូវបានកំណត់បរិវេណចម្ងាយ ៣០០ ម៉ែត្រពីព្រំប្រទល់តំបន់១។

គ.តំបន់ទី៣ : ជាតំបន់ត្រូវប្រើប្រាស់ដីធ្លីតាមបទបញ្ញត្តិ។ មានព្រំប្រទល់ចម្ងាយ ១៥០០ ម៉ែត្រពីក្រៅកំផែងប្រាសាទ ឬ ១៥០០ ម៉ែត្រពីមាត់ស្រះព័ន្ធជុំវិញខាងក្រៅ។

- ព្រំប្រទល់បរិវេណខាងក្រៅនៃតំបន់៣ ត្រូវត្រួសត្រាយធ្វើផ្លូវដែលមានទំហំទទឹង ៥ ម៉ែត្រព័ន្ធជុំវិញ ដើម្បីកំណត់ព្រំប្រទល់បរិវេណប្រាសាទផ្នែកខាងក្រៅផ្លូវព័ន្ធជាតំបន់របស់ការិយាល័យរុក្ខាប្រមាញ់ខេត្ត-ក្រុង។
- រមណីយដ្ឋានទីតាំងស្ថានីយ៍បុរេប្រវត្តិ និងប្រវត្តិសាស្ត្រផ្សេងៗ ត្រូវវាបានកំណត់ផ្ទៃបរិវេណ ៥០០ ម៉ែត្រព័ន្ធជុំវិញ។

ប្រការ២ ..

តំបន់១ ៖ ជាតំបន់ត្រូវថែរក្សាការពារ ដាច់ខាតមិនឲ្យមានការប៉ះពាល់រុករកគាស់កកាយឡើយ ទោះជានៅលើអាកាស លើផ្ទៃដីក៏ដូចជានៅក្រោមដី។

- មិនឲ្យដាំដើមឈើដុះនៅក្នុងតំបន់នេះ ចៀសវាងពេលមានបាតុភូតផ្សេងៗធ្វើឲ្យខូចខាតដល់ប្រាសាទបុរាណ។
- ហាមធ្វើការហោះហើរយន្តហោះគ្រប់ប្រភេទលើតំបន់នេះ។
- ហាមយកសម្ភារៈសំណង់ប្រាសាទដូចជា ឥដ្ឋ ឬ វត្ថុសិល្បៈ ក្បូរក្បាច់ខូចក្រឡ ចេញពីកន្លែងដើម។ អាចយកចេញបានលុះត្រាតែស្ថិតក្នុងករណីពិសេស និងមានការអនុញ្ញាតពីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ។
- ហាមសាងសង់សំណង់តូច-ធំគ្រប់ប្រភេទនៅក្នុងតំបន់នេះ។

Draft

- ហាមធ្វើការត្រួសត្រាយ គាស់កកាយព្រៃ ធ្វើចម្ការ ឬដំណាំផ្សេងៗ។
- ហាមឃ្វាល ឬចង និងប្រលែងសត្វពាហនៈក្នុងបរិវេណនេះ។
- ហាមធ្វើអាជីវកម្ម សេវាកម្ម លក់ដូរ នៅក្នុងបរិវេណប្រាសាទព្រោះតំបន់នេះក៏ត្រូវថែរក្សាការពារដូចតួប្រាសាទដែរ។
- ហាមបើកបររថយន្តតូច-ធំលើសល្បឿន ៣០ គ.ម ក្នុងមួយម៉ោងដែលបានកំណត់ក្នុងមាត្រា ៤៣ នៃក្រិតច្បាប់លេខ ២១ ក្រច ចុះថ្ងៃទី ១៨ មិនា ១៩៨៥ របស់ក្រុមប្រឹក្សារដ្ឋ។
- រថយន្តទាំងអស់ត្រូវចតក្នុងចំណតដែលនាយកដ្ឋានបេតិកភណ្ឌបានកំណត់ទុក។

តំបន់២ ៖ ជាតំបន់ត្រូវធ្វើការថែរក្សា ការពារ និងហាមឃាត់ដូចខាងក្រោម៖

- ហាមប៉ះពាល់ដល់សម្បត្តិធម្មជាតិ ព្រៃឈើ និងបេតិកភណ្ឌវប្បធម៌នៅក្នុងតំបន់នេះ។
- ហាមធ្វើកំណាយផ្សេងៗ។ អាចធ្វើបានលុះត្រាតែមានការអនុញ្ញាតពីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈជាមុនសិន។
- ហាមកាប់គាស់រានដីដើម្បីប្រកបរបរកសិកម្ម និងសិប្បកម្មផ្សេងៗ។
- ហាមសាងសង់លំនៅដ្ឋាន ឬសំណង់សាធារណៈនៅក្នុងតំបន់។ អាចសង់បានលុះត្រាតែមានការអនុញ្ញាតពីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈសិន។
- ត្រូវបំផុសការដាំដុះដើមឈើជាលក្ខណៈធម្មជាតិឡើងវិញ ដើម្បីជារបាំងការពារខ្យល់ព្យុះផ្សេងៗដែលប៉ុនប៉ងដល់ប្រាង្គសិលា។

តំបន់៣ ៖ ជាតំបន់ដែលត្រូវរក្សាទុកជារមណីយដ្ឋាន និងជាឧទ្យានសម្រាប់ការការពារបរិស្ថានប្រវត្តិសាស្ត្រ និងបុរាណវិទ្យា។

- ជាតំបន់ថែរក្សាការពារមិនអនុញ្ញាតឲ្យមានកម្មសិទ្ធិដីធ្លី និងកេរ្តិ៍មរតករបស់ឯកជនឡើយ។
- ក្នុងករណីដែលមានកម្មសិទ្ធិដីធ្លី ឬមានការសាងសង់លំនៅដ្ឋានរួចហើយនោះត្រូវទុកនៅដដែលសិនតែដាច់ខាតមិនឲ្យពង្រីកកម្មសិទ្ធិបន្ថែម ឬតាំងទីលំនៅដ្ឋានថ្មី ឬលក់ដូរ និងផ្ទេរសិទ្ធិឡើយ។
- វត្តអារាម នៅក្នុងបរិវេណប្រាសាទ ដាច់ខាតមិនឲ្យពង្រីក ឬគាស់កកាយនៅក្នុងតំបន់នេះឡើយ។ ត្រូវរក្សាភាពដើមសិន។
- ត្រូវរក្សាការពារព្រៃឈើគ្រប់ប្រភេទឲ្យបានគង់វង្ស និងជំពាត់ល្អសម្រាប់ជារបាំងការពារខ្យល់ព្យុះសង្ឃរាផ្សេងៗ ដែលប៉ុនប៉ងយាយីដល់ប្រាង្គប្រាសាទបុរាណ។ ដាច់ខាតមិនឲ្យដាំដើមប្រេងខ្យល់ ឬដើមអាកាស្យាក្នុងតំបន់។
- សម្បត្តិធម្មជាតិ ដែលមាននៅក្នុងតំបន់ត្រូវថែរក្សាការពារ និងត្រូវដាំដុះបន្ថែមជារៀងរាល់ឆ្នាំ។ ការដាំដុះនេះត្រូវបែងចែកអ្នកទទួលខុសត្រូវលើការដាំដុះ និងថែរក្សាការពារកូនឈើឲ្យបានល្អ។

Draft

- ហាមសាងសង់សំណង់ថ្មីនៅក្នុងតំបន់។ លើកលែងតែមានករណីពិសេសដែលអនុញ្ញាតពីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈហើយសំណង់នោះមិនហួសពី ៦ម៉ែត្រ។ ត្រូវធ្វើបង្គោលសីមាដាក់ឈ្មោះប្រាសាទរមណីយដ្ឋាន។
- ត្រូវបោះបង្គោល ដាក់ផ្លាក់សម្គាល់បរិវេណប្រាសាទនៅគ្រប់ទិស ដើម្បីកំណត់ព្រំប្រទល់ងាយស្រួលដល់ប្រជាពលរដ្ឋក្តាប់ជាប់។

ប្រការ៣ ..

- ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ អភិបាលខេត្ត-ក្រុង និងអង្គភាពអភិរក្សប្រាសាទបុរាណនៅតាមខេត្ត-ក្រុង ត្រូវសហការណ៍ណែនាំបំផុស អប់រំប្រជាពលរដ្ឋដែលរស់នៅតំបន់ឲ្យយល់ពីការអនុញ្ញាតឲ្យការរស់នៅតំបន់នេះនិងយល់ពីភារកិច្ច និងកាតព្វកិច្ចរបស់ប្រជាពលរដ្ឋម្នាក់ៗ គ្រួសារនិមួយៗចូលរួមថែរក្សាការពារ និងឈប់បំផ្លាញសម្បត្តិវប្បធម៌ និងសម្បត្តិធម្មជាតិដូចជា ការកាប់គាស់រានដី ធ្វើស្រែចម្ការ ដុតធ្យូង កាប់ឈើដុតយកជ័រក្នុងតំបន់ហាមឃាត់។
- ចំពោះប្រជាពលរដ្ឋថ្មី គ្រួសារថ្មីដែលទើប និងមកតាំងទីលំនៅក្នុងខេត្ត-ក្រុងអភិបាលខេត្ត-ក្រុង ត្រូវមានផែនការរៀបចំការតាមការកំណត់របស់ខេត្ត-ក្រុង ដោយធ្វើយ៉ាងណាមិនឲ្យប៉ះពាល់ដល់តំបន់ដែលត្រូវការពារ និងចៀសវាងការមានទស្សនៈរបស់ប្រជាពលរដ្ឋដែលបើកភ្នែកសំឡឹងឃើញតែឈើជ័រ វល្លិ៍ និងជីករានដីដាំដំណាំផ្សេងៗនៅក្នុងតំបន់ហាមឃាត់។

ប្រការ៤ ..

- ការគ្រប់គ្រងប្រាសាទ និងព្រៃឈើនៅក្នុងតំបន់ទាំងបីជាសមត្ថកិច្ចរបស់អង្គភាពអភិរក្សប្រាសាទបុរាណ និងនាយកដ្ឋានបេតិកភណ្ឌ។ ប៉ុន្តែការពាក់ព័ន្ធដល់បច្ចេកទេសព្រៃឈើ ត្រូវពិភាក្សាជាមួយក្រសួងកសិកម្ម ឬមន្ទីកសិកម្មខេត្ត-ក្រុង តាមខ្លឹមសារក្រិតច្បាប់លេខ៣៥ ក្រច ចុះថ្ងៃទី២៥ ខែមិថុនា ឆ្នាំ១៩៨៨ និងក្រិតច្បាប់លេខ ២១ ក្រច ចុះថ្ងៃទី ១៨ មិនា ឆ្នាំ១៩៨៥ ស្តីពីការគ្រប់គ្រងបេតិកភណ្ឌវប្បធម៌ប្រវត្តិសាស្ត្រ រមណីយដ្ឋាន វិមានធម្មជាតិរបស់ក្រុមប្រឹក្សារដ្ឋ។

ប្រការ៥ ..

- អគ្គនាយកឧទ្ទកាល័យ អគ្គនាយកបេតិកភណ្ឌវប្បធម៌ ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ អភិបាលខេត្ត-ក្រុង ក្រសួងកសិកម្ម ក្រសួងទេសចរណ៍ ក្រសួងការពារប្រទេស ក្រសួងមហាផ្ទៃ ក្រសួងធម្មការ និងកិច្ចការសាសនា និងក្រសួងផ្សេងៗដែលពាក់ព័ន្ធ មានការកិច្ចអនុវត្តន៍សេចក្តីសម្រេចនេះឲ្យមានប្រសិទ្ធភាពខ្ពស់។

ប្រការ៦ ..

- សេចក្តីសម្រេចនេះ ចូលរួមជាធរមាននៃច្បាប់ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

## ៣.៧ គោលនយោបាយ

### ៣.៧.១ គោលនយោបាយចតុកោណដំណាក់កាលទី៣ របស់រាជរដ្ឋាភិបាល

យុទ្ធសាស្រ្តចតុកោណត្រូវបានរៀបចំឡើងទៅតាមរចនាសម្ព័ន្ធជាមុំបួននៃចតុកោណដែលប្រទាក់ក្រឡាគ្នា ហើយផ្សារភ្ជាប់នៅគ្រប់ជ្រុងទាំងអស់។ ជារួមសមាសធាតុនៃយុទ្ធសាស្រ្តចតុកោណដំណាក់កាលទី ៣ របស់រាជរដ្ឋាភិបាល នីតិកាលទី ៥ នៃរដ្ឋសភា ចុះ ខែកញ្ញា ឆ្នាំ ២០១៣ នេះមានដូចតទៅ ៖

ចតុកោណទី១ : ការលើកស្ទួយវិស័យកសិកម្ម

- មុំទី១ : ការលើកកម្ពស់ផលិតភាព ពិពិធកម្មរូបនីយកម្ម និងពាណិជ្ជូបនីយកម្ម
- មុំទី២ : ការលើកកម្ពស់ការចញ្ចឹមសត្វ និងវារីវប្បកម្ម
- មុំទី៣ : ការកែទម្រង់ដីធ្លី ការបោសសម្អាតមីន និងសំណល់ជាតិផ្ទុះពីសង្គ្រាម
- មុំទី៤ : ការគ្រប់គ្រងធនធានធម្មជាតិប្រកបដោយចីរភាព

ចតុកោណទី២ : ការអភិវឌ្ឍវិស័យហេដ្ឋារចនាសម្ព័ន្ធរូបវន្ត

- មុំទី១ : ការអភិវឌ្ឍវិស័យហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍ និងហេដ្ឋារចនាសម្ព័ន្ធទីក្រុង
- មុំទី២ : ការគ្រប់គ្រងធនធានទឹក និងប្រព័ន្ធធារាសាស្រ្ត
- មុំទី៣ : ការអភិវឌ្ឍវិស័យថាមពលអគ្គិសនី
- មុំទី៤ : ការអភិវឌ្ឍបច្ចេកវិទ្យាព័ត៌មាន និងគមនាគមន៍

ចតុកោណទី៣ : ការអភិវឌ្ឍវិស័យឯកជន និងការងារ

- មុំទី១ : ការពង្រឹងវិស័យឯកជន និងការជំរុញការវិនិយោគ និងធុរៈកិច្ច
- មុំទី២ : ការអភិវឌ្ឍឧស្សាហកម្ម និងសហគ្រាសធុនតូច និងមធ្យម
- មុំទី៣ : ការអភិវឌ្ឍទីផ្សារការងារ
- មុំទី៤ : ការអភិវឌ្ឍវិស័យធនាគារ និងហិរញ្ញវត្ថុ

ចតុកោណទី៤ : ការកសាងសមត្ថភាព និងការអភិវឌ្ឍធនធានមនុស្ស

- មុំទី១ : ការពង្រឹង និងការលើកកម្ពស់វិស័យអប់រំ វិទ្យាសាស្រ្ត បច្ចេកវិទ្យា ព្រមទាំងការបណ្តុះបណ្តាលបច្ចេកទេស
- មុំទី២ : ការលើកកម្ពស់សុខភាព និងអាហារូបត្ថម្ភ
- មុំទី៣ : ការអភិវឌ្ឍប្រព័ន្ធគាំពារសង្គម
- មុំទី៤ : ការជំរុញអនុវត្តន៍គោលនយោបាយជាតិប្រជាជន និងសមភាពយេនឌ័រ។

រាជរដ្ឋាភិបាលបន្តផ្តល់អាទិភាពខ្ពស់ទៅលើការលើកកម្ពស់ផលិតភាព និងការធ្វើពិពិធកម្មរូបនីយកម្មកសិកម្មព្រមទាំងបន្តជំរុញកសិ-ពាណិជ្ជកម្ម។ រាជរដ្ឋាភិបាលនឹងបន្តយកចិត្តទុកដាក់លើការពង្រីកសមត្ថភាពផលិតលើផ្ទៃដីដែលមានស្រាប់ តាមរយៈការបង្វែរទិសពីការអភិវឌ្ឍតាមបែបបើកទូលាយ ឬតាមបែបវិបុលកម្មទៅកាន់អភិវឌ្ឍន៍តាមបែបស៊ីជម្រៅ ឬ តាមបែបប្រពលកម្មក្នុងគោលដៅបង្កើនផលិតកម្ម បង្កើតការងារ បង្កើន



Draft

ប្រាក់ចំណូលនៅជនបទ និងធានានូវសន្តិសុខស្បៀង និងបង្កើនការនាំចេញអង្ករ ដោយផ្តោតទៅលើអន្តរាគមន៍ប្រទាក់ប្រឡាក្នុងវិស័យពាក់ព័ន្ធដូចជា ការប្រើប្រាស់ធាតុចូលកសិកម្មតាមបច្ចេកទេស ការស្រាវជ្រាវអភិវឌ្ឍ និងផ្សព្វផ្សាយកសិកម្ម ការសាងសង់ និងថែទាំហេដ្ឋារចនាសម្ព័ន្ធជនបទ ប្រព័ន្ធធារាសាស្ត្រ ការផ្តល់ឥណទានជនបទ និងមីក្រូហិរញ្ញវត្ថុ ការពង្រឹង ទីផ្សារកសិកម្ម ការរៀបចំសហគមន៍ កសិករ និងការគ្រប់គ្រងដីធ្លីកសិកម្ម។ ក្នុងស្មារតីនេះរាជរដ្ឋាភិបាលខិតខំពង្រឹង និងពង្រីកប្រព័ន្ធសេវាបច្ចេកទេស និងព័ត៌មានកសិកម្ម ដោយជំរុញសេវានេះឲ្យទៅដល់ថ្នាក់ស្រុក ដោយផ្សារភ្ជាប់ជាមួយនឹងបណ្តាញអ្នកស្ម័គ្រចិត្តថ្នាក់ឃុំព្រមទាំងខិតខំធានាចីរភាពនៃប្រព័ន្ធសេវាបច្ចេកទេសកសិកម្មដែលបាននឹងកំពុងអនុវត្តន៍ ក្នុងក្របខណ្ឌនៃគម្រោងអភិវឌ្ឍន៍នានា។

រាជរដ្ឋាភិបាលជំរុញឲ្យមានភាពជាដៃគូរវាងកសិករម្ចាស់ដីតូចៗ និងកសិដ្ឋានខ្នាតធំ សាជីវកម្មកសិកម្ម និងរវាងសម្បទានិកដីសេដ្ឋកិច្ចជាមួយនឹងសម្បទានិកសង្គមកិច្ច ជាពិសេសសម្រាប់ដំណាំកសិ-ឧស្សាហកម្ម ជាអាទិ៍ដំណាំកៅស៊ូស្របតាមផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកៅស៊ូ ដំណាំស្វាយចន្ទី ដំណាំអំពៅ។ រាជរដ្ឋា ភិបាលលើកទឹកចិត្តចំពោះការអភិវឌ្ឍកសិដ្ឋានពហុបំណងក្នុងគោលដៅលើកកម្ពស់ផលិតភាព ការចិញ្ចឹមសត្វ ការដាំដំណាំចម្រុះ និងការគួបផ្សំដំណាំជាមួយការចិញ្ចឹមសត្វ”។

Draft

### ៣.៧.២ គោលនយោបាយជនជាតិដើមភាគតិច

**មាត្រា ២៣..**

សហគមន៍ជនជាតិដើមភាគតិច គឺជាក្រុមមនុស្សដែលរស់នៅលើដែនដីនៃព្រះរាជាណាចក្រកម្ពុជា ដែលសមាជិកទាំងអស់បង្ហាញនូវការឯកភាពនៃជាតិ សង្គម វប្បធម៌ សេដ្ឋកិច្ច ប្រតិបត្តិរបៀបរស់នៅតាមប្រពៃណី និងដាំដុះលើដីដែលខ្លួនកាន់កាប់ទៅតាមក្បួនខ្នាតទំនៀមទម្លាប់នៃការប្រើប្រាស់ជាសមូហភាព។

ក្នុងពេលរងចាំការកំណត់ខាងផ្លូវច្បាប់ នូវលក្ខន្តិកៈរបស់សហគមន៍ក្រុម ដែលមានជាក់ស្តែងមកទល់បច្ចុប្បន្ននេះ និងបន្តគ្រប់គ្រងសហគមន៍ និងអចលនវត្ថុរបស់ខ្លួនតាមប្រពៃណីហើយត្រូវអនុវត្តន៍តាមបញ្ញត្តិនៃច្បាប់នេះ។

**មាត្រា ២៤..**

ចាត់ទុកជាសមាជិកនៃសហគមន៍ជនជាតិដើមភាគតិច ដែលអាចទទួលគុណប្រយោជន៍ពីការធានាសិទ្ធិ និងការការពារដែលរៀបចំឡើងដោយច្បាប់នេះ រាល់បុគ្គលដែលឆ្លើយតបទៅនឹងលក្ខណៈវិនិច្ឆ័យនៃជាតិអំពី វប្បធម៌ និងសង្គមរបស់សហគមន៍ដែលទទួលស្គាល់ដោយមតិភាគច្រើននៃសមាជិកដ៏ទៃទៀត និងដោយព្រមទទួលនូវសាមគ្គីភាព និងភាពចំណុះដែលនាំឲ្យមានការចូលក្នុងសហគមន៍។

**មាត្រា ២៦..**

កម្មសិទ្ធនៃអចលនវត្ថុ ដែលបានចែងក្នុងមាត្រា ២៥ ត្រូវបានផ្តល់ដោយរដ្ឋជូនសហគមន៍ជនជាតិដើមភាគតិចជាកម្មសិទ្ធិសមូហភាព។ កម្មសិទ្ធិសមូហភាពរួមមានរាល់សិទ្ធិ និងការការពារកម្មសិទ្ធិដូចកម្មសិទ្ធិ

ឯកជនដែរ។ ប៉ុន្តែសហគមន៍នោះ គ្មានសិទ្ធិចាត់ចែងនូវចំណែកណាមួយនៃកម្មសិទ្ធិសមូហភាព ដែលជាទ្រព្យសម្បត្តិសាធារណៈរបស់វផ្ទេឲ្យទៅបុគ្គល ឬក្រុមណាមួយបានឡើយ។

ការអនុវត្តន៍នូវសិទ្ធិជាកម្មសិទ្ធិទាក់ទងនឹងអចលនវត្ថុរបស់សហគមន៍ និងលក្ខខណ្ឌជាក់លាក់នៃការប្រើប្រាស់ដីត្រូវស្ថិតនៅក្រោមការទទួលខុសត្រូវរបស់អាជ្ញាធរ ប្រពៃណី និងយន្តការនៃការធ្វើសេចក្តីសម្រេចរបស់សហគមន៍ អនុលោមតាមទំនៀមទម្លាប់របស់ពួកគេ ហើយត្រូវដាក់ឲ្យនៅក្រោមច្បាប់នៃការអនុវត្តន៍ទូទៅទាក់ទង នឹងអចលនវត្ថុដូចជាច្បាប់ការពារបរិស្ថានជាដើម។